# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សយ ប៊ិន ភេទប្រុស (នៅរស់)
## មុខងារ នាវាដើងទឹកកងពល១៦៤
## សម្ភាសជាមួយ សយ ប៊ិន អាយុ៥៩ឆ្នាំ ក្រៅប្រវត្តិរូប
## រស់នៅភូមិវាលធំ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ
## ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៧
## សម្ភាសដោយ ៖ ឡុង ដានី

ដានី ៖ ចុះពូជីបូងអញ្ចឹងខ្ញុំចង់ស្គាល់ឈ្មោះពូពេញ ពូឈ្មោះអីដែរ?

ប៊ិន ៖ បាទ!ខ្ញុំឈ្មោះសយ ប៊ិន ។

ដានី ៖ សយ ប៊ិន ពូសព្វថ្ងៃអាយុប៉ុន្មានហើយ?

ប៊ិន ៖ ខ្ញុំអាយុ៥៩ ។

ដានី ៖ ៥៩ ។ អឺ!ពូមានស្រុកកំណើតកើតជានៅភូមិឃុំស្រុកអីដែរ?

ប៊ិន ៖ នៅភូមិអង្គុញ ឃុំកំពែង ស្រុកគីរីវង្ស ខេត្តតាកែវ ។

ដានី ៖ ឃុំកំពែងហេ៎?

ប៊ិន ៖ បាទ!

ដានី ៖ គីរីវង្ស តាកែវ?

ប៊ិន ៖ បាទ!

ដានី ៖ បាទ! អឺ!គ្រួសារពូឈ្មោះអីដែរ?

ប៊ិន ៖ គ្រួសារខ្ញុំឈ្មោះអឺ!សាយ ផល ។

ដានី ៖ សាយ ផល គាត់អាយុប៉ុន្មានហើយ?

ប៊ិន ៖ គាត់អាយុ៤៧ ។

ដានី ៖ បាទ! គាត់មានស្រុកកំណើតនៅភូមិឃុំស្រុកអីដែរ?

ប៊ិន ៖ មិនទេ ខុសគ្នា ស្រុកកំណើតគាត់នៅអូរយ៉ាហេងនេះ អូរយ៉ាហេងយើង ឃុំអូរយ៉ាហេងៗ អូរយ៉ាហេងយើង អឺ!ព្រៃបប់នេះ ។

ដានី ៖ ព្រៃបប់ៗ បាទៗ នៅឃុំអូរយ៉ាហេង មិនមែនភូមិអូរយ៉ាហេងទេ?

ប៊ិន ៖ បាទ!ភូមិអូរយ៉ាហេង ឃុំអូរយ៉ាហេង ។

ដានី ៖ បាទ!ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់?

ប៊ិន ៖ បាទ!កូនចៅ៣នាក់ ។

ដានី ៖ ៣នាក់?

ប៊ិន ៖ បាទ!

ដានី ៖ ប្រុសប៉ុន្មាន?

ប៊ិន ៖ បាទ!ប្រុស២ ស្រី១ ។

ដានី ៖ បាទ! អឺ!សព្វថ្ងៃពូរស់ក្នុងភូមិឃុំស្រុកអីដែរ សព្វថ្ងៃហ្នឹង?

ប៊ិន ៖ សព្វថ្ងៃ ឥឡូវនឹង ទាំងបច្ចុប្បន្ននឹងហ៎?

ដានី ៖ បាទ!

ប៊ិន ៖ បាទ!អានឹងអឺ! ភូមិគេហៅថាភូមិវាលធំ ។

ដានី ៖ ភូមិវាលធំ?

ប៊ិន ៖ បាទ!ភូមិវាលធំ ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

ដានី ៖ ភូមិវាលធំ ឃុំ?

ប៊ិន ៖ ត្រែងត្រយឹង ស្រុកភ្នំស្រួច ។

ដានី ៖ បាទៗ អឺ!សព្វថ្ងៃពូប្រកបមុខរបររកស៊ីធ្វើអីដែរ?

ប៊ិន ៖ មុខរបរ បើនិយាយពីតួនាទី វាដូចរកប្រាកដអត់ឃើញទេខ្ញុំ ព្រោះម្យ៉ាងក៏ដីតិចៗហើយវាអត់មានដីស្រែ ។ បាទ!ហើយដល់អញ្ចឹងវារកមុខរបរពិតប្រាកដអត់ឃើញណា ។

ដានី ៖ បាទៗ ប៉ុនពូដូចថាជាកងទ័ព ឬក៏ជាកសិករ ឬក៏យ៉ាងម៉េច?

ប៊ិន ៖ អឺ!ចង់និយាយរាល់ថ្ងៃនេះ ឬក៏?

ដានី ៖ បាទៗ ។

ប៊ិន ៖ បាទ!មិនៗជាកងទ័ពទេ បាទ!ជាប្រជាពលរដ្ឋធម្មតា ប៉ុន្តែឥឡូវថាកសិករក៏វាមិនត្រូវ ព្រោះវាអត់មានស្រែធ្វើផង ។ បាទ!ការរកស៊ីចិញ្ចឹមជីវិតសព្វថ្ងៃ វាដូចថារកប្រាកដប្រជាអត់ឃើញ មិនដឹងថា រកអី ។ ប៉ុនទៅដល់មិនដឹងរកអីអញ្ចឹងថា ចុះម៉េចបានជារស់កើត វារកកំណត់មិនឃើញ ប៉ះអីយើងរកនឹង ប៉ះអីរកនឹង អីដែលល្មមថាចិញ្ចឹមជីវិតបាននោះ ម៉ាថ្ងៃរកម៉ាថ្ងៃ ហូបម៉ាថ្ងៃអញ្ចឹងទៅ ។

ដានី ៖ បាទ! អឺ!ពូឪពុកម្តាយពូ គាត់ឈ្មោះអីដែរ?

ប៊ិន ៖ អឺ!ឪពុកខ្ញុំសយ ហួន ហើយម្ដាយ ប៊ិន គួ ប៉ុនគាត់ស្លាប់អស់ហើយ ។

ដានី ៖ គាត់ស្លាប់តាំងពីជំនាន់ណា?

ប៊ិន ៖ បាទ!ស្លាប់ ឪពុកខ្ញុំទើបនឹងស្លាប់ប្រហែលជាអឺ!៩១ បាទ!ស្លាប់៩១ ។

ដានី ៖ បាទ!ចុះម្ដាយ?

ប៊ិន ៖ ម្ដាយខ្ញុំស្លាប់តាំងពី៧១ ១៩៧១ បាទ! ។

ដានី ៖ គាត់ស្លាប់ដោយសារជំងឺ?

ប៊ិន ៖ បាទ!ស្លាប់ដោយសារជម្ងឺ ។

ដានី ៖ ពូបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់ដែរ?

ប៊ិន ៖ បាទ!បងប្អូនទាំងអស់៧នាក់ បាទ! អឺ!ប្រុស៣ ស្រី៤ ។

ដានី ៖ ប្រុស៣ ស្រី៤ ។ ពូកូនទីប៉ុន្មាន?

ប៊ិន ៖ បាទ!កូនទី១ ។

ដានី ៖ បងបង្អស់?

ប៊ិន ៖ បាទ! បង ។

ដានី ៖ កាលពីក្មេងៗពូបានចូលរៀនអីសាលាដែរអត់?

ប៊ិន ៖ បាទ!ចូលរៀន បានចូលរៀនៗ ប៉ុនតែជាប់ត្រឹមកម្រិតសាលា បានន័យថាកាលជំនាន់នោះរៀនដល់ត្រឹមថ្នាក់ទី៦ ។ជំនាន់នោះ ។

ដានី ៖ បាទ!បានទី៦ហ៎?

ប៊ិន ៖ បាទ!

ដានី ៖ ទី៦កាលជំនាន់នោះដូចថា ចេះអាន ចេះសរសេរ ចេះភាសាបារាំងអីខ្លះៗដែរ?

ប៊ិន ៖ បាទ! វាគ្រាន់តែដឹង ទី៦ថាយើងចេះអានអីតិចៗ ។

ដានី ៖ អឺ!ដូចថាកាលនឹងពូ អឺ!ឈប់រៀនឆ្នាំណា មូលហេតុអីបានឈប់រៀន?

ប៊ិន ៖ បាទ!មូលអឺ! ឈប់រៀននៅឆ្នាំ១៩៦៦ បាទ! ។ ហើយមូលហេតុគឺ ទី១សាលានៅឆ្ងាយ គិតទៅពីផ្ទះខ្ញុំទៅសាលារៀន វាឆ្ងាយរហូតដល់កាលនោះដល់ផ្សារគិរីវង្សនោះ បាទ!សាលានៅផ្សារគិរីវង្ស ។ ហើយអញ្ចឹងពីផ្ទះខ្ញុំ ពីអន្លុញនឹងឆ្ងាយ ហើយនឹងមួយ ២ទៀតតែម្នាក់ឯងសុទ្ធ នៅតែម្នាក់ឯងគត់ ដល់អញ្ចឹងវាមិនសូវមានទឹកចិត្តដែរ តែម្នាក់ឯង អានោះឈប់ មូលហេតុអញ្ចឹងទេ ។

ដានី ៖ បាទៗ កាលនឹងពូឈប់ឆ្នាំ៦៦នឹង ដោយសារតែមូលហេតុសាលាឆ្ងាយ ហើយនៅភូមិនឹងមានអ្នកទៅរៀន តែពូ?

ប៊ិន ៖ តែម្នាក់ឯង បាទ!ៗ

ដានី ៖ ដល់ពេលពូឈប់រៀនទៅ ពូធ្វើអីវិញទៅ?

ប៊ិន ៖ បាទ!ឈប់រៀន កាលនោះអឺ!ខ្ញុំមកជួយការងារឪពុកម្តាយនៅផ្ទះ បាទ!ៗ

ដានី ៖ ជួយខាងស្រែចំការ?

ប៊ិន ៖ បាទៗខាងស្រែចំការ យើងនៅខាងខ្ញុំនោះមិនមានចំការទេ មានស្រែ នៅត្រពាំងសែតនោះៗ បាទ!ដល់រដូវស្រែ គឺស្រែនឹងម៉ង ហើយរហូតមកជាមួយម៉ែឪ រហូតមកដល់ឆ្នាំ៧០ ៧១ ឆ្នាំ៧១ៗ អឺ!ក្រោយពីម្តាយខ្ញុំគាត់ ៧០ ចុង៧០នឹងម្តាយខ្ញុំគាត់ឈឺៗទៅធ្លាក់ខ្លួនធ្ងន់ ហើយដល់មើលមិនជា ដល់ពេលម្តាយគាត់ស្លាប់ទៅ ក៏៧១ ខែ៣ បាទ! ខែ៣ខ្ញុំក៏ចេញធ្វើទ័ព ហើយនឹងដល់រហូតតាំងពីនឹងមកៗ ហើយការធ្វើទ័ពនឹង ដំបូងឡើយខ្ញុំនៅអង្គភាពទ័ពស្រុកៗ គិរីវង្សនោះឯងៗ បាទ!ហើយកាលនោះមានតួនាទីជានារសារបស់បញ្ជាការស្រុកៗ ហើយរហូតមកនៅទ័ពស្រុកនឹងរហូតមកដល់៧៣ៗ បានឡើងមកខាងតំបន់ទ័ពស្រុក អឺ!ទ័ពតំបន់ៗតាកែវ បើតាមយើងហៅថាតំបន់១៣នោះៗ ហើយកាលនោះអឺ!តួនាទីជាអនុសេនាតូចៗ ហើយដល់ បាទ! ហើយដល់ អានឹងខ្ញុំនិយាយកាត់សង្ខេបៗទេ ហើយដល់ផុតពីនឹងមក ដល់ ៧៤ ខ្ញុំនែកៗបាន ចុង៧៤ខ្ញុំបានឡើងមកប្រយុទ្ធនៅតាមផ្លូវ ជនផ្លូវលេខ៤នេះ បាទ!ម៉ាជួរយើងអឺ!ដោះកញ្ជរ ម៉ាជួរយើងត្រពាំងក្រឡឹងអីនេះ បាទ!ជនផ្លូវលេខ៤ ហើយឡើងទៅភ្នំពេញៗ ហើយក្នុងនោះខ្ញុំទទួលតួនាទីជាអនុសេនាធំ បាទ!ៗ ហើយរហូតមកដល់៧៥នេះ ខ្ញុំគេត្រូវបញ្ជូនខ្ញុំ ក្រោយរំដោះប្រទេសទាំងបានរួចហើយ គេបញ្ជូនទៅអឺ!នៅកងកេងនោះនៅស្នាច់ដែងថ កង កេងនឹងៗ បាទ!ខ្ញុំក៏ភ្លេចថ្ងៃខែដែលខ្ញុំចេញទៅ ដែលគេត្រូវបញ្ជូនទៅឲ្យហាត់រៀននៅជើងទឹកនឹង វិជ្ជាជើងទឹកនឹង ខ្ញុំភ្លេច ប៉ុនតែក្នុង៧០អឺ!ចុង៧៥ បាទ!ៗ បាទ!ចុង៧៥នឹង ក៏រៀននៅកំពង់សោមបាទ! រៀននៅកំពង់សោម នៅហៅថារៀនជើងខាងជើងទឹក ដូចបាននិយាយពីលើហើយមិញនឹង បាទ!ៗ ហើយជាដំបូងៗ អឺ!គេឲ្យខ្ញុំរៀនខាងអឺ!ម៉ាស៊ីនៗនាវាធន់ការពារនឹង បាទ!ៗ ហើយអស់រយៈពេលជិតមួយឆ្នាំៗដែលខាងខ្ញុំគ្រប់គ្រងខាងម៉ាស៊ីននាវាការពារនឹង ប៉ុន្តែកាលនោះមិនបានចេញទៅល្បាត ឬក៏ទៅប្រយុទ្ធអីដែរៗ ហើយដល់ក្រោយមក បានគេ អស់រយៈពេលជិតម៉ាឆ្នាំនឹង បានគេដកមកខាងនាវាប្រដេញ ដែលគេហៅថានាវាបណ្តែតៗ អឺ!ក្នុងនោះការរៀនរបស់ខ្ញុំ គេឲ្យទទួលខាងអនុប្រធាន បាទ!

ជាអនុប្រធាននាវាប្រដេញនឹង។ ហើយបានម៉ារយៈ ខ្ញុំមិនបានចាំថ្ងៃខែ នឹងពេលវេលាច្បាស់លាស់ទេ ហើយរួចពីនឹងមកបានគេទៅមាននាវាថែម នាវាថែមមកទៀត ក្នុងអឺ!ក្នុងប្រហែលជា១៩៧៨អីនឹង ៧៨នឹងហើយបានគេថែមនាវាមកទៀតហ៎។ ដល់ថែមនាវាមកទៀតមកអានឹងបានកើតជា អាប្រធានខ្ញុំនឹងគេទៅទទួលនាវាថ្មីមួយទៀត បានកើតជាខ្ញុំឡើងជាប្រធានបាទ!។ ព្រោះអឺ!នាវារបស់ខ្ញុំដែលធ្លាប់នៅនឹងមិនបានទៅប្រយុទ្ធអីនឹងគេទេ ព្រោះច្រើននៅប្រចាំការណ៍នៅនឹងដែនឹង ទាំងការពីនៅនាវាការពារ រហូតមកដល់នាវាបណ្តែតនឹងក៏មិនដែលបានចេញទៅប្រយុទ្ធ ឬក៏ទៅល្បាតនាវាណាទេ បាទ!។ នឹងដំណើរសាច់រឿង មានត្រឹមនឹង។

ដានី : បាទៗ អញ្ចឹងខ្ញុំចង់សួរអឺ!ពូបន្តិច បកក្រោយ ពូកាលពូចេញទៅធ្វើកងទ័ព កាលនឹងពូស្ម័គ្រចិត្តទៅឬក៏យ៉ាងម៉េច?

ប៊ិន : កាលដែលជិនាន់ចេញទៅធ្វើកងទ័ព កាលនោះអឺ!ខ្ញុំនិយាយឲ្យត្រង់ៗ ព្រោះក្នុងឋានៈកូនសិស្សក៏ដោយ មិនកូនសិស្សក៏ដោយ ក៏ការនោះជឿៗស្រឡាញ់សម្តេចណាស់ ម៉ែឪ បាទ!។ ពិសេសហើយខ្ញុំទម្លាប់តាំងពីកូនសិស្សនឹងផង ដូចខ្ញុំស្រឡាញ់ណាស់សម្តេចៗឪបាទៗ។ ហើយដល់អាពេលរដ្ឋប្រហារនឹង មិនដឹងថាគេយ៉ាងម៉េច យ៉ាងម៉ាទេ ប៉ុនថាទី១ពូថាទម្លាក់សម្តេចឲ្យ ប៉ុនទី២វាដូចជាគេដេរពេក ដេរតិះដៀលគាត់ពេក វាដូចឈឺចាប់ អញ្ចឹងនៅមិនបានទេ ទី៣ទៀត កាលនោះវាបាក់វាទៅម៉ង បាទ! ទៅឲ្យអារបៀបថាយុវជន កាលនោះខ្ញុំវានៅចេះស្ទើរដែរ បាទ!យុវជនរៀងស្ទើរល្មមៗ គឺចេះតែទៅហើយ។ អញ្ចឹងដល់ឃើញវាទៅហើយ អញ្ចឹងមានចិត្តចង់ទៅនឹងគេ អានឹងម្យ៉ាង។ ម្យ៉ាងទៀត យើងមិនដែលបានកាំភ្លើងកាន់ផងកាលនោះ ឃើញគេកាន់កាំភ្លើងរៀងដូចជាចង់ដែរ បាទ!។ អានេះនិយាយទៅម្យ៉ាងវាដូចថាដោរជន់ទៅតាមៗគ្នា បាទ!។

ដានី : កាលពូនៅ ចូលដិបូងអឺ!នៅចូលដិបូងទៅនៅនារសាបញ្ជាការស្រុក អឺ!គិរីវង្ស?

ប៊ិន : បាទ!

ដានី : កាលនឹងអឺ! បញ្ជាការស្រុកគិរីវង្ស គាត់ឈ្មោះអីទៅ?

ប៊ិន : ឈ្មោះសោម ណែម។

ដានី : ឈ្មោះ សោម ណែម?

ប៊ិន : បាទ!

ដានី : សោម ណែម គាត់បញ្ជាការស្រុក?

ប៊ិន : បាទ!បញ្ជាការស្រុក។

ដានី ៖ ពូនៅពី៧១ រហូតដល់ឆ្នាំ៧៣?

ប៊ិន ៖ បាទ!រហូតដល់៧៣ ។

ដានី ៖ ៧៣ យ៉ាងម៉េច បានពូអឺ!ផ្លាស់ទៅតំបន់?

ប៊ិន ៖ កាលដែលផ្លាស់ មិនមែនចិត្តយើងទេ ព្រោះតាមគម្រោងការណ៍របស់គេៗខាងលើៗនឹងដែរ ។

ដានី ៖ របស់គេ ផ្លាស់ទៅទាំងអស់ហើយក៏យ៉ាងម៉េច?

ប៊ិន ៖ បាទ!អឺ!ទៅៗជាអង្គភាព ប៉ុនដល់ជំនាន់នោះគេជ្រើសរើសសមត្ថភាព ឬក៏និន្នាការអញ្ចឹងណា៎ ប៉ុនត្រង់ខ្ញុំស្អាតមិនស្អាត អ្នកផ្សេងស្អាត ឬអាក្រក់អ្នកណាខ្ញុំអត់ដឹងទេ ។ ប៉ុនដល់ចំរាញ់ជ្រើសរើស វាត្រូវម៉ាអង្គភាព កាលនឹងគេយកទៅម៉ាអនុសេនាតូចនេះ ។ ហើយទៅគេហាត់លុតដុំអីនឹងហើយទៅ បានគេជ្រើសរើស យើងជ្រើសរើសទៅបាននៅតែខ្ញុំដូចជាគ្នាប៉ុន្មាននាក់ ៥នាក់ ៦នាក់ មិនដឹង ។ ហើយ៥ ៦នាក់នឹងអឺ! ក្រោយពីគេរៀបចំអង្គភាពអឺ!តំបន់នឹងមក ខាងខ្ញុំចូលគ្រប់គ្រង ។

ដានី ៖ អនុសេនាតូច?

ប៊ិន ៖ បាទ!អនុសេនាតូច អញ្ចឹង ។

ដានី ៖ កាលនោះពូអនុសេនាតូច អឺ!ក្នុងអនុសេនាធំទីប៉ុន្មាន?

ប៊ិន ៖ បាទ!អនុសេនាធំលេខ២២ ។

ដានី ៖ អនុសេនាធំលេខ២២?

ប៊ិន ៖ បាទៗ វរសេនាតូចកាលនោះតំបន់គេហៅ«គ» គ១ គ២ គ៣ គ៤អញ្ចឹងណា ប៉ុនខ្ញុំនៅក្នុងអង្គភាពវរសេនាតូច«គ៤» ។

ដានី ៖ «គ៤»?

ប៊ិន ៖ បាទ!

ដានី ៖ កាលនឹងមាន អឺ!ត្រឹមវរសេនាតូច មានវរសេនាធំដែរអត់?

ប៊ិន ៖ កាលនឹងមិនទេ មិនមានវរសេនាធំទេ ព្រោះខាងតំបន់គេគ្រប់គ្រងផ្ទាល់ តំបន់តំណាងឲ្យវរៈសេនាធំ ឬកងពល ។

ដានី ៖ បាទៗ អឺ!កាលនឹងអឺ!វរសេនាតូច អឺ!វរសេនាធំឈ្មោះអីទៅ?

ប៊ិន ៖ វរសេនាធំអត់ៗមានទេ អត់មានវរសេនាធំទេ មានតែវរសេនាតូចហ៎ ។

ដានី ៖ អូ!មានអនុសេនាធំឈ្មោះអី?

ប៊ិន ៖ អនុសេនាធំឈ្មោះអឺ! អីភ្លេចហើយអានុសេនាធំនឹង ស្អីទេរ៉េតហើយ ឈ្មោះរ៉េត ។

ដានី ៖ ឈ្មោះរ៉េតហ៎?

ប៊ិន ៖ បាទ! រ៉េត ស្អីរ៉េតហើយទេ ខ្ញុំភ្លេចហើយ ខ្ញុំនឹកអត់ឃើញ ។

ដានី ៖ មិនមែនពូរ៉េត?

ប៊ិន ៖ មិនមែនទេ មិនមែនរ៉េតនេះទេ បាទ!រ៉េតមួយទៀត ។ រ៉ែតនោះគេ រ៉ែតគេសិស្ស ។

ដានី ៖ អឿន រ៉េត?

ប៊ិន ៖ បាទ! រ៉ែតផ្សេង រ៉េតនោះសិស្សរៀនថ្នាក់ខ្ពស់ជាងរ៉េតនេះ ។

ដានី ៖ បាទៗ ចុះអឺ!វរសេនាតូច?

ប៊ិន ៖ វរសេនាតូចឈ្មោះអឺ! ហ៊ិន ប្រធានវរសេនាតូចឈ្មោះហ៊ិន ។

ដានី ៖ ហ៊ិនហ៎?

ប៊ិន ៖ បាទ!

ដានី ៖ ពូហ៊ិន មួយដែលទៅជាប្រធាន?

ប៊ិន ៖ តែគាត់ស្លាប់ហើយ ហ៊ិននេះស្លាប់ហើយ បាទ!ស្លាប់ភូមិដាន កាលយើងអឺ!៧៩រត់ ។

ដានី ៖ នៅខាងភូមិដាន ខាងកោះកុងនឹង?

ប៊ិន ៖ បាទៗ ។

ដានី ៖ អឺ!ហ៊ិននឹង?

ប៊ិន ៖ ហ៊ិននឹង បាទៗ ។

ដានី ៖ ហ៊ិនវរសេនាតូច?

ប៊ិន ៖ បាទ!

ដានី ៖ ចុះកាលនឹងអឺ!វរសេនាតូចអីនឹង នៅក្នុងអឺ!គ្រប់គ្រងរបស់តំបន់?

ប៊ិន ៖ បាទ!របស់តំបន់ ។

ដានី ៖ តំបន់១៣? គាត់ពីណាគេអ្នកគ្រប់គ្រងអានឹង?

ប៊ិន ៖ ខាងតំបន់នឹង?

ដានី ៖ បាទ!

ប៊ិន ៖ ខាងនឹងឈ្មោះអឺ!លោក ញ៉ែវ ។

ដានី ៖ ឈ្មោះញ៉ែវ?

ប៊ិន ៖ បាទ! ប៉ុន្តែញ៉ែវនឹងក៏ស្លាប់ដែលហើយ ។

ដានី ៖ ញ៉ែវ ចុះពីណាគេ មានតែញ៉ែវម្នាក់ទេ?

ប៊ិន ៖ ដល់រួចពីនឹងមកខ្ញុំផុតៗមកហើយក្រោយពី ដូចកាលនឹងតាញ៉ែវនៅនឹងទេ ហើយអឺ!ជាវង ជាអីគាត់មិនដឹងពីណាខ្លះទៀត ដូចខ្ញុំអត់សូវដឹងរឿងអីដែរ ។ បាទ!ដឹង ប៉ុនគ្រាន់ដឹងថាគណៈតំបន់កាលនឹងអឺ!តាសោម ។

ដានី ៖ តាសោមគណៈតំបន់?

ប៊ិន ៖ តាសោម បាទ!គណៈតំបន់ ។

ដានី ៖ តាញ៉ែវ ខាងយោធា?

ប៊ិន ៖ បាទ!ខាងយោធា បាទ! ។ ហើយដល់ក្រោយមក គេមិនបញ្ជូនខ្ញុំឲ្យឡើងមកខាងភូមិភាគនេះជួរជួរលេខ៤បាទ! ។

ដានី ៖ ដល់ពេលឆ្នាំណាដែលពូឡើងមកភាគ?

ប៊ិន ៖ អានឹង៧៤ ។

ដានី ៖ ចុងឆ្នាំហើយ?

ប៊ិន ៖ បាទ!មិនៗ នឹងហើយចុងដែលហើយ បាទ! ។

ដានី ៖ អានឹងពូឡើងមកភាគៗនារតី?

ប៊ិន ៖ បាទ!ភាគនារតី ។

ដានី ៖ នារតីទិស កាលនឹងពូអឺ!ឡើងពីអនុសេនាតូចឡើងមកប្រធាន?

ប៊ិន ៖ អនុសេនាធំបាទ! ។

ដានី ៖ ទទួលអនុសេនាធំ?

ប៊ិន ៖ បាទ!

ដានី ៖ សេនាធំលេខប៉ុន្មានកាលនឹង?

ប៊ិន ៖ បាទ!អនុសេនាធំនឹងគេអត់ប្រែទេ នៅ២២ដដែលតាំងពីតំបន់មកអញ្ចឹង ។

ដានី ៖ ចុះរ៉េត គាត់ទៅណាវិញ?

ប៊ិន ៖ រ៉េតនឹង ដល់ បាទ!រ៉េតនឹងនៅជាមួយគ្នា រ៉េតដែលប្រធានអនុសេនាធំនឹង ។ បាទ! ប៉ុន្តែខ្ញុំមិនមែនប្រធានទេ ខ្ញុំអនុប្រធានគេកាលនឹងណា បាទ!រ៉េតនឹងជាប្រធាន ដល់អញ្ចឹងយើងឡើងមកវាឡើងតាមលំដាប់អញ្ចឹងណា ។

ដានី ៖ បាទៗ អនុសេនាធំ អឺ!វរសេនាតូចអីនៅឈ្មោះហ៊ានដដែល?

ប៊ិន ៖ បាទ!

ដានី ៖ អូ!អញ្ចឹងគេកាត់ពីតំបន់មកចូលក្នុងភូមិភាគ គេកាត់ទាំងអស់មកម៉ង?

ប៊ិន ៖ ភូមិភាគ បាទ!ម៉ាអគ្គភាពនឹងម៉ង ។

ដានី ៖ ម៉ាអគ្គភាពវរសេនាតូច មកទាំងអស់?

ប៊ិន ៖ បាទ! ហើយៗដល់អឺ!កាលនឹងមក មិនមកកាលនឹងជាកងឯករាជ្យទេណា ជាវរសេនាតូចឯករាជ្យ នៅវាយផ្លូវនឹង ហើយដល់ក្រោយមក បានប្រហែលជា២ខែអី ៣ខែអីមិនដឹងទេ បានគេបញ្ចូល គេបញ្ចូលជាឲ្យមានអគ្គភាពវរសេនាធំ ព្រោះរបស់ភូមិភាគ ។ បាទ!អឺ!វរសេនាធំនឹង គឺគេឲ្យឈ្មោះថាវរសេនាធំអឺ!វរសេនាធំយ៉ាន ស្អីហើយលេខប៉ុន្មានទេ៥ អឺ!វរសេនាធំលេខ២២អញ្ចឹង វរសេនាធំយ៉ាន ២២ បាទ!វរសេនាធំ២២ ។

ដានី ៖ ២២ ប្រធានឈ្មោះយ៉ានហេ៎?

ប៊ិន ៖ យ៉ាន បាទ!

ដានី ៖ អូ!ប្រធានវរសេនាធំ ឈ្មោះយ៉ាន?

ប៊ិន ៖ បាទ!

ដានី ៖ គង់ មកនៅមានកងពលហើយនៅ?

ប៊ិន ៖ មានមិនទាន់ទេ ព្រោះវាទើបនឹងរិតវរសេនាធំទេ បាទ!ជិតទាន់យើងជិតវាយយួននោះណា ៧៤ ផ្លូវនឹង អត់ អូ!មានហើយៗ កងពលលេខ៣ៗ បាទ! ។

ដានី ៖ កងពលលេខ៣?

ប៊ិន ៖ បាទ!

ដានី ៖ កងពលលេខ៣ ។ អឺ!ខាងកងពល ពីណាគេទទួលខុសត្រូវ?

ប៊ិន ៖ បាទ!អឺ!តាមុត ។

ដានី ៖ តាមុតៗម្នាក់ហេ៎?

ប៊ិន ៖ បាទ!តាមុត ហើយអឺ!ណាទៀត កាលនឹងកងពល អឺ!មួយតារិនមួយទៀត ។

ដានី ៖ តារិន?

ប៊ិន ៖ តារិនវៀចមាត់នោះ បាទៗ ។ បាទ!អានឹងកំពុងប្រយុទ្ធនឹង ។

ដានី ៖ បាទ!ប្រយុទ្ធ ផ្លូវជាតិលេខ៤ ច្រក ផ្លូវជាតិលេខ៤ចុះទៅខាងណា ខាងពោធិ៍ចិនតុង?

ប៊ិន ៖ យើងៗ មិនទាន់បាន ទៅចាប់ពីអឺ! យើងត្រូវទៅកើតបាទ! ប៉ុនភាគច្រើនយើងនៅវិលវក់ មិនដឹងថាយើងអី ។

ដានី ៖ បាទ!អត់ដែល អត់បានវាយចូលទៅខាងពោធិ៍ចិនតុង ខាងភ្នំពេញ?

ប៊ិន ៖ បាទ!អានឹងដល់អាថ្ងៃៗជិតបញ្ចប់ចុងក្រោយ បាទ! ។

ដានី ៖ ចូលទៅដល់ត្រឹមណា?

ប៊ិន ៖ ខ្ញុំចូលទៅដល់ៗ ខ្ញុំចូលដល់ត្រឹមអឺ!ស្អី យើងខាងលិចផ្លូវបែកចោមចៅ ។

ដានី ៖ កំបូល?

ប៊ិន ៖ កំបូល នឹងហើយចូលដល់ត្រឹមកំបូល បែកត្រឹមនឹង ។

ដានី ៖ បាទៗ ដល់ពេលគេបែកហើយ ពូបានស្នាក់នៅរហូតដល់គេជម្លៀសប្រជាជនចេញ ឬក៏យ៉ាងម៉េចដែរ?

ប៊ិន ៖ កាលដែលគេបែកហើយ គេជម្លៀសចេញបណ្តើរហើយ ប៉ុន្តែកាលនោះគេទៅដល់បែកនោះហើយដោះកញ្ជួរយើងនៅអត់ទាន់បែកទេ ។

ដានី ៖ ដោះកញ្ជួរនៅកន្លែង?

ប៊ិន ៖ បាទៗដោះកញ្ជួរករណីយើងនេះ បាទ!អត់ទាន់បែកទេណា អញ្ចឹងគេត្រូវបញ្ជូនបកពីនោះមកវិញ បញ្ជូនដល់វាយរួមគ្នាវាយនេះ ។ ប៉ុនខ្ញុំមកអត់បានវាយអត់ប្រយុទ្ធអីផង ក៏នេះគេបែកហើយនឹង ។

ដានី ៖ បាទៗ ដល់ពេលហើយយើងបកទៅវិញ ហើយក៏?

ប៊ិន ៖ អត់បកទៅវិញទេ គេបញ្ជូនទៅៗអឺ!ទៅស្ទាច់ ទៅកង កេងនឹងម៉ង ។

ដានី ៖ បញ្ជូនទៅទាំងកងពលទី៣ទៅទាំងអស់?

ប៊ិន ៖ បាទ!ទៅទាំងអស់ម៉ង ។

ដានី ៖ កាលនឹងពូនៅក្នុងវរអឺ!២២របស់តាយ៉ានទៀត?

ប៊ិន ៖ បាទៗ ហ្នឹងឯង ។

ដានី ៖ បញ្ជូនទៅៗស្ទាច់ដែងៗខាងកងកេង ខាងព្រលានយន្តហោះនឹង?

ប៊ិន ៖ បាទៗ នឹងហើយ ។

ដានី ៖ ការបញ្ជូនទៅនឹង អឺ!ដូចថាគេឲ្យដឹបូងនៅកន្លែងកងកេង នៅស្ទាច់ដែងនឹងនៅធ្វើអីទៅ?

ប៊ិន ៖ បាទ!អានឹងយើងនៅគ្រប់គ្រងកងទ័ពនឹង ហើយនឹងដូចថាប្រជាពលរដ្ឋជម្លៀសចេញមកផ្លាស់មកនៅនឹង បានន័យថាក្រោយពីខ្ញុំទៅដល់នឹង គេជម្លៀសប្រជាពលរដ្ឋចេញមកចង់អស់ហើយ ពីកំពង់សោមពីអី អឺ!កន្លែងទីប្រជុំជនអីនឹង បាទ!ចង់អស់ហើយ ។ ហើយដល់ខ្ញុំនៅនឹងទៅវាយើងរំដោះវាខែៗប៉ុន្មាន ដូចជាខែមេសា មែនទេ ១៧មេសាបាទ! ។ វាដូចថាដូចចង់ធ្លាក់ទឹកភ្លៀងដែលហើយណា ។ បាទ!អញ្ចឹងវាឲ្យខ្ញុំនឹងនៅគ្រប់គ្រងមនុស្សដែលនៅទីនឹង ប្រជា

ពលរដ្ឋនៅទីនឹង គឺមិនមែនគ្រប់គ្រងទៅក្នុងឋានៈជាភូមិ ជាឃុំជាភូមិអីទេ មិនមែនទេ។ គ្រប់គ្រងក្នុងឋានៈជាកងទ័ពរួមគ្នាធ្វើស្រែ ធ្វើចំការ បាទ!អញ្ចឹង។

ដានី : កាលនឹងពួកពូទៅធ្វើស្រែធ្វើចំការដែរ?

ប៊ិន : បានចូលរួមនឹងគេដែរ។

ដានី : នៅស្នាច់ដែង នៅតាមស្រុកអីនឹង?

ប៊ិន : បាទៗ។

ដានី : កាលនឹងពួក អឺ!ទាំងវរសេនាធំ២២នឹង នៅស្នាច់ដែងបាន?

ប៊ិន : បាទ!នៅម្យ៉ាង វានៅមិនមែនតែស្នាច់ដែងម៉ុំទេ នៅនឹងដូចថាម៉ាអនុសេនាធំអញ្ចឹងទៅ មកនៅអាភ្នំដើងអនុសេនាធំអញ្ចឹងមក ហើយនៅខាងលិចម៉ាអនុសេនាធំ ហើយអឺ!វរសេនាតូចផ្សេងៗទៀត គេចេះតែបែកៗគ្នាទៅនៅកន្លែងផ្សេងអញ្ចឹងណា។

ដានី : អឺ!អញ្ចឹងកាលនឹងយើងធ្វើតែស្រែសុទ្ធរហូតម៉ង?

ប៊ិន : បាទៗ។

ដានី : រហូតដល់ចុងឆ្នាំ៧៥ បានគេបញ្ជូនពូទៅរៀន ដើងទឹក?

ប៊ិន : បាទៗ។

ដានី : ពូចាំខែ ចាំអឺ!ថ្ងៃដែលអត់?

ប៊ិន : ភ្លេច មិនចាំទេបាទ!។

ដានី : នៅចុងៗឆ្នាំ?

ប៊ិន : បាទ!

ដានី : ការបញ្ជូនទៅៗរៀនខាង ទៅរៀនខាងដើងទឹកនៅកំពង់សោមនឹង គេបញ្ជូនទៅទាំងអស់គ្នា គឺគេជ្រើសរើស?

ប៊ិន : គេជ្រើសរើស បាទ!គេជ្រើសរើសទេ ហើយក្នុងអង្គភាពខ្ញុំ ម៉ាអនុសេនាធំខ្ញុំនឹង ឃើញគេៗយកៗតែខ្ញុំមួយទៅ។

ដានី : ម៉ាអនុសេនាធំពូ?

ប៊ិន : បាទ! គេយកតែខ្ញុំមួយទៅ ហើយនឹងជ្រើសរើសពីអង្គភាពវរសេនាធំ វរសេនាតូចអីផ្សេងៗមកទៀតមក។ បាទ!ព្រោះកាលនោះវាទៅខាងដើងទឹក មិនមែនទៅទាំងខុលទេ សំខាន់ឲ្យកំណត់នោះគេនិយាយថា គេដោះប្រវត្តិរូបល្អបានទៅដល់អញ្ចឹង។ ហើយអញ្ចឹងដូចខ្ញុំនិយាយ

មកដល់នេះ ថាខ្ញុំមិនដឹងជាល្អអាក្រក់អីទេ ព្រោះខ្ញុំមិនដែលស្គាល់ផ្ទះផង តាំងពីចេញពីផ្ទះមក អញ្ចឹងដឹងណាមាននាការណ៍អីម៉េចៗទេអានឹង គេរុញទៅណាចេះទៅនឹងហើយ បាទ!ៗ

ដានី ៖ ដល់កាល អញ្ចឹងទៅរៀនជើងទឹកដំបូង គេជ្រើសរើសទៅពីកន្លែងវរសេនាធំពូក្នាប៉ុន្មាននាក់ទៅ?

ប៊ិន ៖ កាលនឹងខ្ញុំ ដូចជាទៅប្រហែលជាជិតម៉ាក្រុម តែខ្ញុំមិនរាំក្មេចកាំងៗដែរណា ប្រហែលជាជិតម៉ាក្រុមណាមើល ប៉ុនដល់ហើយទៅដល់នោះអាចគេសំរិតសំរាំងចេញវិញខ្លះទៀត ៗ

ដានី ៖ ចេញខ្លះទៀត?

ប៊ិន ៖ បាទ!

ដានី ៖ ចុះទៅ ដល់ពេលទៅរៀនអឺ!ទៅនៅកំពង់សោម រៀននៅមុំណា?

ប៊ិន ៖ រៀនបច្ចេកទេសនឹង?

ដានី ៖ បាទ!

ប៊ិន ៖ បាទ!រៀននៅអូរឈើទាលនឹងម៉ង ៗ

ដានី ៖ រៀននៅអូរឈើទាលហេ៎?

ប៊ិន ៖ ព្រោះកាលនោះអឺ!អូរឈើទាលនឹងមិនមែនដូចឥឡូវទេ កាលនោះផ្ទះ អឺ!ផ្ទះថ្មប៉ុនវាអត់វាមាន ២ ៣ជាន់អីទេណា ៗ ជាន់ៗនោះច្រើនតើ ផ្ទះច្រើនរហូតទៅទល់ដល់ដំណាក់ស្តេច ៗ បាទ! ហើយអញ្ចឹងកន្លែងពួកខ្ញុំគឺ នៅនឹងនៅម៉ុំដំណាក់ស្តេចនឹងមក បាទ!ហើយទាំងអស់ដែអូរឈើទាល ឥឡូវវារូសរើសអស់ហើយ កាលនោះវាមានដៃៗឈើធ្វើដោយដៃខ្លួនឯងសសរប៉ុនៗនឹង បាទ!ៗ

ដានី ៖ ហើយរៀននៅកន្លែងអូរឈើទាល?

ប៊ិន ៖ បាទៗ ៗ

ដានី ៖ កាលដំបូង ដល់ពេលពូទៅដល់កំពង់សោម ទៅដល់រាមដំបូងគ្នាច្រើនដែរអត់ ពេលរៀននឹង?

ប៊ិន ៖ កាលពីរៀននឹងច្រើនដែលនឹង មនុស្សប្រហែលជា ខ្ញុំប៉ាន់មើលប្រហែល អឺ!កាលនឹងគេរៀបជាវរសេនាធំដែរ វរសេនាធំអឺ!ជើងទឹកនឹង គេរៀបចំម៉ាវរសេនាធំដែលកាលនឹង ៗ

ដានី ៖ អូ!គេរៀបចំដែរ?

ប៊ិន ៖ បាទ!

ដានី ៖ វរសេនាធំជើងទឹក លេខ មានលេខ?

ប៊ិន ៖ បាទៗមាន១៤០ ៗ

ដានី ៖ លេខ១៨០ហេ៎?

ប៊ិន ៖ បាទ!

ដានី ៖ វរសេនាធំដើងទឹក១៨០?

ប៊ិន ៖ បាទ! ហើយអឺ!ប្រធានគឺជាបងសារឿន អឺ!មិនដឹងត្រកូលគាត់ស្អីទេ ប៉ុនឈ្មោះបងសារឿន ប៉ុនគាត់ទៅស្លាប់បាត់ដែរ ។

ដានី ៖ ប្រធានឈ្មោះសារឿន ចុះអនុ បន្ទាប់ៗ?

ប៊ិន ៖ អឺ!អនុគាត់ កាលនឹងដូចជាមិនៗឃើញមានដែរ ឃើញតែគាត់តែឯង ម្នាក់ឯង ។

ដានី ៖ បាទ!សារឿន ប្រធាន ពេលដែលគេជ្រើសរើសឲ្យទៅរៀននឹង គេចាប់ផ្ដើមបង្កើតវរសេនាធំហើយនោះ?

ប៊ិន ៖ បាទ! ដល់មកពីអង្គភាពនោះបន្តិច អង្គភាពនេះតិចៗ ចង់និយាយថាវរសេនាធំនោះខ្លះៗតាមការជ្រើសរើសរបស់គេ មកប្រមូលផ្ដុំគ្នា ហើយបង្កើតជាវរសេនាធំមួយ ។

ដានី ៖ បាទ!១៨០?

ប៊ិន ៖ បាទ!១៨០ ។

ដានី ៖ ចុះអឺ!ក្នុងវរសេនាធំ១៨០នឹង អឺ!កាលនឹងមានប៉ុន្មានវរសេនាតូច?

ប៊ិន ៖ វាមាន៣វរសេនាតូចដែរ បាទ!ប៉ុនវរសេនា ៣វរសេនាតូចនឹងវា យកឈ្មោះតែវរសេនាតូចប៉ុន្តែរបៀបដើងទឹក វាមិនរៀបពេញដូចដើងគោកទេ ។ បាទ! ដូចថាឥឡូវឧទាហរណ៍ថា ម៉ានាវាប្រដេញអញ្ចឹង នាវាប្រដេញអញ្ចឹង ការពិតមានគ្នាតែ១២នាក់ ១៣នាក់ទាំងពេទ្យមួយផង ។ ដូច្នេះ វាសិទ្ធិរបស់វាៗស្មើនឹងប្រធានវរសេនាតូចដើងគោក បាទ!សិទ្ធិរបស់វា ។ អញ្ចឹងគេមិនៗរៀបដូចដើងគោក ស្មើដើងគោកទេ បាទ!អញ្ចឹងកាលនឹងក៏មាន៣វរសេនាតូចដែរ ។ បាទ! ហើយខាងខ្ញុំនៅដំបូងឡើយ នៅវរសេនាតូចរបស់អឺ!បងហ៊ានដែរ បាទ! ។

ដានី ៖ វរសេនាតូចលេខប៉ុន្មានឈ្មោះហ៊ាន?

ប៊ិន ៖ អឺ! ទេកាលនឹង វរសេនាតូចលេខប៉ុន្មាន ខ្ញុំភ្លេចដែរកាលនឹង បើខ្ញុំភ្លេចៗ ។

ដានី ៖ ឈ្មោះហ៊ាន?

ប៊ិន ៖ បាទ!

ដានី ៖ ចុះប្រធានវរសេនាតូចផ្សេងៗទៀត ពូចាំទេ ក្នុងកង អឺ!ក្នុង១៨០ កង១៨០?

ប៊ិន ៖ អឺ!នឹងវរសេនាតូចមួយទៀត ឈ្មោះមឿនៗវរសេនាតូចមួយដែរ ហើយវរសេនាតូចមួយទៀតអឺ! ឈ្មោះស្អីម៉េចដឹងទេអានឹង ខាងមកពីបូព៌ាវិញ ។

ដានី ៖ ខាងបូព៌ា?

ប៊ិន ៖ បាទ!មកពីខាងបូព៌ា ឈ្មោះស៊ីម៉េចទេ ។

ដានី ៖ សាង?

ប៊ិន ៖ អឺ!សាងៗ ឌីនៗ កាលនឹងបើមិនសាង ឌីន បាទ! ។

ដានី ៖ សាង ឌីន បាទ! មានតែ៣វរសេនាតូចនឹងទេ?

ប៊ិន ៖ បាទ!

ដានី ៖ ចុះក្នុងអឺ!៣វរសេនាតូចនឹង ដូចថាអឺ!កាន់កប៉ាល់ដូចថាកប៉ាល់ខាងកប៉ាល់ស៊ីខ្លះទៅ ប្រភេទកប៉ាល់?

ប៊ិន ៖ បាទ!ប្រភេទកប៉ាល់ ដំបូងឡើយអត់ទាន់មានអាធន់ប្រដេញ ដូចខ្ញុំនិយាយ៣អាៗគ្រាប់បែកបុកទេ ។ យើងមានតែធន់ការពារ បាទ!ធន់ការពារ ដូច្នេះកាលនោះគេប្រធានវរសេនាតូច ឬអនុប្រធាន ឬសមាជិករបស់គេនឹង នឹងសុទ្ធតែគេនឹងប្រធានហើយ កាលនឹងវាមានតិច ។ បាទ!ហើយដែលដូចជាពួកយើងខ្ញុំក្រោមៗអីនេះ វាតាមមុខជំនាញ អ្នកខ្លះក៏កាំភ្លើង៣៧ អ្នកខ្លះក៏២៥ អ្នកខ្លះក៏រ៉ាដា អ្នកខ្លះក៏អឺ!ខាងត្រីវិស័យ អីអញ្ចឹងទៅ ព្រោះមុខជំនាញរបស់វាមានបែកខុសៗគ្នា ។ បាទ! ហើយដល់ក្រោយមកបាន អានឹងយើងនិយាយវគ្គទី១នឹងមក ចប់រៀនវគ្គទី១មកបានក្រោយមកវាមានគេពង្រីកទៀត ពង្រីកដាក់ឲ្យសិស្សស្រគួរហើយសម្រាប់នាវាមកគេថែម ។បាទ!អានឹងបានៗកើតចេញជាប្រធានវរសេនាតូចខ្លះ ក៏ចេញទៅជាប្រធាននោះខ្លះ ខ្លះអនុសេនាធំ ខ្លះក៏ចេញជាប្រធានកប៉ាល់នោះៗ ខាងក្រោយដែលវាមកអឺ!កប៉ាល់នោះថែមមក ។

ដានី ៖ កាលនឹង អញ្ចឹងដំបូងពូនៅក្នុងវរសេនាតូចរបស់ឈ្មោះ?

ប៊ិន ៖ អូៗ ខ្ញុំស្គាល់ហើយ វរសេនាតូចនឹង៤៤ ។

ដានី ៖ ៤៤ហេ៎?

ប៊ិន ៖ បាទ!៤៤ ត្រូវ ហើយមួយទៀត៤២ ៤៣អញ្ចឹងមក អូ!៤វរសេនាតូច តាវ៉ែនមួយទៀត ៤១ តាវ៉ែន បាទ!វាៗភ្លេច ដល់វាមិនបានចាប់អារម្មណ៍យូរវាភ្លេចណា ។

ដានី ៖ ឈ្មោះវ៉ែម ដែ?

ប៊ិន ៖ បាទ!៤១ ប៉ុនគាត់ស្លាប់បាត់ហើយ ។

ដានី ៖ វ៉ែម ៤១?

ប៊ិន ៖ បាទ!

ដានី ៖ ចុះមឿន ៤០ប៉ុន្មាន?

ប៊ិន ៖ មឿននឹង៤២ ។

ដានី ៖ ៤២?

ប៊ិន ៖ បាទ!

ដានី ៖ ខាងបូព៌ា ឈ្មោះឌឺន ឈ្មោះ សាននឹង៤៣ហ៎?

ប៊ិន ៖ បាទ!៤៣ ហើយខាងខ្ញុំ៤៤ បាទៗ នឹងហើយ៤វរសេនាធំ ។

ដានី ៖ កាលនោះពូ ដល់ពេលគេចែងអញ្ចឹង កាលនឹងអឺ!ក្នុងវរសេនាតូចនឹង មានអនុសេនាធំអីនឹងពូកាលនឹង?

ប៊ិន ៖ កាលនឹងដូចជាមិនៗគិតថាអនុសេនាធំ ឬអនុសេនាតូចអីទេ របៀបរៀបចែកជាក្រុមៗវិញម្តង បាទ!ទោះជាអ្នកវរសេនាតូចក៏ដោយ អ្នកអីក៏ដោយ វាសំខាន់គឺចង់និយាយថាសំដៅ និយាយខ្ញុំនិយាយឲ្យត្រង់ចុះ ព្រោះសំខាន់គឺយើងនិយាយទាំងសំដៅបក្សជនចាស់ និងថ្មីៗ បាទ!អ្នកពេញសិទ្ធិចាស់ និងពេញសិទ្ធិថ្មី ដូច្នេះទោះជាអ្នកវរសេនាតូចក៏ដោយ ឬក៏អនុសេនាធំក៏ដោយ គេជាប្រធានក្រុមក៏ដោយអីក៏ដោយ តែគេជាបក្សជនចាស់ ដល់ពេលៗរៀបចំរុះគ្នាអញ្ចឹង វាត្រូវអ្នកនឹងដឹកនាំវិញ ។ បាទ!ប៉ុន្តែមិនៗប្រកាសជាអ្នកឯងជាអីៗទេ ប៉ុនថាឲ្យក្រុមខាងនេះ ក្រុមឈ្មោះ«ក» ក្រុមឈ្មោះ«ខ»អញ្ចឹង បាទ!ព្រោះដូចខ្ញុំនិយាយអញ្ចឹង យើងអគ្គភាព យើងរបៀបជារៀបជាទ្រង់ទ្រាយសមាជិកកប៉ាល់ហើយម៉ង ។

ដានី ៖ បាទៗ ចុះពូអឺ!វរ បក្សជនចាស់ បក្សជនថ្មី បានន័យថាអ្នកដែលចូលមុន ចូលក្រោយ ឬយ៉ាងម៉េច?

ប៊ិន ៖ បាទ!មុនក្រោយ បាទ! ។

ដានី ៖ ឧបមាថាមួយដូចថាយើងជាបក្សជន ដែលយើងចូលពេលសម័យវាយកាលពីសង្រ្គាម ពីចន្លោះ៧០ ៧៥ ហើយអ្នកបក្សជនថ្មី បានន័យថាអ្នកចូលក្រោយ?

ប៊ិន ៖ ចូលក្រោយបាទ! ។

ដានី ៖ ដល់ឆ្នាំ៧៥?

ប៊ិន ៖ បាទៗ ។

ដានី ៖ អញ្ចឹងហី គេគិតអញ្ចឹង?

ប៊ិន ៖ បាទៗ គេគិតអញ្ចឹង ។

ដានី ៖ កាលនឹងអី! ពេលពូចូលទៅរៀនខាងកប៉ាល់ពីចុងឆ្នាំ៧៩ ចូលរៀនបច្ចេកទេសខាងកប៉ាល់នឹង កាលនឹងរៀនបានរយៈពេលប៉ុន្មានទៅ?

ប៊ិន ៖ ខ្ញុំអី!៧ខែៗខាងបច្ចេកទេសម៉ាស៊ីន បាទ!បច្ចេកទេស មិនមែនជាបច្ចេកទេសជួសជុលទេ គឺខាងប្រើ ។

ដានី ៖ ប្រើមនុស្ស?

ប៊ិន ៖ បាទ!ឲ្យយល់ពីរបៀបរបបប្រើម៉ាស៊ីន ។

ដានី ៖ ចុះអ្នកផ្សេងទៀត គេរៀនរយៈពេលប៉ុន្មាន?

ប៊ិន ៖ អ្នកផ្សេងៗក៏រៀនប៉ុននឹងដូចគ្នា ម៉ាវគ្គដំបូង ។

ដានី ៖ រៀនប៉ុននឹងដូចគ្នា?

ប៊ិន ៖ បាទ!

ដានី ៖ អូ!រៀនខាងណាគេមកបង្រៀន?

ប៊ិន ៖ ចិន បាទ! ចិនដីគោកណ៎ ។

ដានី ៖ គ្រូចិន មកពីស្រុកចិនមក?

ប៊ិន ៖ បាទ!មកពីស្រុកចិន ។

ដានី ៖ គេបង្រៀនជាភាសាអី?

ប៊ិន ៖ គេ រៀនជាភាសាចិន ប៉ុន្តែយើងក៏មានអ្នកបក ។

**កាសែតទី១ ផ្នែក«ខ»**

ដានី ៖ អ្នកបកប្រែនឹងគាត់ជាជនជាតិខ្មែរយើង ឬក៏ជនជាតិចិន?

ប៊ិន ៖ ខ្មែរយើងនឹង ប៉ុនណាដូចថាអាចិនៗនៅស្រុកខ្មែរយើងពីដើមមកនឹងណ៎ បាទ!ពួកនឹងគេ ។

ដានី ៖ ពូមានចាំឈ្មោះ មានស្គាល់អ្នកណាខ្លះដែរអត់ ដែលធ្លាប់ជាអ្នកបកប្រែពេលរៀនបច្ចេកទេស នឹង?

ប៊ិន ៖ ទេ! ខ្ញុំដូចជាភ្លេចហើយ ស្គាល់តើ ពួកនឹងសុទ្ធតែស្គាល់តើថាគ្នាភ្លេចទៅណា ។

ដានី ៖ ឈ្មោះអីទៅ ពូចាំទេ?

ប៊ិន ៖ អឺ!នារីអេងនេះមួយ ។

ដានី ៖ នារីអេងហ៎?

ប៊ិន ៖ បាទ!ហើយអឺ!លោកសានឌីង២ ហើយអឺ!មួយ ពីរទៀត ខ្ញុំមិនសូវស្គាល់ទេ អានឹងវាមកបក ក្រោយៗ ថ្មីៗហើយ ។

ដានី ៖ បាទ១ ចុះនារីអេង ហើយឈ្មោះសាងមិត្តសាងនឹងអឺ!គាត់អ្នកស្រុកណាដែរ មកពីខាងណា?

ប៊ិន ៖ ខ្ញុំអត់ដឹង អត់បានសួរប្រវត្តិគេនឹងទេ ។

ដានី ៖ អត់ទេនោះ?

ប៊ិន ៖ បាទ! ព្រោះនៅជំនាន់នឹងយើងអត់ដែលហ៊ានសួរប្រវត្តិគេទេ បាទ! ។

ដានី ៖ កាលនឹងអឺ!ដូចកាលពេលពូកំពុងតែរៀនជាមួយគ្រូចិន១គាត់ឈ្មោះអីខ្លះដែរ?

ប៊ិន ៖ ចិន ។

ដានី ៖ ដែលបង្រៀនពូ?

ប៊ិន ៖ ដូចថាគ្រូខាងការពារនឹង ខ្ញុំរៀនខាងម៉ាស៊ីននឹង មានអឺ!អាចិនមិនដឹងគេបកថាម៉េចទេណាប៉ុនគេចំណាំឃើញគេហៅឡោ យិក១ បាទ! ។

ដានី ៖ ហៅឡោ យិកហ៎?

ប៊ិន ៖ បាទ!ឡោ យិក ឃើញវាច្រើននិយាយអញ្ចឹង ហើយគាត់ហៅគ្នាគាត់ក៏អញ្ចឹង គេហៅអញ្ចឹងប៉ុនគេនិយាយភាសាចិនទេ គេហៅឡោ យិក១អញ្ចឹងមក បាទ! ។

ដានី ៖ កាលនឹងពូមានរេះចិនអីខ្លះ១?

ប៊ិន ៖ អត់ទេ ប៉ុនដល់យើងរៀន ។

ដានី ៖ ដូចជួបរេះ ដូចហូបបាយ ហូបទឹក សួស្តី សុខសប្បាយ?

ប៊ិន ៖ អីកាលនឹងនៅចាំច្រើនដែរ មកដល់ឥឡូវនេះភ្លេចហើយ ប៉ុនគ្រាន់យើងដល់យើងរៀនជាមួយគេយូរខែអញ្ចឹង យើងដូចថាស្គាល់ពីកាយវិការ គេធ្វើកាយវិការមកហាក់ដូចតែ អូ!ប្រហែលនេះហើយ អូ!ថាចុះហើយ អឺ!ភាសានឹងនិយាយចេញចុះ ។

ដានី ៖ បាទ!ចិនគេមកបង្រៀននឹង បង្រៀនតាមជំនាញ ផ្នែក១ដូច?

ប៊ិន ៖ បាទ!ជំនាញផ្នែក១ ដូចប្អូនខ្ញុំជំនាញខាងម៉ាស៊ីន ដឹងពីរឿងម៉ាស៊ីនម៉ង ហើយអឺ!ប្អូនខាងនោះជំនាញខាងបើកបរ គាត់ថាខាងគ្រូមកបើកបរ ដឹងបើកបរម៉ង បាទ! អឺ!គ្រូខាងកាំភ្លើងដឹងកាំភ្លើងម៉ង កាំភ្លើងអី១ គឺខុស១គ្នា បាទ! ។

ដានី ៖ មានអឺ!ក្នុងកប៉ាល់មួយមានប៉ុន្មានផ្នែកទៅ?

ប៊ិន ៖ កប៉ាល់មួយគេគិតមើល វាឥឡូវមានកាំភ្លើង២៥ កាំភ្លើង៣៧ អានឹងយកអាការពារនឹងណា បាទ!វាមានម៉ាស៊ីន១នឹងបើយើងយកម៉ាស៊ីនក្នុងនឹងវាមានម៉ាស៊ីនទាំងអស់ ម៉ាស៊ីនអូសស្ទាបចាក់៤ បាទ!ហើយនឹងម៉ាស៊ីនអគ្គីសនី២ ។ ដូច្នេះ យុទ្ធជនអគ្គីសនីម្នាក់ ហើយនឹងយុទ្ធជនម៉ាស៊ីននឹងវា៥នាក់ ប្រធានម៉ាស៊ីនមួយផង ។ ហើយក្នុងនឹងប្រធានម៉ាស៊ីនវាគ្រប់គ្រងយុទ្ធជន

អគ្គីសនីមួយទៀត អានឹងផ្នែកក្រោម ។ ហើយដល់មកកណ្តាលមកវាមាន អឺ!មានអនុប្រធាន ហើយអានឹងផ្នែកកណ្តាល ហើយនឹងយុទ្ធជនត្រីវិស័យ បាទ!ហើយនឹងយុទ្ធជនវ៉ាដា ។ បាទ! ហើយដល់មកផ្នែកលើមកមានប្រធាន ហើយនឹងមានកាំភ្លើងនេះឯងកាំភ្លើង៣៧នឹងអាកាំភ្លើង ២៥នឹង ។ សរុបទៅសមាជិកដូចជា៣៦ ហ៎ា បាទ! ។

ដានី : ៣០នាក់ជាងអញ្ចឹង?

ប៊ិន : បាទ!

ដានី : ៣៦?

ប៊ិន : បាទ!

ដានី : បាទ!អញ្ចឹងក្នុងចំណោមដូចថាយុទ្ធជនដែលពូរៀបរាប់មិញនឹង រៀនក្នុងរយៈពេល៦ខែ អឺ!៧ ខែដូចគ្នា?

ប៊ិន : ៧ខែ បាទ!ដូចគ្នា ព្រោះម៉ាវគ្គនឹងដូចត្រូវចប់ទាំងអស់ បាទ! ។

ដានី : ហើយដូចថាយើងរៀន ខាងវគ្គម៉ាស៊ីននឹង យើងមានទៅរៀននៅខាងបើកមានរៀនក្នុងព្រៃ?

ប៊ិន : អត់ទេៗ អត់ ។

ដានី : រៀនខាងតែម៉ាផ្នែកៗនឹងម៉ង?

ប៊ិន : បាទ!លើកលែងតែប្រធានហើយអនុប្រធានទេ ដែលគេៗព្រោះក្នុងឋានៈគេគ្រប់គ្រងរួមគេ ត្រូវឲ្យយល់ដឹងគ្រប់មុខសញ្ញា ។ បាទ!ប៉ុនជំនាញរបស់អនុប្រធាន គឺដែនទីនឹងឯង ហើយបើ ប្រធានគឺទាល់ជំនាញខាងអឺ! និយាយម៉ាត់ឲ្យៗយល់ដឹងទាំងអស់ម៉ង ប្រធាន ។

ដានី : បាទៗ អញ្ចឹងពេលដែលពូរៀនចប់ក្នុងចុងឆ្នាំ៧៥ចូលរៀន ដល់ពេលប្រហែលជា៧៦បានរត់ ចេញមកវិញ?

ប៊ិន : បាន ៧០ព្រោះកាលអា៧៥នឹង កាលនឹងដូចជាពួកគេនឹងគេ មិនទាន់ពុចិនមកទេ អញ្ចឹងរៀន ខាងជើងទឹកដែរ ប៉ុន្តែខាងពួកទាហានជើងទឹកចាស់ យកទាហានជើងទឹកចាស់មកបង្រៀន ។

ដានី : ទាហានខាងលន់នល់?

ប៊ិន : បាទ!

ដានី : មកបង្រៀនដែរ ជំបូងបង្រៀនដែរ?

ប៊ិន : បាទ!បង្រៀន ។

ដានី : កាលនឹងពូចូលរៀនជាមួយទាហាន?

ប៊ិន ៖ បាទ!ដែលរៀនតើ រៀន បាទ! ប៉ុនពួកនឹងវាពិបាកនិយាយៗសុទ្ធតែអង់គ្លេស ជាភាសាអង់គ្លេស គាត់ថាបើបកខ្មែរអត់ចេញដែរ ហើយគាត់និយាយតាមគេគ្រូវាបង្រៀនមកអញ្ចឹងដែរ បាទ! អានឹងតាមនឹងៗ ហើយដល់ចិនយកកប៉ាល់មកឲ្យហាត់នឹង អឺ!ដូចជា៧៦ហើយតាមមើល នឹងហើយ ។

ដានី ៖ ៧៦?

ប៊ិន ៖ បាទ!

ដានី ៖ ដល់ពេល៧៦ យើងបានរៀនបច្ចេកទេសពីចិន?

ប៊ិន ៖ បាទៗ អានឹងបានមកពីចិនហើយ ។

ដានី ៖ អូ! បើកាលពី៧៥ ចូល៧៥នឹងរៀនជាមួយយោធាលន់នល់ទេ?

ប៊ិន ៖ បាទ!នឹងទាហានលន់នល់ទេ ។

ដានី ៖ អឺ!កាលនោះនៅសល់ទាហានលន់នល់ច្រើនដែរ?

ប៊ិន ៖ នៅតែ នៅៗអឺ!សំខាន់អត់ទេវាប្រសប់រកណាស់អានឹងដែល ដឹងថាអាណាអឺ!ខាងចេះអាបច្ចេកទេសអស់នឹង ជំនាញខាងនឹង វាជ្រើសរើសមកៗ បាទ!អាគ្រូបង្រៀនខ្ញុំកាលជាមួយទាហានលន់នល់នឹង ឈ្មោះប៊ិនដូចខ្ញុំមានដែរ បាទ!ប៉ុនមិនដឹងស្អីប៊ិន ខ្ញុំភ្លេចបាត់ ។

ដានី ៖ បាទ!ដល់ពេលរៀនរួចទៅ ធ្វើម៉េចទៅគេឲ្យ?

ប៊ិន ៖ អីទេ យើងគ្រាន់ថារៀនដែលថាជាជាងដូចថាមកហៅទៅហើយមិនឲ្យនៅទំនេរ រៀន ហើយដល់ការពិតទៅអាបច្ចេកទេសនឹង វាខុសគ្នាជាមួយចិន ដល់រៀនជាមួយចិនបានខុសគ្នា ដូច្នេះយកអានឹងប្រើការវាអត់កើតម៉ង ។

ដានី ៖ ចុះដល់ពេលចិនមកទៅ ពូទៅរៀននឹង ពូគេឲ្យទៅធ្វើស្រែវិញ ឬក៏គេឲ្យនៅធ្វើកង់ទ័ពនឹងដដែលទាហានៗខាងទាហានលន់នល់ដែលគ្រូបង្រៀននឹង?

ប៊ិន ៖ អូ!ទាហាននៅនោះនឹង ។

ដានី ៖ បាទ!

ប៊ិន ៖ មិនដឹងដល់អញ្ចឹងមិនដឹងទេ មិនដឹងជាគេយកទៅណាៗ ខ្ញុំនិយាយឲ្យត្រង់ទៅ អត់ហ៊ានសួរម៉ង អត់ហ៊ានសួរសោះរឿងរបស់គាត់ ។ បាទ!បើយើងធ្លាប់ស្គាល់ ធ្លាប់ដឹងដើងចាស់ អានឹងយើងចេះតែ អឺ!យើងដឹងហើយណា ប៉ុនគេឲ្យសួរមើលអ្នកឯងនៅណាអី មកពីណាអី អត់ហ៊ានទេ អត់ហ៊ាន ។

ដានី ៖ បាទ! អឺ!អញ្ចឹងបន្ទាប់ពីរៀនពីចិនហើយ ពូចូលមកនៅកប៉ាល់ការពារ?

ប៊ិន ៖ បាទ!

ដានី ៖ រៀនកប៉ាល់ការពារ នៅកប៉ាល់ការពារ ក្នុងអឺ!រៀនចូលជាមួយចិនឆ្នាំ៧៦?

ប៊ិន ៖ បាទ!

ដានី ៖ អញ្ចឹងដល់ពេលចប់ អឺ!បន្ទាប់ពីរៀន៧ខែទៅ នៅក្នុងចុងឆ្នាំ៧៦ឬក៏៧៧ដែលពូចូលធ្វើការ?

ប៊ិន ៖ អឺ!អានឹងនៅចុង អឺ!ដូចជាចុង៧៦ បាទ!នឹងហើយចុង៧៦ ។

ដានី ៖ ចុង៧៦ពូមកនៅក្នុងកប៉ាល់ការពារ?

ប៊ិន ៖ បាទ!

ដានី ៖ ខាងអី ខាងម៉ាស៊ីន?

ប៊ិន ៖ បាទ!ខាងម៉ាស៊ីន ។

ដានី ៖ ដល់ពេលមកនៅកប៉ាល់ការពារនឹង កប៉ាល់ការពារកប៉ាល់នៅកប៉ាល់ការពារនឹងកាលនឹងប្រធានឈ្មោះអីទៅ?

ប៊ិន ៖ បាទ!ប្រធានឈ្មោះអឺ! ប្រធានអាការពារនឹង ដល់យូរពេកហើយវាមិនបានចាប់អារម្មណ៍ភ្លេចអស់ហើយ វាស្ងាប់បាត់អស់ហើយ ។

ដានី ៖ ឈ្មោះអីទៅ?

ប៊ិន ៖ អឺ!បងហ៊ានៗ បាទ!ប្រធានខ្ញុំ ។

ដានី ៖ អូ!ប្រធានការពារ?

ប៊ិន ៖ បាទ!បងហ៊ាន ដែលថាធ្វើវរសេនាតូចនឹង ។

ដានី ៖ ហើយគាត់ធ្វើប្រធានម៉ង?

ប៊ិន ៖ បាទ!

ដានី ៖ ព្រោះកាលនឹងម៉ាៗវរៈ អឺ!មានកប៉ាល់តែមួយហ៎?

ប៊ិន ៖ បាទ!ម៉ាវរៈនឹងកាលនឹង កប៉ាល់គេមកឲ្យហាត់៤ ឲ្យយកមករៀនដំបូងបំផុតនឹង៤ណាំ ដល់អញ្ចឹងវាត្រូវម៉ាវរៈមួយៗ ។

ដានី ៖ ម៉ាវរៈមួយៗ?

ប៊ិន ៖ បាទ!

ដានី ៖ វរៈមួយៗអញ្ចឹងហ៊ាននឹងគាត់ប្រធាន?

ប៊ិន ៖ បាទ!

ដានី ៖ ដល់ពេលពូមកនៅកប៉ាល់ការពារ ដូចមានបានចេញទៅល្បាត ចេញទៅ?

ប៊ិន ៖ អត់ទេ មិនដែលចេញទេ ។

ដានី ៖ ក្រែងដូចថាពេលដែលយើងហាត់ យើងថាកប៉ាល់ការពារនឹង កប៉ាល់ល្បាត?

ប៊ិន ៖ បាទ!ត្រូវហើយ អានឹងដូចខ្ញុំនិយាយលេងខាងដើមអញ្ចឹង ព្រោះអានឹងបើនៅស្រុកគេសំបូរមកអីដែលគេអ្នកផលិតម៉ង ក៏នាវានឹងក៏មិនជានាទីរបស់វាប្រយុទ្ធទេ នាទីការពារព្រំដែនគ្រាន់តែប៉ុននឹងទេ ។ បាទ! ហើយដល់ស្រុកយើងវាអត់អានឹងវាគេប្រយុទ្ធទៅប្រយុទ្ធដែលនឹង ប៉ុនប្រយុទ្ធដល់៧៩នេះហើយទេ ។ ប៉ុនបើទ្រឹស្តីនៅប្រទេសគេៗមិនទៅប្រយុទ្ធទេ នាវាល្បាតៗធ្វើអញ្ចឹងខុស ។

ដានី ៖ អញ្ចឹងពេលដែលពូចេញៗមកៗ ចេញមកនៅកប៉ាល់ការពារអញ្ចឹងចេញទៅល្បាតដែរ ហើយអត់ទេ?

ប៊ិន ៖ អត់ទេ អត់ដែលចេញទេ ។

ដានី ៖ នៅធ្វើអីទៅអញ្ចឹង?

ប៊ិន ៖ អានឹងដូចថាបោះយុថ្កា ត្រៀមលក្ខណៈអញ្ចឹងម៉ង ។

ដានី ៖ បោះយុថ្កានៅកន្លែងណា?

ប៊ិន ៖ បោះយុថ្កានៅនឹងមុខអូរឈើទាលនេះ ។

ដានី ៖ នៅមុខអូរឈើទាលនឹង?

ប៊ិន ៖ បាទ!

ដានី ៖ ចុះមានចេញទៅម្តងៗចេញទៅតាមកោះអីអត់?

ប៊ិន ៖ បើទៅតាមកោះយូរៗទៅម្តង បាទ!តាមកោះតាងអីនឹង ។

ដានី ៖ ទៅធ្វើអីទៅ?

ប៊ិន ៖ អានឹងដូចថាទៅ ទេ!អានឹងជារឿងរបស់គេ ដូចជាខាងលើរឿងធំៗលើៗ ខ្ញុំមិនយល់ដែរ ប៉ុនតែគេហៅទៅ យើងដឹងតែនាទីរបស់យើង ទៅហើយ ។ ប៉ុនតែគ្រន់ទៅដល់នោះវាធ្វើអីៗប៉ុនតាមខ្ញុំមើលមិនទៅធ្វើអីទេ ដូចថាតាមបទបញ្ជាពីលើមកឲ្យទៅកោះនេះ កោះនោះអីអញ្ចឹងមកវាៗជាដែនរបស់ដែលយើងត្រូវការពារ បាទ!វាគ្រាន់អញ្ចឹងទេ ។ យើងទៅកោះតាង ជាប៊ូឡូវ៉ៃៗ យូរៗទៅម្តងទេ បាទ! ។

ដានី ៖ កោះតាងទៅញឹកញាប់?

ប៊ិន ៖ បាទ!កោះតាងទៅញឹកញាប់ ។

ដានី ៖ ចុះកោះផ្សេងទៀត ដូចជាកោះសេះ កោះព្រីង កោះក្រចកសេះ កោះថ្មី?

ប៊ិន ៖ បាទ! ដល់មកប៉ែកខាងនឹង អត់មកទេ ។

ដានី ៖ អត់ទេ?

ប៊ិន ៖ ព្រោះហេតុអីបាននិយាយអញ្ចឹង ព្រោះកាលនោះគេលាក់ការណ៍ៗចង់និយាយថាម៉ាប៉ែកខាងមករាម មកត្បូងចេះអត់ឲ្យចេញមក បិទមកជើងចេះឲ្យចង់មកកោះកុងមកអី ព្រោះបើចេញពីនោះវ៉ាដាខាងយួនចាប់បាន បាទ!អត់បានទេ ដល់ចេញពីរាមមកនេះ វ៉ាដាយួនចាប់បាន ។ ហើយវាចាប់បានវាដឹងហើយ ដូច្នេះក្នុងក្របខ័ណ្ឌគេលាក់ការណ៍ដែលណា ។

ដានី ៖ បើចេញមកខាងនេះ ចុះថៃអីចាប់អត់បានទេ ខាងកោះតាង?

ប៊ិន ៖ ថៃវាចាប់បាន ប៉ុន្តែដូចអត់មានសួរចាប់អារម្មណ៍អីជាមួយថៃប៉ុន្មានទេ ព្រោះហេតុអីបានថាអញ្ចឹង វាយើងមិនដែលមានបញ្ហា ជាមួយថៃ ។

ដានី ៖ អញ្ចឹងខាងៗរាមមកខាងៗថៃខាងរាម?

ប៊ិន ៖ មករាម មកត្បូងមក មកកើតមក រាមមកកើតមក ។

ដានី ៖ រាមមកកើតមកអានឹងអត់សួរចេញទេ?

ប៊ិន ៖ មិនដែលចេញម៉ង អត់សួរ មិនចេញពីនឹងម៉ង អត់ចេញ ។

ដានី ៖ ខ្លាចវ៉ាដាយួនចាប់?

ប៊ិន ៖ បាទ! ព្រោះ ។

ដានី ៖ ចុះវ៉ាដាយើង?

ប៊ិន ៖ ចាប់បានដូចគ្នា ខាងអឺ!វារៀបចំពីកោះអីៗត្បូងនឹង ។

ដានី ៖ កោះឫស្សី?

ប៊ិន ៖ មិនមែនទេ មិនមែនកោះឫស្សីដែលកោះយួនយករាល់ថ្ងៃនេះ កោះអាធំនេះ ។

ដានី ៖ កោះត្រល់?

ប៊ិន ៖ បាទ!កោះត្រល់ ខាងយួនរៀបចំថាដឹងចេញមកហើយនឹង យើងចាប់បាន ។

ដានី ៖ ដល់យើងចាប់បាន យើងធ្វើម៉េច?

ប៊ិន ៖ ទេ!យើងអត់ធ្វើម៉េច គ្រាន់ដឹងថាអូ!វាចេញមក ចេញ ប៉ុនបើចូលមកដីយើងក៏វាមិនដែលចូលដែរ ចូលមកតែខាងពួកទូកនេសាទទេ ទូកនេសាទតូចៗនឹង ។ បាទ! ប៉ុនដល់អាទូកនេសាទនឹងអឺ! ពួកក្រុមទូកយើងសម្រាប់ល្បាតតាមនឹងទៀត ។

ដានី ៖ អូ!អញ្ចឹងមិនមែនពួកការពារល្បាត មានទូកល្បាត?

ប៊ិន ៖ បាទ!មានទូកល្បាតទៀត ។

ដានី ៖ ទូកអីគេពូ?

ប៊ិន ៖ ទូកឈើនឹងៗ ។

ដានី ៖ ចុះពួកណាអ្នកល្បាត?

ប៊ិន ៖ អានឹងមានពួកក្នុងអន្តភាព អឺ!អានឹងនិយាយទៅដូចជាដឹងនៅវរសេនាធំណាទេអានឹង ដូចជាកង ពលគ្រប់គ្រងផ្ទាល់អានឹង អាអន្តភាពល្បាតនឹង ទូកឈើទេ ។

ដានី ៖ អឺ!អានឹងគេហៅ ក្នុងខុសពីអឺ!ក្នុងខុសពីវរសេនាធំ១៨០ទៀត?

ប៊ិន ៖ ទេ!ហើយបើនៅក្នុងនឹង ខ្ញុំមិនបាន ដូចខ្ញុំថាអញ្ចឹងរឿងដេញដោល មិនបានដេញដោលទេ អត់បានដេញដោលទេ ឬបើថាស្គាល់គឺវានៅស្គាល់នៅធម្មតាអញ្ចឹងទៅ បើថាដេញដោលដូច អត់ហ៊ានទេ ។

ដានី ៖ បាទ!ប៉ុន្តែគ្រាន់ពូដឹងថាអានឹងទូកឈើ?

ប៊ិន ៖ បាទ!ទូកឈើ ។

ដានី ៖ ទូកឈើ?

ប៊ិន ៖ បាទ!

ដានី ៖ ចុះក្នុងពូមានស្គាល់អ្នកក្នុងកង នៅក្នុងល្បាតនឹងដែរអត់?

ប៊ិន ៖ មានស្គាល់ដែរតើ ។

ដានី ៖ ឈ្មោះអីទៅ?

ប៊ិន ៖ បាទ!មានឈ្មោះម៉ៅ អឺ!ឈ្មោះដិន ប៉ុននេះស្លាប់អស់ហើយ ។

ដានី ៖ ម៉ៅ ដិន?

ប៊ិន ៖ បាទ!

ដានី ៖ គាត់ស្លាប់អស់ហើយ?

ប៊ិន ៖ បាទ!ស្លាប់អស់ហើយ ។

ដានី ៖ អត់មានអ្នកនៅរស់ទេ?

ប៊ិន ៖ អត់ទេ ។

ដានី ៖ ពូមានចាំក្នុងចំណោមនឹងមានអ្នកនៅរស់ដែរ?

ប៊ិន ៖ ទេ!ដូចអត់មានណានៅរស់ផង ពួកនឹង ។

ដានី ៖ បាទ! ចុះខបមាដូចមានព្រឹត្តិការណ៍ កាលជំនាន់នឹងពីដំបូងមានគេ អឺ!មានព្រឹត្តិការណ៍ម៉ាយឺ ហេតុសអីដែរ ពូ?

ប៊ិន ៖ មានៗ ព្រឹត្តិការណ៍ម៉ាយ៉ាហ្គេសនឹង ប៉ុនណាខាងខ្ញុំនឹងមិនបាន អេ៎!បើនិយាយអណ្តិខ្ញុំមកអត់បានឃើញទៀតណា ។

ដានី ៖ អត់បានឃើញ?

ប៊ិន ៖ បាទ!អត់បានឃើញនឹង ប៉ុនណាកាលនឹងហើយខ្ញុំក៏មិនដឹងច្បាស់ ថាអ្នកណាគេចេញទៅចាប់អាម៉ាយ៉េហ្គេសនឹង បាទ!មិនដឹងថាអ្នកណា ខ្ញុំមិនបានដឹងទេរឿងនឹងតែឃើញមិនបានឃើញផង ។

ដានី ៖ ប៉ុន្តែពូដឹងទេ?

ប៊ិន ៖ បាទ!គ្រាន់តែដឹងៗរកគេចាប់បានម៉ាយ៉េហ្គេស ។

ដានី ៖ ចាប់នៅកោះណា?

ប៊ិន ៖ ឯណានឹងចេះចាប់នៅអឺ!ផ្លូវអន្តរជាតិនឹង ។

ដានី ៖ ចាប់ពីផ្លូវអន្តរជាតិមក?

ប៊ិន ៖ បាទ!

ដានី ៖ ចុះយើងចាប់អញ្ចឹងវាខុស?

ប៊ិន ៖ វាមិនទេ វាជិតនឹង វាមិនដល់ផ្លូវអន្តរជាតិទេ ប៉ុនវាជិតនឹងណា ឃើញគេចាប់ពីផ្លូវអន្តរជាតិខុសហើយ ប៉ុនវាដូចថាចូលមកជ្រៅដែរនឹង ប៉ុនមិនដឹងចំណុចត្រង់ណា ។ បាទ!និយាយទៅកាលនោះអឺ!យើងក៏ខ្វាចៗ ដូចគ្នា មិនចាំបាច់ចង់ដឹងរឿងអីទេ បាទ!ព្រោះឃើញវាចាប់ប៉េះៗអញ្ចឹង ។

ដានី ៖ ចុះកាលនឹងមានព្រឹត្តិការណ៍គេបាញ់គ្នា មានទម្លាក់គ្រាប់ដែរអីអត់?

ប៊ិន ៖ ទម្លាក់ អាមេរិចកាំងមកទម្លាក់ ។

ដានី ៖ ទម្លាក់នៅណា?

ប៊ិន ៖ ទម្លាក់នៅកង កេង ទម្លាក់នៅរាម ។

ដានី ៖ ទម្លាក់នៅកងកេង នៅរាម?

ប៊ិន ៖ បាទ!ហើយនឹងកំពង់ផែ ។

ដានី ៖ កំពង់ផែ?

ប៊ិន ៖ បាទ!

ដានី ៖ ចុះមានវាយគ្នានៅកោះអីអត់?

ប៊ិន ៖ កោះអានឹង កោះបាទ!វាយនៅកោះៗតាងនឹង អឺ! ។

ដានី ៖ កាលនឹងមាន គេមានបញ្ជូនក្រុមអីទៅវាយនៅនឹង ហើយមានក្រុមគេនៅប្រចាំការណ៍កោះ?

ប៊ិន ៖ ក្រុមប្រចាំការណ៍កោះៗវាយ ។

ដានី ៖ អឺ!ពូស្គាល់ដែរអត់ក្រុម?

ប៊ិន ៖ អត់ទេ ខ្ញុំអត់ៗស្គាល់ទេ ពួកកោះពួកអីអត់សូវស្គាល់ទេ វាស្គាល់ចល័តបន្តិចៗ ព្រោះវាក្មេច យើងត្រូវក្មេច ចុះឧទាហរណ៍ស្គាល់នៅជាមួយគ្នាយ៉ាងស្និតអញ្ចឹង ហើយសម្រាប់ទៅដល់ជួបគ្នាឥឡូវ ដល់ជួបដល់រាយរ៉ាប់ប្រាប់ អូ!នឹកឃើញ ថាអញ្ចឹងវាក្មេចពេកហើយណា ។

ដានី ៖ កាលពេលព្រឹត្តិការណ៍យ៉ាយ៉េហ្គេសនឹង ប៉ុន្មានទៅបានគេដូចថាដោះលែង ក៏ឲ្យលែងទៅវិញ?

ប៊ិន ៖ រឿងនេះខ្ញុំមិនបានតាមដានដឹងទេ ដូចខ្ញុំថាតែឃើញខ្ញុំមិនបានឃើញដែរ ហើយមិនដឹងជាចត នៅត្រង់ណាអីត្រង់ណា ចាប់កន្លែងណាពិតប្រាកដអត់ទេ ។ បាទ! ហើយរយៈពេលប៉ុនណាៗ ក៏ខ្ញុំអត់ដឹង បាទ! ។

ដានី ៖ បាទ!អញ្ចឹងកាលពីពូនៅកប៉ាល់ការពារនឹង នៅចត អឺ!នៅតែ?

ប៊ិន ៖ នៅតែដែនឹងហើយ នៅតែចតនឹង ពោះយុទ្ធានឹង បាទ! ។

ដានី ៖ ប៉ុនៗពួកគេឲ្យទៅតាមកោះម្តងៗ?

ប៊ិន ៖ បាទ! យូរៗវាចេញដើរម្តងដែរ ។

ដានី ៖ យូរៗចេញទៅអឺ!ទៅច្រើនទៅកោះតាង ប៊ូឡូវៃ?

ប៊ិន ៖ បាទ!មិនសូវបានទៅទេ ប៊ូឡូវៃ បើនិយាយទៅកាលខ្ញុំនៅអាការពារនឹងបានទៅម្តង ។

ដានី ៖ បើទៅៗ?

ប៊ិន ៖ ទៅកោះតាងនឹងបានទៅអឺ!៤ ៥ដងនឹងណា ៥ ៦ដងនឹង ។

ដានី ៖ បាទ!ទៅឡើងលើកោះតាងនឹង?

ប៊ិន ៖ បាទ!ឡើង ប៉ុនតែយើងក្នុងឋានៈយើងអញ្ចឹងខ្ញុំមិនហ៊ានឡើងទៅណាឆ្ងាយពីកប៉ាល់បាន ដូចថាកប៉ាល់ចតអញ្ចឹង យើងអាចឡើងអង្គុយលេងលើដែនឹងអីបាន ព្រោះសំខាន់អត់ឲ្យឆ្ងាយពីកន្លែងរបស់ខ្លួន ។

ដានី ៖ បាទ!ចុះពេលទៅនឹងអឺ!ដូចថាពេលយើងទៅៗជាមួយមេបញ្ជាការអីខាងកងពល ខាងវរអីទៅជាមួយ ឬក៏ទៅតែអ្នកដែលនៅក្នុងកងពល?

ប៊ិន ៖ អានឹងតាមបញ្ជារបស់គេ ជួនកាលខ្លះម៉ាកប៉ាល់យើងទៅម៉ង ដូចថាអ្នកណាគ្រប់គ្រងកប៉ាល់បញ្ជាឲ្យកប៉ាល់នឹងចេញទៅម៉ង បាទ!មិនបាច់ថា ប៉ុនខ្ញុំមិនដែលបានដើរទៅជាមួយកងពលផងមិនដែរៗ ។

ដានី ៖ ចុះកាលនឹងដូចថាពេលទៅនឹង ពូទៅដល់កោះគាងហើយៗពូឃើញលក្ខណៈអីយ៉ាងម៉េច គេៗបានគេដូចថានៅលើកោះគាងមានព្រឹត្តិការណ៍អីដែរ?

ប៊ិន ៖ មិនៗដូចថាកាលនោះមិនមាន ទាន់មានព្រឹត្តិការណ៍អីទេ បាទ!ដូចថាទៅអឺ!ហាក់ដូចជាទៅសួរសុខទុក្ខបងប្អូនអីធម្មតា ។

ដានី ៖ សួរសុខទុក្ខ?

ប៊ិន ៖ បាទ! អានេះសម្រាប់ខ្ញុំភ្លាប់បានទេណា បាទ! ។

ដានី ៖ ចុះដូចថាកាលជំនាន់នឹង ដូចពេលពូធ្វើកង័ពអីខាងជើងទឹកអីអញ្ចឹង ដូចពូខស្សាហ៍បានមកលេងផ្ទះ អីក៏ខស្សាហ៍ទាក់ទងអីមកផ្ទះ?

ប៊ិន ៖ មិនបាន ដាច់ម៉ាត់ម៉ង ។

ដានី ៖ ដាច់ម៉ង?

ប៊ិន ៖ ដាច់ម៉ាដំណឹងអីមិនឮ ដូចខ្ញុំនិយាយអញ្ចឹងខ្ញុំថាតាំងពីខ្ញុំចេញពីផ្ទះមក កាល៧/៣អាបេវាយខ្ទាំងនឹង ខ្ញុំបានអឺ!ឈឺគ្រុនឈឺដល់មកដេកពេទ្យៗនឹងក៏បានទៅផ្ទះបាន៣ថ្ងៃ កាលនឹងបេ៥២វាយខ្ទាំងណាស់ ហើយតាំងពីនឹងមករហូត ។

ដានី ៖ បាទ!ចុះមានដែលដឹងដំណឹងឪពុកម្តាយទេ?

ប៊ិន ៖ អត់ទេ អត់ដឹងទាំងអស់ហើយក៏មិនដែល ដឹងសួរសាកសួរតាមដំណើរហ៎ង បើអត់មានមនុស្សចេញចូលទាក់ទងនឹងផង ។

ដានី ៖ ពូអត់ដែលសុំគេមកលេងផ្ទះ ហើយក៏ម៉េច?

ប៊ិន ៖ សុំគេមិនឲ្យមកដែរ ។

ដានី ៖ គេថាកាលនឹងគេអឺ!រវល់ ឬក៏អីយ៉ាងម៉េច បានគេអត់ឲ្យមក?

ប៊ិន ៖ កាលនឹងខ្ញុំហាក់ដូចជាមិនយល់ដែរ ប៉ុនម្យ៉ាងថារវល់ក៏ថាបាន បើនៅច្បាំងយើងវារវល់ច្បាំងប៉ុនដល់ចប់សង្គ្រាម យើងវារវល់រួមចំណែកកសាងប្រទេស អឺ!ហើយបើយើងជាប់រៀនបច្ចេកទេស វាកំពុងជាប់រៀន ។ បាទ!ហើយដល់ចប់ពីរៀនបច្ចេកទេស វាជាប់គ្រប់គ្រងអឺ!មុខសញ្ញារបស់ខ្លួន ដូច្នេះអត់មានពេលដែលថា ។

ដានី ៖ រវល់រហូត?

ប៊ិន ៖ បាទ!រវល់រហូត ។

ដានី ៖ អត់មានឈប់ថ្ងៃសៅរ៍ ថ្ងៃអាទិត្យអី?

ប៊ិន ៖ អត់ទេ អូ!អត់មាននិយាយអាទិត្យ ព្រោះជំនាន់នោះថ្ងៃសៅរ៍ ថ្ងៃអាទិត្យគេ គឺ!អត់មានសៅរ៍ផង មានតែអាទិត្យៗគឺថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ បាទ! ។

ដានី ៖ ឈប់បានម៉ោថ្ងៃៗ សៅរ៍ ថ្ងៃអាទិត្យ?

ប៊ិន ៖ អត់ឈប់ទេ ប៉ុន្តែគ្រាន់ថាអានោះដូចថាមានកម្មវិធីបន្ថែមអីៗយើង អានឹងនិយាយពីរឿងជីវភាពវិញ អឺ!វាគ្រាន់ថាមានកម្មវិធីបន្ថែមអីអញ្ចឹង ថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ វាទាស់ថាឲ្យសម្រាក វាអត់មានសម្រាកអីទេ ។

ដានី ៖ ចុះមានថ្ងៃយើងជួបជុំគ្នា ដូចថាក្នុងកងពល ថ្ងៃគេជួបជុំគ្នា គេប្រជុំ?

ប៊ិន ៖ ជួបជុំ លុះត្រាតែខាងកងពល អឺ!ហៅមកជួបជុំរៀនៗសូត្រខាងនយោបាយ ខាងអីអញ្ចឹងណា ប៉ុន្តែមិនបានជួបទាំងអស់ជាទូទៅទេ គេចាប់តែមេៗដឹកនាំមកមេថ្នាក់ណាៗត្រឹមគេត្រូវយកត្រឹមណាៗមកអញ្ចឹងណា ត្រឹមអនុសេនាតូចឡើងមកលើ ឬក៏ត្រឹមវរសេនាតូច អេ៎!អនុសេនាធំឡើងមកលើអី មកជួបជុំគ្នា នឹងហើយនេះពេលនេះអញ្ចឹង ។ បាទ!បើថាជួបជុំគ្នាតាំងពីយុទ្ធជនអីមកម៉េង អត់ទេ ។

ដានី ៖ អត់នោះ?

ប៊ិន ៖ បាទ!អត់ទេ ។

ដានី ៖ ចុះដូចថាកាលនឹង អឺ!ពេលដំបូងបែកឆ្នាំ៧៥ កងពលទី៣ទេ?

ប៊ិន ៖ បាទ!

ដានី ៖ ដល់ពេលចុះឆ្នាំណាទៅបានគេដូរឈ្មោះទៅជាកងពល?

ប៊ិន ៖ ឆ្នាំអឺ!៧៥នឹង ។

ដានី ៖ ៧៥ហេ៎?

ប៊ិន ៖ បាទ! ក្រោយពីរៀបចំ អឺ!ជាអន្តរជាពដើងទឹកៗប្រយុទ្ធលើគោក ដើងទឹកប្រយុទ្ធលើទឹកនឹងៗបានគេរៀបចំអឺ!ជាកងពល លេខកងពល ។

ដានី ៖ បាទ! មូលហេតុអីបានគេចាំបាច់ដូរពីកងពលទី៣មក១៦៤?

ប៊ិន ៖ ខ្ញុំមិនយល់ដែរទេ ប៉ុន្តែអានឹងការងាររបស់គេ មើលការដូរ ។

ដានី ៖ បាទ!កាលនឹង១៦៤ អឺ!គណៈកងពលអឺ!នៅតែតាមុតដដែល?

ប៊ិន ៖ បាទ!តាមុត ។

ដានី ៖ តាមុត ចុះអនុបន្ទាប់ៗគាត់?

បិន ៖ អនុកផលនឹង មែនទែនទៅវាដូចជាវាចេះឡើងបន្តបន្ទាប់ ហើយក៏ចាប់បន្តបន្ទាប់ដែរ ។ បាទ! យើងកាលនោះមិនអនុកផល មិនអ៊ី!ពីបូព៌ាមក លោកឌឹម បាទ! ។ ដល់ក្រោយពីអ៊ី!លោកឌឹមហើយនឹងឆានមិនអញ្ចឹង ហើយដល់ដកចាប់ៗយើងក៏អត់ដឹងទេ ដល់ដកបាត់ពួកនឹងមកឡើងមកអ៊ី!តាស្រស់តាអីនេះៗ តាស្រស់អីនឹងតាយ៉ាន់នឹង យ៉ានដែលថាប្រធានវរសេនាធំខ្ញុំនឹង ។ ហើយដល់អ៊ី!ដកពួកនឹង បាត់ទៀតមក អានឹងវាចេះតែពេលវេលាចេះតែរំកិលទៅមុខហើយវាមកដល់៧៨ ៧០អីនេះហើយ ចូល៧៨ ៧០អីនេះ បាទ! ។ ហើយដល់ផុតពីនឹងមក ណាដូចជាអ៊ី!យ៉ាននឹងដូចក្រោយគេ កាលនឹងរកតាញ៉ាន់ទេ ។

ដានី ៖ តាញ៉ាន់?

បិន ៖ តាញ៉ាន់ បាទ!អ៊ី!តាង៉ែតៗទៀត ។

ដានី ៖ តាញ៉ាន់ តាង៉ែនហេ៎?

បិន ៖ បាទ!ដល់ហើយចេះ ដកពួកនឹងផុតៗបាត់មក ដកនឹងបានស្លាប់ហើយ បាទ! ។

ដានី ៖ តាញ៉ាន់គាត់នៅដែរ?

បិន ៖ ប៉ុននៅតែតាញ៉ាន់ បាទ!នៅតែតាញ៉ាន់នេះ ប៉ុនចង់និយាយថាហើយតាញ៉ាននេះគាត់មិនដែលបានទៅដល់អនុដល់អីគេទេ គ្រាន់ភស្តុភារទេ ម៉ាកផលនឹង ចំរុះភស្តុភារ ។

ដានី ៖ ភស្តុភារនោះ?

បិន ៖ បាទ!តែភស្តុភារទេ ហើយឯអនុ ឯបញ្ហាអីអានឹងគេអ្នកផ្សេងៗដូចខ្ញុំនិយាយអញ្ចឹង តាង៉ែតអ៊ី!តាឌឹម តាអ៊ី!តា ។

ដានី ៖ តាឆាន?

បិន ៖ ឆាននឹងហើយ តាឆាន ហើយអ៊ី!តាយ៉ានអីនេះ អានឹងសុទ្ធតែឡើងបន្តៗគ្នា ប៉ុន្តែក៏បាត់ទៅវិញបន្តៗគ្នាអញ្ចឹងដែរទៅ ។

ដានី ៖ បាទ!ប៉ុនតាង៉ែតអីនៅដែរអត់?

បិន ៖ តាង៉ែតនឹងអត់ទេ តាង៉ែតនឹងក៏ចាប់តាំងពីមុនគេដងនឹង ។

ដានី ៖ គាត់មកពីបូព៌ាដែរតាង៉ែត?

បិន ៖ អត់ទេតាង៉ែតនៅនឹង នៅអ៊ី! ពីមុនវរសេនាធំតាង៉ែត៦១ៗ តាង៉ែត៦២ ៦១នឹងហើយនៅកងពលលេខ១ ១ កងពលបើមិនកងពលលេខ១លេខ២ ។

ដានី ៖ បាទ!តាង៉ែតហេ៎ ៦១ ៦២?

បិន ៖ ៦២ ៦១ ៦២នឹង វរសេនាធំ បាទ! ។

ដានី ៖ បាទ! ៦២ពីណាគេ?

ប៊ិន ៖ ៦២ មិនដឹងពីណា ។

ដានី ៖ ចុះតាញ៉ាន់?

ប៊ិន ៖ បាទ!តាញ៉ាន់គាត់នៅខាងអឺ! អឺ!តាមាញ់នឹងហើយអឺនឹងហើយតាមាញ់ទៀត បាទ! ។

ដានី ៖ តាមាញ់?

ប៊ិន ៖ បាទ!ប៉ុន្តែពួកនឹងតាមមើលស្លាប់អស់ហើយ ។

គាន៖ សុទ្ធតែចាប់ ។

ប៊ិន ៖ បាទ!សុទ្ធតែចាប់បណ្តើរៗអស់ ។

ដានី ៖ សុទ្ធតែពួកមកពីខាង ជំនៀរខាងនារតីដែរ?

ប៊ិន ៖ មិនទេ មនុស្សបាត់ មនុស្សសុទ្ធតែមនុស្សពួកនារតីនេះ មកពីខាងបូព៌ាតែឌឹមទេ ។

ដានី ៖ ឌឹម?

ប៊ិន ៖ បាទ!

ដានី ៖ ខាងបូព៌ាមកច្រើនដែរ?

ប៊ិន ៖ មកៗម៉ាវរសេនាធំ ។

ដានី ៖ ម៉ាវរសេនាធំហ៎?

ប៊ិន ៖ បាទ! ប៉ុនវរសេនាធំនឹង វាមាននៅជើងទឹកប្រយុទ្ធលើទឹក ជើងទឹកប្រយុទ្ធលើគោក ។

ដានី ៖ ជើងទឹកប្រយុទ្ធលើគោកបានន័យថាពួកប្រយុទ្ធតាមកោះ តាម?

ប៊ិន ៖ បាទ!តាមកោះ តាមអីនឹង បាទ!តាមដីគោកអីនឹង បាទ!ប៉ុនគ្រាន់ចំណុះឲ្យជើងទឹក ។

ដានី ៖ ចុះខាងអឺ!ខាង១៨០ មានអឺ!តាសារឿនមួយទេ?

ប៊ិន ៖ បាទ!វរសេនាធំមានតែបងសារឿននឹងមួយទេ វរសេនាធំ១៨០ ។

គាន៖ ចុះតាហ៊ិន ។

ប៊ិន ៖ អឺ!តាហ៊ិនកាលនឹងនៅអឺ!ជាវរសេនាតូចនៅឡើយ?

គាន៖ អឺ!ខាងជើងទឹកនឹង ការប្រយុទ្ធនឹងហើយ តាសេង ។

ប៊ិន ៖ អូ!តាសេងនឹងមួយទៀត អញ្ចឹងឃើញទេ ដល់អញ្ចឹងបាននឹកឃើញ នឹងហើយតាសេងមួយទៀត ។

ដានី ៖ ទឹមសេងនឹង?

ប៊ិន ៖ បាទ!សេង ស្អីសេងទេ ។

ដានី ៖ គាត់ស្លាប់ហើយឥឡូវ?

ប៊ិន ៖ បាទ!ស្លាប់ហើយ ។

ដានី ៖ តាសារឿនក៏ស្លាប់ដែរ?

ប៊ិន ៖ ស្លាប់អស់ហើយ ។

ដានី ៖ ស្លាប់?

ប៊ិន ៖ តាសារឿនស្លាប់មុន ។

ដានី ៖ ស្លាប់ជំនាន់ណាតាសារឿន?

ប៊ិន ៖ ជំនាន់លយើងរត់ក្នុងព្រៃនេះ ។

ដានី ៖ អូ!តាសារឿន តាសេង ២នាក់នឹង?

ប៊ិន ៖ បាទ!កាលនឹងបងសារឿនបង្រៀននោះ ។

គានៈ បងយើងបង្រៀន ។

ប៊ិន ៖ នឹងហើយ ។

ដានី ៖ សេងអនុ?

ប៊ិន ៖ បាទ!ហើយដល់ក្រោយមកបាន អានឹងរឿងរបស់គាត់យើងមិនសូវដឹងទេ ប៉ុនដល់ក្រោយមក តាមុតនេះឡើងមក កាន់រូមនៅភ្នំពេញនេះមក បានតាសេងគេឡើងកងពលអញ្ជឹងហី ។

ដានី ៖ ដល់តារឿន គាត់នៅជើងទឹកដដែរ?

ប៊ិន ៖ បងសារឿងដល់ហើយខ្ញុំទៅណា ដូចជាៗ ទៅខាងបូព៌ ។

គានៈ ទៅបូព៌ហើយទៅបាន១០០៣ហើយ ខាងលិច ។

ប៊ិន ៖ ហ្នឹងហើយទៅខាងប្រកពាម១០០៣ ប្រកអីណានោះ បាទ!

ដានី ៖ បាទៗ ចុះអញ្ជឹងតាញាន់គាត់នៅតែកាន់ភស្តុភាររហូត?

ប៊ិន ៖ មិនទេ តាញាន់ដលហើយក៏ទៅនឹងដែរ ទៅប៉ែកខាង១០០៣នឹងដែរ គេបញ្ជូនទៅ ។ តាញ៉ាន់ ដល់ហើយដូចជារុញទៅខាងបូព៌ដែរ បាទ! ។

ដានី ៖ នៅតែឈ្មោះតាសេងមួយនៅៗរហូតទាល់បែក៧៩?

ប៊ិន ៖ បាទ!ដល់បែក៧៩រហូត ទល់ព្រំដែនអញ្ជឹងទៅ បាទ! ។

ដានី ៖ បើតាមុតគាត់ទៅមកក្តាប់រូមនៅភ្នំពេញតាំងពីអង្កាល់ឆ្នាំណា?

ប៊ិន ៖ បាទ!អានឹងដូចជា៧៨ តាមុតមកនោះ រដូវ៧៨នឹង ប៉ុនអានឹងយើងវាអត់ច្បាស់ទេ ប៉ុនតែ កំឡុងរដូវនឹងណា ប៉ុនឃើញគាត់ទៅមកៗអញ្ជឹង ។

ដានី ៖ គាត់ទៅមកៗដែរ ចន្លោះនឹង?

ប៊ិន ៖ បាទ!

ដានី ៖ គាត់នៅតែគ្រប់គ្រងកងពលដដែលនឹង?

ប៊ិន ៖ បាទៗ ហើយប្រហែលដល់ស្ថានការណ៍កាលនោះវាអាចតានតឹង វាអាចមកជួយចាត់តែនៅកន្លែងទីបញ្ជាការធំៗ

ដានី ៖ ចុះកាលនឹងទីបញ្ជាការធំរបស់កងពលនៅណា?

ប៊ិន ៖ ទីបញ្ជាការធំរបស់កងពលនៅកំពង់សោមនឹងៗ

ដានី ៖ កំពង់សោម នៅម្តុំណាទៅ?

ប៊ិន ៖ អានឹងនៅម្តុំអឺ!ជិតគោ ខាងជើងគោនេះៗ

ដានី ៖ ខាងជើងគោ២នឹង?

ប៊ិន ៖ បាទ! ខាងជើងគោ ហើយបញ្ចាកបន្តិចៗ

ដានី ៖ គេហៅថាមន្ទីរម៉េចគេនឹង?

ប៊ិន ៖ អានឹងគេហៅមន្ទីរកងពលម៉ង់ៗ

ដានី ៖ ហៅមន្ទីរកងពលហ៎?

ប៊ិន ៖ បាទ!

ដានី ៖ ចុះកាលនឹង អឺ!ដែៗមានប៉ុន្មានកន្លែង?

ប៊ិន ៖ ដែមានតែដែ មានតែ២កន្លែងនឹង ដែរាម ហើយនឹងដែ អឺ!បើមាន បើនិយាយទៅសរុបជាដែមានតែ២កន្លែងទេ ដែយោធា ហើយនឹងដែស៊ីវិលធម្មតាណាៗ បាទ!ប៉ុនដែស៊ីវិលនោះវាមានដែទឹក ដែស្ងួត បាទ!ប៉ុនវានៅជាប់ក្នុងកំពង់ដែដដែលទេៗ

ដានី ៖ ប៉ុនដែរបស់កងទ័ពជើងទឹកមានប៉ុន្មាន?

ប៊ិន ៖ ដែរបស់ជើងទឹក អារបស់ដែ គេដាក់ៗកន្លែងដែរាមម៉ាកន្លែង អានឹងដែៗចាស់ណា ដែថ្មហើយក៏អត់ដែយើង អឺ!ធ្វើក្រោយមកមានតែអូរឈើទាលមួយទេ ធ្វើដោយដៃឯងៗ

ដានី ៖ បាទ!ដែអូរឈើទាល និងដែរាម?

ប៊ិន ៖ បាទ!

ដានី ៖ ចុះដែនៅកោះរ៉ុង?

ប៊ិន ៖ អូ!កោះរ៉ុងនឹងហើយៗ

គាន៖ ស្ងឹងហាវៗ

ប៊ិន ៖ ស៊ីងហាវៗមួយទៀត ប៉ុន្តែស៊ីងហាវយើងមិនមានដែអីស្រួលប្ញូលទេ វាគ្រាន់ថាដូចថាបោះ យកបន្តិចកប៉ាល់មិនហ៊ានចូលចតផងនឹង ព្រោះខ្លាចបុកថ្ម ។

ដានី ៖ បាទ!ប៉ុនគេៗរៀបចំផ្ញើ ហើយអត់ទេ?

ប៊ិន ៖ កាលនឹងគេមានគម្រោងផ្ញើ ហើយគេគម្រោងផ្ញើជាដែថ្មផង ។

ដានី ៖ គេគម្រោងផ្ញើ?

ប៊ិន ៖ បាទ!ប៉ុនថាវាអត់ទាន់បានផ្ញើ ។

ដានី ៖ ចំងាយប៉ុន្មានពីកំពង់សោម ដែនៅស៊ីងហាវនឹង ឆ្ងាយហ៎

ប៊ិន ៖ អីឆ្ងាយ ពីកំពង់សោមទេខ្ញុំមិនដឹងប៉ុន្មានគីឡូដែរទេ ប៉ុនឆ្ងាយដែរនឹង ។

ដានី ៖ ពូធ្លាប់ទៅកន្លែងស៊ីងហាវនឹងដែរអត់?

ប៊ិន ៖ បាទ!ទៅ ។

ដានី ៖ ខាងណាកំពង់សោម កាលនឹងខាងភាគខាង?

ប៊ិន ៖ អឺ!អានឹងយើងចេញពី យើងៗមកទៅអឺ!គេហៅភូមិថ្មី បាទ!ស្គាល់ភូមិនុទេ ។

ដានី ៖ បាទៗ ភូមិថ្មីនៅទំនប់រលកអីនឹង?

ប៊ិន ៖ បាទៗ នឹងហើយៗទៅតាមផ្លូវទៅខាងជើងអញ្ចឹង ទៅតាមអាផ្លូវនឹង ។

ដានី ៖ ទៅជើង អានឹងខាងជើងកំពង់សោមហ៎?

ប៊ិន ៖ បាទ!ជើងហើយមានឆាកចុង ឆាកកើតហើយ កើតបានន័យថាកើតឆាកជើងវិញអានឹង ។

ដានី ៖ បាទ!បើយើងជិះទៅ ប្រហែលប៉ុន្មានម៉ោងយូរដែរ ប្រហែលប៉ុន្មាននាទី ប៉ុន្មានវិនាទី?

ប៊ិន ៖ ទេ!បើតាមខ្ញុំធ្លាប់រត់ឡានកាលនោះ ខ្ញុំខសប្រាហ៍ចេញចូលដែរ ប៉ុនខ្ញុំរត់ឡានដឹកមិនមែនឡានផ្ទេរទេ ឡានដឹកវាអាច ហើយកាលនោះផ្លូវពិបាក មិនជាយូរប៉ុន្មានដែរទេ បើនេះប្រហែលជាថាម៉ោម៉ោងចុះ បើអានឹងយើងរត់ឡានដឹកធ្ងន់ ហើយផ្លូវពិបាក ។

ដានី ៖ ប្រហែល២០គីឡូអីមើលទៅ?

ប៊ិន ៖ ហ៎!មិន២០ទេ ដូចជាង ។

ដានី ៖ ជាង២០?

ប៊ិន ៖ បាទ!

ដានី ៖ ប៉ុនកាលនឹងគេប្រុងរៀបចំការ អឺ!កសាងដែនៅនឹង?

បិន ៖ បាទ!គេរៀបចំ កាលនឹងគេប្រុងរៀបចំមានដៃ តែអានឹងវាមិនមែនជាដៃយោធាដូចថាអាកន្លែងរោងចក្រប្រេងកាតនឹងមានរៀបចំដៃដែរ គេអានេះជាគម្រោងហើយពិសេសខាងដៃយោធាគឺស៊ីងហាវនឹងឯង ។

ដានី ៖ ដៃយោធានៅស៊ីងហាវ?

បិន ៖ បាទ!

ដានី ៖ ដៃយោធានៅស៊ីងហាវ ចុះរាម?

បិន ៖ បាទ!អានឹងក៏យោធា ប៉ុនបើនៅស៊ីងហាវ បានន័យថាវាលាក់ការណ៍ ល្អៗជាងព្រោះនោះវាគំលៀតណ៎ា ។

ដានី ៖ គំលៀតហេ៎?

បិន ៖ វាគំលៀត ចូលមកចេះ ។

ដានី ៖ បាទៗ ចុះដៃៗនៅអូរឈើទាល អានឹងដៃយ៉ាងម៉េចអានឹង?

បិន ៖ អានឹងដៃយើងធ្វើដៃយើងៗសម្រាប់គេថា វាអត់ទាន់មានកន្លែងចត ហើយកន្លែងនឹងវាគ្រាន់ដូចថាលាក់ការណ៍បានម៉ាចំនួនដែរ បើខាងវ៉ាជាយួនវាចាប់អត់បានទេ ។ បាទ!អញ្ចឹងបានវាដូចថាវាបាំងបួយៗកោះ ។

ដានី ៖ បាទៗ បាំងគយៗកោះអញ្ចឹងហើយ បានន័យថាយើងធ្វើនឹងដើម្បីលាក់ការណ៍កុំឲ្យខាងគេចាប់បានហេ៎?

បិន ៖ បាទ!

ដានី ៖ ចុះ បើពួកនេសាទអីដូចថាទៅដំបូងអីអញ្ចឹង មើលខាងថៃគេយកកប៉ាល់ដើងទឹកគេមកកាងអីអញ្ចឹង ឲ្យពួកនេសាទគេមកចាប់ត្រីអីអញ្ចឹង កាលពីដំបូង ដល់ពេលក្រោយមកយើងហាត់រៀនខាងកប៉ាល់ខាងអីដូចខាងការពារខាងអីហើយ ក្រោយមកពួកថៃគេមានមកចូលមកនេសាទ?

បិន ៖ បាទ!អត់មាន ។

ដានី ៖ ចុះខាងយួន?

បិន ៖ យួនបើកប៉ាល់ការពារនេសាទមក មានពួកនេសាទ ប៉ុនមកពួកនឹងលេងដាក់កាំភ្លើងតាម ។

ដានី ៖ ពួកយួនដាក់កាំភ្លើងតាម?

បិន ៖ បាទ!កាំភ្លើងសុទ្ធតែយូសេធ យូវីទអីទៀតណា ចាប់បាន ។

ដានី ៖ ដល់ពេលដាក់កាំភ្លើងតាម គេធ្វើម៉េច?

ប៊ិន ៖ បាញ់ៗ បាទ! បាញ់ បាទ!កាលនឹងមានរបួសមានអីហូរហែល បាទ! ។

ដានី ៖ បានន័យថាពួកនេសាទៗគេក្លែងក្លាយ ពួក?

ប៊ិន ៖ មិនដឹងជាយ៉ាងម៉េចយើងមិនបានយល់តែទៅជិតមានកាំភ្លើងដៃមានបេអីបាញ់ដូចយើងធម្មតា ប៉ុនបើយើងនៅជិតឆ្ងាយល្មមនឹងវាតហើយយូសេធ លេងយូសេធហើយណា ។

ដានី ៖ កាលនឹងពួកកប៉ាល់ការពារយើងទៅ?

ប៊ិន ៖ មិនមែនទេ ដូចខ្ញុំនិយាយអញ្ចឹង អាទូកឈើ ។

ដានី ៖ ទូកឈើនឹង?

ប៊ិន ៖ បាទ!ទូកឈើដែលទូកល្បាតនឹង ហើយអឺ!មួយទៀតមានអាស្ទី អាផ្ដាច់មីន មានអាបោសមីន យកមកចិញ្ចឹមដែរអានឹង ប៉ុនអានឹងតាមសាកសួរថថាវាកប៉ាល់ចាស់ដែរ ហើយប៉ុនវារៀង តូចៗ ប៉ុនវាមានល្បឿនជាងគេបន្តស់ ។

**ការស្សេតទី២ ផ្នែក«ក»**

ដានី ៖ ចុះពូកាលនឹងដូចថាពួកយួននឹង ក៏ពួកអ្នកនេសាទគេមានកាំភ្លើងដែរ?

ប៊ិន ៖ បាទ!

ដានី ៖ កាំភ្លើងដល់ពេលអញ្ចឹង អ្នកចូលអឺ!ពួកនេសាទនឹងចូលមកនេសាទក្នុងដែន?

ប៊ិន ៖ ក្នុងដែនទឹកយើង ។

ដានី ៖ ដែនទឹកយើង?

ប៊ិន ៖ បាទ!

ដានី ៖ ដល់បាញ់គ្នាអញ្ចឹង យើងមានចាប់បានដែលអត់?

ប៊ិន ៖ ហ៉េ!កាលនឹងដូចជាអត់ដែលមានចាប់បានផង ព្រោះយើងមិនដែលបានចូលដល់ចាប់ទេ ព្រោះ ហើយទូកយើងភាគច្រើន ទូកយើងតូចជាងទូកគេ ។ ហើយទូកគេរបៀបគេមានគម្រោងចូល របស់គេចេះ គេអាចប្រើម៉ាស៊ីនលឿនៗ ហើយយើងកាលនោះក៏វាមានគម្រោងការពារដូច គ្នា ប៉ុន្តែយើងវាខ្វះបច្ចេកទេសការរៀបចំទូកម៉ាស៊ីនឲ្យវាមានប្រជេញនេះណា ។ បាទ!ហើយ ដល់អញ្ចឹងយើងភាគច្រើន ត្រង់ត្រូវចេះទៅរបួសរបស់គេ ។

ដានី ៖ ត្រូវរបួសហ៉េ?

ប៊ិន ៖ បាទ! ចុះពេទ្យមួងវ៉ាន់ មិនបាក់ជើងបាក់អីដោយសារល្បាត ។

ដានី ៖ ល្បាត ចុះអឺ!ក្រោយៗមកទៀត ពូមានពូដែលឃើញគេ អឺ!ពូដឹងពីថាមានកប៉ាល់បរទេស អីៗ ចូលមកវង្វេង ចូលមកឬចូលមកខាងកោះតាង ចន្លោះ៧៨ ក្នុងឆ្នាំ៧៧ ៧៨អី?

ប៊ិន ៖ អានឹងដូចជាមានៗ ដូចជាមានម្ដងតា ហ្នឹងហើយមានម្ដង ដែលគេថាកប៉ាល់វង្វេងនឹងណា បាទ! ប៉ុនខ្ញុំវាភ្លេចដែរវាងអត់ៗចង់ចាំ តិចមាំណាស់ឥឡូវនេះ ។

ដានី ៖ បាទៗកប៉ាល់វង្វេងនឹងបើតាមពូនៅចាំ កប៉ាល់នឹងកប៉ាល់យ៉ាងម៉េច បានវង្វេងចូលមកដែនសមុទ្រយើងនឹង?

ប៊ិន ៖ ទេ!កាលនឹងតាមពូបងប្អូនគាត់ អឺ!ដូចថាយើងចេះតែសួរគ្នាអញ្ចឹងថាទិសទៅគេថាទៅថៃវិញ មិនវង្វេង គេថាអញ្ចឹង ។

កាន៖ បងស៊ីមៀន គាត់ធ្វើអ្នកបកប្រែ ។

ប៊ិន ៖ ហ្នឹងហើយ បងស៊ីមៀនបកប្រែ អ្នកបកប្រែ អ្នកបកៗអឺ!ជាភាសាអង់គ្លេស ។

ដានី ៖ បាទ!ឈ្មោះស៊ីមៀននឹងគាត់អ្នកបកប្រែ?

ប៊ិន ៖ បាទ! ប៉ុនស៊ីមៀននឹងនៅជាមួយគ្នា នៅក្នុងវរសេនាធំជាមួយគ្នា ។

កាន ៖ ប៉ុនស្លាប់ប្ដូរស់?

ប៊ិន ៖ មៀន! ស្លាប់បាត់ហើយនឹងមៀនប្ដីយាយវននឹងណា ។

កាន ៖ ប្ដីយាយវន ។

ដានី ៖ យាយវននឹងគាត់នៅដែរអត់?

ប៊ិន ៖ ទេ! វននៅប៉ុនមិនដឹងនៅត្រង់ណាឥឡូវនឹង ។

កាន ៖ យកគ្រួសារទៀត ។

ប៊ិន ៖ បាទ!យកប្ដីទៀត ប៉ុនបើនៅអាចនៅជួរខាងលិចនឹង អាផ្លូវឈោងមកនេះ ម៉ាជួរអស់នឹងហើយ

កាន ៖ ទោកប៉ាល់ណាគេចាប់ឃើញៗគេចាប់ ។

ប៊ិន ៖ បាទ!នៅម្ដុំជួរអីឈោ ជួររ៉េតអីនឹង បើសិនជានៅណា ។ បាទ! ប្ដូក៏គាត់មកស្រុកគាត់ផ្ទះគាត់វិញមិនដឹងប៉ុនស្រុកទេសយើងមិនបានដឹងច្បាស់ទេ ប៉ុនដឹងថាគាត់នៅស្រុកកោះអណ្ដែត ប៉ុនមិនដឹងនៅឃុំអីអត់ដឹង ។

ដានី ៖ ប្រពន្ធគាត់ឈ្មោះយាយវនហ៎?

ប៊ិន ៖ បាទ!យាយវន ។

ដានី ៖ យាយវន អ្នកស្រុកកោះ អឺ!យាយវននឹងអ្នកស្រុកកោះអណ្ដែត?

ប៊ិន ៖ បាទ!ហ៎! តាមខ្ញុំដឹងទេណា ប៉ុនអត់ដឹងនៅភូមិអីឃុំអីទេ ។

ដានី ៖ បាទៗ អឺ!ហើយខ្ញុំចង់ដឹងពីដូចថា កាលនឹងពូគ្រូដំណើងថាម៉េច មានកប៉ាល់វង្វេង កប៉ាល់នឹងវាយ៉ាងម៉េច បានវាវង្វេង?

ប៊ិន ៖ ទេ! គេមិនដឹងជាគេមានបំណងអី ឬក៏វាវង្វេងមែនក៏មិនដឹង ហើយក៏មិនដឹងជាគេដឹករបស់អី ដែរ ប៉ុនតាមបងប្អូននិយាយថាគេមានទិសដៅទៅថៃទេ ហើយកាលនឹងគេសួរថាកប៉ាល់នឹង ចេញមកពីណា មកពីហុងកុងអញ្ចឹងហេ៎ ដូចថាមក ។

កាន ៖ កាលមុនអត់បានចាប់អារម្មណ៍ គ្រាន់ដឹងៗ ។

ប៊ិន ៖ ដឹងដូចថាមកពីហុងកុង ខ្ញុំដឹងហេ៎ថាចូលទៅថៃ ប៉ុនតែដូចថាវង្វេង ។

ដានី ៖ វង្វេង?

ប៊ិន ៖ បាទ!

ដានី ៖ កាលនឹងវង្វេងនៅកន្លែងណា?

ប៊ិន ៖ ទេ!មិនដឹងជាចំណុចត្រង់ណាដែរ ។

កាន ៖ អឺ!រឿងនឹងវាមាន២វគ្គ វគ្គទី១វង្វេងនោះម្តងនោះថា ។

ប៊ិន ៖ អាម៉ាយ៉ាហ្គេស ។

កាន ៖ ជិតកប៉ាល់ អឺ!ជិតកោះរ៉ុងទេ ខាងឃាត់ឲ្យយើងឃាត់ទេ យើងវាយសញ្ញាទៅដាក់ថាស្តុប អា សញ្ញាស្តុបគឺឈប់ ហើយដល់ឈប់ហើយគេសួរមកវិញ ឃាត់គេធ្វើអី យើងក៏អត់មានពាក្យ និយាយគឺអត់ចេះ ចេះតែសញ្ញារៀនចេះតែៗគេឲ្យរៀនប៉ុន្មានចេះប៉ុននឹង ។ ដល់អញ្ចឹងបាន ជួបបងស៊ីមៀន គាត់ទើបបកទៀតគេដឹងរឿង ប៉ុន្តែកាលនោះទៅណា វង្វេងអីទេ ពីទីនេះនឹក ឃើញថា គិតថាកាលជិនាន់ម៉ាយ៉ាហ្គេស កាលនឹងក៏មានពត៌មាន វាកម្ពុជាប្រជាធិបតេយ្យ នឹងគាត់បានថ្លែងការណ៍ដែរ មានតាំងពីរ៉ាដា លេខផ្សាណូអីណា ម៉េចបានប្រែទៅជាបានវង្វេង បានអីនឹង កាលជិនាន់ម៉ាយ៉េហ្គេសនឹង ឬក៏វង្វេងថាវង្វេងដែរ នឹងសមាជិកប៉ុន្មាន៤១រូបបាត់ ម៉ារូបឃើញនៅ៤០នឹងណា ។ តាមពិតម៉ារូបនោះនៅទាក់ទងខាងបញ្ជូនពត៌មានទៅស្រុកក្រៅ វិញទេប្រទេស ។

ប៊ិន ៖ បាទ!ខាងទូរលេខវា ដឹងបន្ទប់វាណា ។

ដានី ៖ បាទ!ចុះអាកប៉ាល់ក្រោយ កប៉ាល់វង្វេងនឹងដូចថាកាលនឹងវង្វេងនឹងក្នុង បើតាមពូចាំក្នុងចន្លោះ ខែណា ដូចជាខែវស្សា ឬក៏ខែប្រាំងកាលជិនាន់ដែលពូព្ធថាកប៉ាល់វង្វេង ក្រោយមកទៀត មិនមែនកប៉ាល់ម៉ាយេហ្គេសទេ អាកប៉ាល់ក្រោយ?

ប៊ិន ៖ បាទ! កប៉ាល់ក្រោយដែលថាវង្វេងនៅថៃនឹងហេ៎ ។

ដានី ៖ បាទៗ!

ប៊ិន ៖ តាមមើលដូចជាខែ ជិតៗរដូវវស្សាហើយមើលនេះ ប្រហែលជាម៉ុំធ្លាក់ទឹកភ្លៀងនឹង ។

ដានី ៖ ខែភ្លៀង?

ប៊ិន ៖ បាទៗ ប្រហែលជាម្តុំខែធ្លាក់ទឹកភ្លៀង ។

ដានី ៖ ធ្លាក់ទឹកភ្លៀង?

ប៊ិន ៖ បាទ!ប៉ុនតែយើងវាមិនបានចាំ មិនបានចាប់អារម្មណ៍អីអញ្ចឹងទេ ។

ដានី ៖ កាលនឹងខ្យល់សមុទ្របកមកពីខាងណា?

ប៊ិន ៖ បាទ!មកពីលិច ។

ដានី ៖ បកមកពីខាងលិច?

ប៊ិន ៖ បាទ!មកលិច ព្រោះខែនឹងខែរលកហើយនឹង ។

ដានី ៖ ខែរលក?

ប៊ិន ៖ ខែរលកហើយនឹង ហើយបើរលកវាចាប់ពីខែ៩ឡើងមក អានឹងរលកហើយសមុទ្រ

កាន ៖ អត់បានកត់ចំណាំដែរ ។

ប៊ិន ៖ បាទ!យើងមិនចាប់អារម្មណ៍អញ្ចឹងៗអីទេ បាទ!គ្រាន់ដឹងថាធម្មតាហើយនោះម៉ាចុបៗអញ្ចឹង ។

ដានី ៖ កាលនឹងក្រុមអ្នកដែលៗទៅដូចថាទៅបកប្រែទៅឃាត់នឹង ក្រុមឈ្មោះអឺ!ក្រុមអឺ!ក្រុមពូឈ្មោះស៊ីមៀននឹង?

ប៊ិន ៖ បាទ!

ដានី ៖ ស៊ីមៀនគាត់បេះអង់គ្លេស?

កាន ៖ តាមពិតស៊ីមៀននឹងគាត់នៅកន្លែងវរសេនាធំទេ ។

ប៊ិន ៖ នៅកន្លែងវរសេនាធំម៉ង បាទ! ។

កាន ៖ ហើយកប៉ាល់នោះចាប់បានយើងឃាត់ទុកមិនលែង មិនដឹងអីគេមិនដឹង កាលគេទៅមិនឲ្យគេទៅ អញ្ចឹងឃាត់ខ្លួន ប៉ុនមិនដឹងនិយាយគ្នា ទាល់តែយកបងស៊ីមៀននឹងដឹកទៅបានគាត់បកបាន ប៉ុន្តែដឹងកាលនោះកប៉ាល់អ្នកណាខ្ញុំមិនបានចាំ ។

ដានី ៖ បាទៗ កាលនឹងអឺ!ឈ្មោះស៊ីមៀននឹងគាត់ការជាមួយអឺ!ឈ្មោះ?

ប៊ិន ៖ វ៉ន ។

ដានី ៖ យាយវ៉ននឹងនៅ?

ប៊ិន ៖ បាទ!

ដានី ៖ គាត់ការហើយ គាត់មានប្រពន្ធនៅយាយវ៉ន?

ប៊ិន ៖ បាទ!ទេ! កាលនោះដូចជាមិនដឹងជាយ៉ាងម៉េច អត់បានចាំ ត្រង់មានប្តីមានប្រពន្ធហើយនៅ

កាលនឹង បាទ! វាអត់បានចាប់អារម្មណ៍ ប៉ុន ។

ដានី ៖ ប៉ុន្តែយាយវននឹងមើលទៅគាត់នៅរស់នេះ?

កាន ៖ នៅ ។

ប៊ិន ៖ នៅហ៎! ឥឡូវនៅ មិនដឹងនៅណា ។

កាន ៖ ហើយដល់ក្រោយមកមានឈឺថ្កាត់អី ប៉ុន្តែបើនិយាយពីវ័យនោះមិនទាន់អីទេ ។

ប៊ិន ៖ បាទ!នៅវ័យខ្ទង់ស្រករខ្ញុំជាមួយខ្ញុំ ខ្ទង់ស្រករគ្នានឹងទេ ។ បាទ!ប៉ុនបើបងស៊ីមៀនគាត់ចាស់ហើយ បើសិនជានៅក៏ចាស់ដែរឥឡូវនេះ ។

ដានី ៖ បាទ!បើចង់សួរទាក់ទងរកយាយវនៗនឹងទៅសួរខាង?

ប៊ិន ៖ ដល់ទៅទាក់ទងខាងឈា ខាងអីវិញ ។

ដានី ៖ បាទៗ ។

ប៊ិន ៖ ក្រែងៗ ។

ដានី ៖ បាទៗ ខ្ញុំកាលនឹងខ្ញុំនៅជួបអឺ!ពូរ៉េត គាត់ប្រាប់ថាឈ្មោះស៊ីមៀន គាត់ប្រាប់ថាឈ្មោះ កុលអីនឹង គាត់ថាអញ្ចឹង?

ប៊ិន ៖ បាទៗកុលៗ ។

កាន ៖ កុលវាចេះបកហើយ ។

ប៊ិន ៖ កុលនឹងហើយគេជំនាញខាងអង់គ្លេស អង់អីហើយ ។

កាន ៖ ក្នុងនឹងកុលនឹងក៏អាចចូលរួមក្នុងនឹងដែរកាលនោះ ប៉ុនកងពលអត់សូវបានចាប់ខ្លួនដែរ ។

ប៊ិន ៖ កុលនឹងមន្ទីរកងពល ។

ដានី ៖ ប៉ុនកាលនឹងកុលធ្លាប់ចូលរួមដែរ?

ប៊ិន ៖ មិនដឹងម៉េច ។

កាន ៖ សួរមិនដឹងយ៉ាងម៉េច ប៉ុន្តែប្រហែលជាដឹងរឿងនឹង ពីព្រោះគាត់ មានតែគាត់ដែលចេះ ភាសាកាលនោះគាត់ថ្នាក់ខ្ពស់ហ៎ ។

ប៊ិន ៖ គាត់រៀនថ្នាក់ខ្ពស់ ។

ដានី ៖ ប៉ុន្តែបើតាមពូចាំ ដឹងថាអឺ!ពូឈ្មោះស៊ីមៀននឹង ដឹងថាគាត់ទៅ?

កាន ៖ ទៅដែរកាលនោះ គាត់ចេញមានអ្នកបក ។

ប៊ិន ៖ ស៊ីមៀននឹងក៏គាត់រៀនថ្នាក់ខ្ពស់ដែរ ។

ដានី ៖ គាត់អ្នកស្រុកណា អឺ!ស៊ីមៀននឹង?

ប៊ិន ៖ ហ៎!មិនដឹង ។

កាន ៖ មិនដឹងដែរ តែគាត់អឺ!ជាកងទ័ពអឺ!តំបន់៣៣ ។

ប៊ិន ៖ ហ្អឹងហើយតំបន់កំពង់ស្ពឺយើងនេះ ដែលកាលនោះគេហៅ៣៣នោះ ។

កាន ៖ តំបន់៣៣លេខ១០២ តំបន់៣៣ ទ័ពតំបន់កាលនោះ ទៅមិនរួចទេមេគេទៅ ។

ប៊ិន ៖ ជាមួយទូច ។

ដានី ៖ អ៊ឺ!បើសួរពូទូចគាត់អាចដឹងពីពូស៊ីមៀននឹង?

ប៊ិន ៖ បាទ!ប្រហែលគេដឹងៗ ព្រោះកាលគេអ្នកនៅអឺ!នៅតំបន់នឹងដូចគ្នា ។

កាន ៖ កាលនោះកងទ័ពបែកតំបន់ ។

ដានី ៖ ទៅសួរពូទូចៗនេះហ៎?

ប៊ិន ៖ បាទៗ ទូច សាលី ។

ដានី ៖ ទូចសាលី គាត់ឈ្មោះ?

ប៊ិន ៖ ទូចទេ ឈ្មោះសឿ ទូច ប៉ុនដល់ឥឡូវដល់គេធ្វើសមាគមន៍នឹងគេបកមកទូច សាលីវិញ ។

កាន ៖ បាទ! តាមពិតគេឈ្មោះសឿ ទូចទេ ។

ដានី ៖ បាទៗ អញ្ចឹងកាលកប៉ាល់វង្វេងនឹង វង្វេងខែភ្លៀង ប្រហែលជាក្នុងឆ្នាំ បើតាមពូចាំប្រហែល
ជាឆ្នាំ៧០ប៉ុន្មានទៅ ៧០?

ប៊ិន ៖ ខ្ញុំប្រហែលជា៧៨ ៧០អីនឹង ។

ដានី ៖ ៧៨ហ៎?

ប៊ិន ៖ បាទ!

ដានី ៖ ជិតៗបែកហើយអញ្ចឹងហ៎?

ប៊ិន ៖ មែននៅទេ មិនទាន់ជាជិតប៉ុន្មានទេ កាលនឹងវាកំពុងតែបើមិនចុង៧៧ ៧៨នឹង ។

ដានី ៖ ៧៨ហ៎?

ប៊ិន ៖ បាទ!

ដានី ៖ ប៉ុនពូចាំថានៅក្នុងខែភ្លៀងហ៎?

ប៊ិន ៖ បាទ!

ដានី ៖ ខែភ្លៀងខែ?

ប៊ិន ៖ ខែភ្លៀង បើខ្ញុំខែ៥ ខែ៦អីនឹង ។

ដានី ៖ បាទៗ កាលនឹងពូអឺ!កាលកប៉ាល់នឹងវង្វេងនឹង វង្វេងហើយគេៗឃាត់ អឺ!គេអឺ!ដូចថាគេឃាត់

កប៉ាល់នឹង យាត់នៅម្តុំខាងណា កោះណាទៅ?

ប៊ិន : អឺ!ខ្ញុំអត់ដឹងចំនុចទេ ដល់ចំនុចអត់ដឹងត្រង់ណាដែរ ។

ដានី : អត់ដឹងនោះ?

ប៊ិន : បាទ!អត់ត្រង់ណា គ្រាន់ដឹងថាគ្រាន់ពូៗគេថាយាត់ៗមានយាត់មានអី ចាប់កប៉ាល់វង្វេងចាប់កប៉ាល់អីនឹង ។

ដានី : បាទៗ ដឹងថាកប៉ាល់នឹង អ្នកនៅក្នុងកប៉ាល់នឹង អឺ!អត់ចេះនិយាយខ្មែរទេ?

ប៊ិន : ប្រហែលជាមិនចេះទេ តាមមើលបានយកបងមៀនទៅ ។

ដានី : បាទ! ចុះដល់ពេលក្រោយមកមានឃើញពួកអ្នកដូចថានៅលើកប៉ាល់នឹង ត្រូវបានគេបញ្ជូនមកមន្ទីរ?

ប៊ិន : អត់ទេៗ អត់ដែលបានឃើញ មិនដឹងជាគេយកមកណាទៅណាមកណា ហើយម៉េចខ្ញុំអត់បានដឹងទេ ព្រោះដូចខ្ញុំថាអញ្ចឹងស្អីដែលកប៉ាល់នៅណា គឺមនុស្សនៅនឹង ។ ដូច្នេះពត៌មានក៏អត់សូវដឹងអត់សូវពូអីដែរ ។ បើបាននៅអែបដែទៅ ជាប់ដៃទៅ គ្រាន់បានឡើងលេងលើដៃមានសេរីភាពបន្តិច ប៉ុនបើបោះយុថ្កាគឺ នៅកណ្តាលទឹកហើយ ប៉ុន្មានថ្ងៃប៉ុននឹងហើយ ។

ដានី : ពូៗដឹងថាកប៉ាល់នឹងមកពីហុងកុង ទៅឆ្ពោះទៅថៃ?

ប៊ិន : ទេ! គ្រាន់ពូថាអញ្ចឹងទេ ប៉ុនជាក់ស្តែង ដឹងគេចេញមកពីណា ហើយទៅណាទេ បាទ! ។

ដានី : កប៉ាល់នឹង អឺ!រៀងកប៉ាល់ដូចកប៉ាល់នេះដែរអត់?

ប៊ិន : អឺ!មិនបានឃើញផង ។

ដានី : អត់ដែលបានឃើញទេ?

ប៊ិន : អត់បានឃើញផង ។

ដានី : នេះមានកប៉ាល់មួយដែរ កប៉ាល់ថាអឺ!បរទេសមួយថាវង្វេងដើរចូល?

ប៊ិន : វាមិនបានឃើញអាកប៉ាល់គេនឹងណា ។

កាន : មិនបានឃើញកប៉ាល់ផង ។

ដានី : អត់ឃើញនោះ ពូអត់បានឃើញ?

ប៊ិន : បាទ!

កាន : វាមានព្រឹត្តិការណ៍នឹងច្រើនអារឿងកប៉ាល់នឹង ។

ដានី : មានច្រើនៗ?

ប៊ិន : បាទ!

កាន ៖ បាទ!ជាហូរហែលវាមិនដឹងកប៉ាល់ណាខ្លះ អឺ!ដូចជាយើងមិនបានឃើញ ដោយផ្ទាល់នៅកោះ ឃើញកោះឃើញអី ។

ប៊ិន ៖ អត់មានឃើញកោះ ។

ដានី ៖ បើតាមកាលនឹងពូចាំ ប្រហែលខាងៗណាកោះៗតាង?

កាន ៖ ដូចជាមិនមែនកោះតាងទេ កាលចាប់នឹង ដូចជាហួសកោះរ៉ុងបន្តិចហ៎ កោះរ៉ុងៗនុង ហ្មង ។

ប៊ិន ៖ បាទ!ខាងលិចកោះរ៉ុងៗហ្មងហ៎ ។

កាន ៖ បាទ!

ប៊ិន ៖ អឺៗ ។

កាន ៖ អានឹងតាមចាំ ខ្ញុំមិនប្រាកដដែរ ។

ប៊ិន ៖ អានឹងគេហៅថារ៉ុងក្រៅ កោះរ៉ុងក្រៅអានឹង បាទ! ។

ដានី ៖ កោះរ៉ុងក្រៅហ៎?

ប៊ិន ៖ បាទ!

ដានី ៖ បាទ!ដល់ពេលក្រោយមកទៀត មកអត់មានដឹងដំណឹងកប៉ាល់នឹងត្រូវគេដោះលែងទៅវិញ ឬ ចាប់កប៉ាល់នឹង?

ប៊ិន ៖ មិនបានដឹងទេ ។

កាន ៖ អត់ដឹងៗទេបាទ! មានតែម៉ាយ៉ាហ្គេសទេ មុននឹងដោះលែងទៅត្រូវធ្វើអន្តរាគមន៍ខ្លាំងមែន ទែន ។

ប៊ិន ៖ បាទ!ប៉ុនខ្ញុំក៏អត់បានឃើញ ។

កាន ៖ ម៉េចបានឃើញខ្ញុំនៅកោះប៉ូឡូវ៉ៃកាលនឹង ។

ប៊ិន ៖ អូ!ខ្ញុំអត់បានសួរ ។

ដានី ៖ ចុះអឺ! ពូអឺ! កាលនឹងពូនៅបន្ទាប់អឺ! ពីនៅការពារមកពូផ្លាស់មកនៅកប៉ាល់បណ្ដែតអីឆ្នាំណា ទៅ?

ប៊ិន ៖ ឆ្នាំណា ខ្ញុំមកនៅអាបណ្ដែតនឹងដូចជា៧៧ ។

ដានី ៖ ៧៧ហ៎?

ប៊ិន ៖ បាទ!

ដានី ៖ ដល់ពេលពូមកនៅបណ្ដែតនឹង អឺ!នៅកន្លែងណាដល់ពេលពូ?

ប៊ិន ៖ អឺ!កាលនឹងខ្ញុំភាគច្រើន ឥឡូវមិនដឹងជាស្អីគេដាក់ឈ្មោះស្អី ប៉ុនភាគច្រើនខ្ញុំច្រើនបោះយុថ្កានៅ

មុខអូតែសុខា ។

ដានី ៖ បោះយុថ្កានៅនឹង?

ប៊ិន ៖ បាទ!

ដានី ៖ អត់ៗមានចេញទៅនេះ?

ប៊ិន ៖ អត់ទេ មិនសូវចេញប្រតិបត្តិការណ៍អីទេ ប៉ុនបើសិនហ៉ា!ដូចត្រូវអី! ហ៉ាកជូនមេៗទៅកោះនេះ កោះនោះអី អានឹងបានចូលទៅដៃ ។ ដៃនឹងគឺ ចូលអី!ដៃអូរឈើទាលនឹងឯង ។

ដានី ៖ ចុះអ្នកនេសាទថៃអីយ៉ាងម៉េចដែរ ដល់ពេលក្រោយមក?

ប៊ិន ៖ ទេ!ដល់ពួកនេសាទថៃ កន្លងមកក៏ពួកខាងល្បាតដើងទឹកនឹង ក៏គេចាប់បានអានោះប៉ុន្មានគ្រឿង អាធំៗអា១០០០សេស ម៉ា២២០០សេសនឹង មួយគ្រឿង អា១០០០នឹងម៉ាគ្រឿង ។

កាន ៖ បើ៨០០នឹងច្រើន ។

ប៊ិន ៖ អឺ! បើ៨០០នឹងច្រើន ។

ដានី ៖ បាទ!ខ្ញុំអឺ!អ៊ីឡូនប្រាប់ខ្ញុំដែរថា កាលនឹងអាម៉ា១២០០ អា៨០០អីគេចាប់យកមកខាងរាម នឹង?

ប៊ិន ៖ បាទៗ ។

ដានី ៖ ចុះកាលនឹងអ្នកនេសាទនឹងគេបញ្ជូនទៅណាទៅគេចាប់ហើយ?

ប៊ិន ៖ បាទ!ដល់ចំនុចនឹងអត់ដឹង មែនទែននិយាយឲ្យត្រង់ គឺមិនដឹងថាគេយកទៅណាមកណា ហើយ មានសមាជិកប៉ុន្មាននាក់ អត់ដឹងហើយបាទ! ។

ដានី ៖ បាទ!ប៉ុនដឹងថាគេចាប់មកដែរ?

ប៊ិន ៖ បាទ!ដឹងៗហើយអានឹងបានឃើញទូកនឹងម៉ង ។

ដានី ៖ ឃើញទូកនឹង?

ប៊ិន ៖ បាទៗ បានឃើញ បានឡើងមើលអី បាទ!ពួកគេ ។

ដានី ៖ ប៉ុន្តែមនុស្សអី?

កាន ៖ ទេ!នេះខ្ញុំមើលមិនមែន កប៉ាល់ដឹកទំនិញ ។

ប៊ិន ៖ មិនមែនទេ ។

កាន ៖ អាកប៉ាល់តូចៗ រូបថតអញ្ចឹងឃើងមើលមិនច្បាស់ តាមមើលអាកប៉ាល់តូចៗទេ អានឹងៗមិន មែននៅលិចកោះរ៉ុងនេះ ។

ប៊ិន ៖ បាទ!

ដានី ៖ អានេះនៅណាតាមពូដឹង?

កាន ៖ តាមពិតពួកនេះៗអានេះទំនងសំនាញ់នេះ អានេះសំនាញ់កុំឲ្យធ្លាក់មនុស្ស ។

ប៊ិន ៖ បាទ!កប៉ាល់ប្រយុទ្ធ ។

កាន ៖ ហើយអញ្ចឹងកប៉ាល់នឹងទំនងចាប់យកមកម៉ុំអី! ម៉ុំរាមនេះវិញទេ ហើយម៉េច អឺ!កោះ ។

ប៊ិន ៖ កោះតាងគៀវ?

កាន ៖ កោះតាងកោះអី ។

ដានី ៖ កោះតាងហេ៎?

កាន ៖ បាទ!ពីព្រោះកប៉ាល់នោះមានដងពីលើខ្ពស់ណាស់ ប៉ុននៅតុបពីក្រោយនេះមានប្រើម៉ាស៊ីនតូចមួយ ខ្ញុំនៅចាំ ប្រើម៉ាស៊ីនតូចមួយសម្រាប់មិនដែល ហើយពីលើចាក់ថ្ម ហើយគេថានៅលើអីទៀត ក្នុងនឹងមានកាស្សែតរបស់គេនឹងផ្ទាល់ មានសូរសាន់ណៃចេញមុន ហើយពួកខ្មែរយើងស្រែកនឹង ស្រែកចាប់ឡើងលោតចូលអីនៅរបស់វាទាំងអស់ នៅបាតទាំងអស់ ។

ដានី ៖ គេចាប់បាន សម្ដេងគេនៅក្នុងនឹងទាំងអស់?

កាន ៖ សម្ដេងគេនៅក្នុងទាំងអស់ ។

ប៊ិន ៖ អត់ទេ ប៉ុនខ្ញុំអត់បានទៅឃើញ ។

កាន ៖ គ្រាន់ដឹងប៉ុននង មិនមែនពួកយើងទៅចាប់ ពួកធំៗទៅ ពួកអឺ!កប៉ាល់ពួកBE Bអីថាវង្វេងនោះក្រោយមកទៀតកប៉ាល់ប្រភេទនឹង២ ៣គ្រឿងទៀត ប៉ុន្តែដូចជាមិនចាប់បានទេហើយមនុស្សគេនៅនឹងអត់ច្រើនទេ តែ៣ ៤នាក់ប៉ុននឹងឯង មើលយូរមិនមែនកប៉ាល់ធំទេ ។

ដានី ៖ បាទ!ប៉ុនមនុស្សក្នុងនឹងគេយ៉ាងម៉េចដែរកាលនឹង?

កាន ៖ ឃើញមានរបួសម្នាក់កាលនឹង ។

ដានី ៖ មានរបួសម្នាក់ហេ៎?

កាន ៖ បាទ!របួសត្រូវដៃ ។

ដានី ៖ បរទេសហើយក៏?

កាន ៖ បរទេស ខ្ពស់ស្ដើង

ដានី ៖ ខ្ពស់ ស្ដើង ប្រហែលជា អឺ!រូបថតក្នុងនេះ ពូមើលៗដឹងដែរអត់?

កាន ៖ អឺ!អត់ចាំទេ យូរហើយ អត់ចាំៗ ប៉ុន្តែគេអត់មានពាក់អាវទេ ស្លៀកខោអីទេ មានស្លៀកតែខោខ្លី បាទៗ វាត្រូវកំពូតដៃមើលពីក្រៅ ។

ដានី ៖ អូ!កាលនឹងដល់ពេលមាន អញ្ចឹងមានខាងកងពលគេទៅដែរអត់?

កាន ៖ អត់ទេ នៅកោះតាងអត់មានអ្នកណាទៅដង កាលនឹងមានតែកម្លាំងយើងអ្នកកងបណ្តុតជាអនុសេនាធំ សេនាតូចអីគេនឹង ។

ដានី ៖ បាទ!កាលនឹងពូបានទៅឃើញផ្ទាល់ដែរ?

កាន ៖ ខ្ញុំពេលគេចាប់បើកមកបានខ្ញុំទៅមើល ។

ដានី ៖ ទៅមើល អឺ!គេចាប់បានមកនៅណា?

កាន ៖ មិនដឹងមកនៅណា ខ្ញុំភ្លេចហើយ ប៉ុនដូចជាទំនងកោះតាងកាងនោះភ្លេចទៅ មិនដឹងជាកន្លែងណា ។

ដានី ៖ បើរូបថតកូល័រពូមើលឃើញ បើរូបថតកូល័រពូ?

កាន ៖ អត់មានៗ ដូចអត់មានឃើញកន្លែងណាដែលខ្ញុំសម្គាល់បាន ខ្ញុំមិញខ្ញុំអង្គុយមើលយូរទៅខ្ញុំនឹកឃើញពីរឿងដងអីអញ្ចឹងវែងអញ្ចឹង ប្រហែលជាមិនមែនកប៉ាល់ទំនិញទេ ទៅជាកប៉ាល់អ្នកដំណើរក៏មាន ដងខ្ពស់ហើយដង ដែកតាំងលេស ហើយខ្សែនេះ មិនមែនខ្សែធម្មតាគឺខ្សែដែកតូចៗ សៗ ។

ដានី ៖ បាទ!ខ្ញុំមានរូបថតច្បាស់ ប៉ុន្តែក្នុងComputer អានេះដល់ពេលផ្តិតមកវាខ្មៅហើយ ចាំថ្ងៃណាអឺ!មកលើកក្រោយខ្ញុំយកComputerមានរូបថតនឹងច្បាស់ អាចពូមើលឃើញច្បាស់មើលទៅអញ្ចឹង ។

កាន ៖ បាទ! ប៉ុនខ្ញុំផ្ទាល់មិនឃើញម៉ាស៊ីននៅពីក្រោម ។

ដានី ៖ អញ្ចឹងកាលពូទៅមើលនឹងមានគ្នាពូទៅប៉ុន្មាននាក់?

កាន ៖ ដូចជាខ្ញុំមើលថ្ងៃនឹងដូចជា៤នាក់ ឬក៏៣នាក់ មិនដឹង ។

ដានី ៖ មានស្រីទេ ក្នុងនឹង?

កាន ៖ អត់ឃើញស្រីទេ ដូចថានៅក្នុងនោះអត់ចុះទៅក្នុងដង ហើយយើងគ្រាន់ទៅឃើញធ្លាក់នៅលើដំបូង លើរនាបចេះណា អាយើងអង្គុយលើនេះណា ឃើញដែកសរសៃរធ្លាក់ពីអង្កាល់ដែរកាលនឹងដៃៗចាក់ស៊ីម៉ង់ម៉េចមិនដឹងទេ កប៉ាល់នឹងជ្រៅណាស់ ។

ដានី ៖ កប៉ាល់នឹងជ្រៅ ប៉ុន្តែតូចទេ?

កាន ៖ តែវាតូចរាក់លើនេះ ព្រោះកប់ក្រោមចៀសវៀងអាការឃោងក្រឡាប់អីទៅ ទោះបីជារលកក៏មិនចេះក្រឡាប់ដែរ ហើយដងគេនឹងខ្ពស់ណាស់ៗខ្ពស់មែនទែន ។

ដានី ៖ ក្នុងនឹងសុទ្ធបរទេសតែម្តង២ ៣នាក់នឹង?

កាន ៖ បាទ!ឃើញសុទ្ធតែបរទេស នៅនឹងដូចជា៣នាក់ ឬក៏៤នាក់ទេ ដូច ។

ដានី ៖ កាលទៅនឹងពីណាគេ អ្នកទៅបកប្រែនឹង?

កាន ៖ អត់ៗមានអ្នកណាបកទេកាលនឹង អត់មានបកទេ គ្រាន់តែយើងចាត់ក្នុងនឹងក៏កាលនោះមានខ្ញុំមិនច្បាស់ កាលជាភស្តុតាងឬកន្លែងណា ព្រោះខ្ញុំទៅមើលនឹងរកនឹកត្រង់កន្លែង ។

ដានី ៖ ខាងកើតកោះតាង?

កាន ៖ មាននៅម្តុំកោះតាង មិនដឹងគេចាប់ត្រង់ណាទៅ ប៉ុន្តែប្រហែលជាគេដឹក ។

ដានី ៖ ប៉ុន្តែគេយកមកកោះតាងនឹង?

កាន ៖ គេយកមកកោះតាង ។

ដានី ៖ បាទ!គេយកមកកោះតាង គេបញ្ជូន?

កាន ៖ បាទ!គេបញ្ជូនមកៗយើងកំពង់សោម មិនដឹងទៅណាមកណែទៀតទេ ។

ដានី ៖ បាទៗ បញ្ជូនមកកំពង់សោម បញ្ជូនមកខាងរាម ហើយក៏បញ្ជូនមកខាងអូរឈើទាល ។

កាន ៖ ខ្ញុំមិនច្បាស់ដល់ពេលនឹង ព្រោះពេលនឹងឆ្ងាយគ្នាណាស់ ក៏កាលយើងចូលកាលនោះ មិនដែលបានចេញមក ។

ដានី ៖ កាលនឹងពូមាននៅចាំខែដែរអត់?

កាន ៖ ខែដូចជាខែ៦ ខែ៧ ។

ដានី ៖ ខែ៦ ខែ៧?

កាន ៖ បាទ!ព្រោះកាលនោះខ្យល់ណាស់ ។

ដានី ៖ ខ្យល់ខ្លាំង?

កាន ៖ បាទ!ក្នុងខែអញ្ចឹង បាទ!ខ្យល់បោកបកអញ្ចឹង ។

ដានី ៖ ខ្យល់រលក ពេលចាប់នឹងដូចថាមេឃសមុទ្រអីរលក?

កាន ៖ បាទ!វារៀងងងឹតណាស់ ។

ដានី ៖ ងងឹតហេ៎?

កាន ៖ បាទ!ព្រោះពេលនោះខ្ញុំអត់បានទៅនឹងគេទេ តែខ្ញុំនៅកន្លែងនឹង តែខ្ញុំដឹងថាពួកវាដែលចាប់យកមកនឹងដូចពេលវេលាអញ្ចឹង ។

ដានី ៖ បាទ!ពេលម៉ោងប៉ុន្មានទៅចាប់នឹង?

កាន ៖ អឺ!ប្រហែលជាយប់ជ្រៅហើយតាមមើល តាមពិតទៅប្រហែលជាម៉ោង៨ ម៉ោង៩ទៀតហើយ ។

ដានី ៖ ម៉ោង៨ ម៉ោង៩យប់?

កាន ៖ បាទៗ ម៉ោង៩យប់ណា ។

វណ្ណៈ ៖ ប៉ុនដល់ពេលគេចាប់បាននៅលើកោះនឹង ពូបានទៅមើលផ្ទាល់?

កាន ៖ បាទ!ខ្ញុំបានទៅមើលម៉ង ។

ដានី ៖ ពេលអី!ពេលទៅមើលនឹង ពូទៅមើលយប់ ហើយក៏ទៅមើលពេលណា?

កាន ៖ យប់មើលយប់ បាទ!មើលទាំងយប់ប៉ុនគេបើភ្លើង បើកចាំងពិលចាំងហ្វាអីអញ្ចឹងបាទ!យើង ។

ដានី ៖ ប៉ុន្តែក្នុងចំណោមពនាក់នឹងមានរបួសម្នាក់?

កាន ៖ មានរបួសម្នាក់ របួសស្រាល របួសដៃ ។

ដានី ៖ អ្នកដែលរបួសនឹង អឺ!មាឌយ៉ាងម៉េច វៀង?

កាន ៖ អឺ!សស្តើងខ្ពស់ ។

ដានី ៖ គាត់ស ស្តើង ហើយខ្ពស់?

កាន ៖ ប៉ុនជនជាតិគេវាច្រើនស ស្តើងខ្ពស់អញ្ចឹងណា ប៉ុន្តែគ្រាន់ថាខ្ញុំមិនដឹងថាគេនឹងវាមាត់យ៉ាងម៉េច វាអត់ច្បាស់ទេ ។

ដានី ៖ បាទ!គាត់ស្លៀកពាក់អីដែរ ពេលនឹង?

កាន ៖ អត់ទេស្លៀកខោខ្លី ។

ដានី ៖ ខោខ្លីហ៎?

កាន ៖ បាទ!ខោខ្លី ហើយកាលនោះ ។

ដានី ៖ ខោខ្លីពណ៌អី?

កាន ៖ បាទ!ពណ៌វៀងសៗ ហើយកាលនោះដូចជាគ្មានអឺ!ពាក់អាវផង កាលនឹង ទៅដល់នោះយើងរុំណា យើងរុំឃើញសៗធ្លាក់ក្នុង«ក»នេះ ប៉ុន្តែដៃនឹងបើសិនមិនចងក៏វាអត់នេះដែរ វាអាចផ្ទុះដាច់ផ្ទុះអីវាបាក់អ្ហីងណា ។

ដានី ៖ បាទៗ កាលនឹងឆ្នាំណា ពូចាំឆ្នាំទេ?

កាន ៖ នេះគាត់នឹងដឹងៗប៉ុន្មាន ។

ដានី ៖ ប៉ុនដូចថាយើងប្រហែលជាក្រោយមករយៈពេលប៉ុន្មានយើងបែក៧៩នោះ ដូចថាជិតដែរ ឬក៏នេះ?

កាន ៖ ឆ្ងាយដែរ បាទ!ដូចឆ្ងាយដែរ យើងប៉ាន់ទៅថាដូចជាទំនងដូចម៉ាឆ្នាំអីអញ្ចឹង ម៉ាឆ្នាំៗជាងអីនោះ បាទ! ហើយកាលនឹងមានពត៌មានថាកប៉ាល់នឹងគេវង្វេងទិសអីយើងទៅគេធ្វើបាបអីណា ដូចថាអញ្ចឹង បើថាមានទៀត ប៉ុនមិនដឹង មិនដែលបានឃើញទេ ឃើញតែមួយនឹងទេ ។

ដានី ៖ ប៉ុន្តែដឹងថាមនុស្សនឹងបញ្ជូនមកខាងកងពលហើយនោះ?

កាន ៖ បាទៗ ក្នុងនឹងជួបពួក**ពែល**បានដឹងម៉ង តាមមើល ពួកពែល ។

ដានី ៖ តាពែលគាត់នៅណា នៅ?

កាន ៖ កោះតាង មិនដឹងនៅណា តាពែល ពីដើមនៅកោះតាង ។

ដានី ៖ ប៉ុន្តែគាត់នៅរស់ទេ សព្វថ្ងៃហ៎?

ប៊ិន ៖ បាទ!កាលពី៧៩នឹងមក មិនដឹងជាយ៉ាងម៉េច ខ្ញុំដូចមិនច្បាស់ដែរ ប៉ុន៧៩យកពីនឹងមកក៏នាំគ្នាស្លាប់នៅ ។

ដានី ៖ បាទ!ឈ្មោះតាពែលហ៎?

ប៊ិន ៖ បាទ!តាពែលនឹងប្រហែលជានៅម្តុំយើងពី **ខេត្តតាកែវអង្គតាសោម**អីទៅចេះ អានឹងណា ។

ដានី ៖ ស្រុកកំណើតរបស់គាត់ ហើយយ៉ាងម៉េច?

កាន ៖ ស្គាល់អត់ច្បាស់ កំនើតយើងនិយាយគ្នា គ្រាន់ដឹងៗអញ្ចឹងណា ។

ដានី ៖ ប៉ុន្តែគាត់អ្នកនៅខាងណា ខាងអង្គតាសោមហ៎?

កាន ៖ បាទ!

ដានី ៖ បើចង់ទៅរកឈ្មោះតាពែលនឹងទៅ បើយើងទៅសួរពីណាអាចដឹង?

កាន ៖ យើងរកមិនឃើញទេ ទៅខ្សែតាមកងទ័ពវិញ ខ្សែខាងតាយាន ពួកតាយានតាអីនឹងបានដឹងតាយាននៅណានឹង រ៉ុននៅហើយ អូ!មិនដឹងទៅណាទៅណែខ្លះ ។

ប៊ិន ៖ តាយានហើយសួរបងនួន ។

កាន ៖ អឺ!សួរបងនួនវិញ ស្រែអំបិលទៀតហើយ ត្រង់នឹងសួរបងនួន នឹងហើយ រកតាយានអីសួររកឃើញតាពែលនឹងហើយ ដឹងរឿងនឹងច្រើនជាង ។

ប៊ិន ៖ សួរនួននឹងនៅត្បូងដឹងហើយ ។

កាន ៖ ហើយដឹងរឿងនឹងច្រើនជាងខ្ញុំពួកខ្ញុំនិយាយនឹងដឹងច្រើនជាង ព្រោះកាលនឹងគេប្រចាំការណ៍ គេមិនឲ្យយើងទៅចាប់ទេ ទៅចាប់នឹងអាចដឹង ឲ្យអាពួកកប៉ាលឈើទៅចាប់ទេ ពួកកប៉ាល់ធំៗគេអត់ឲ្យទៅ ។

ដានី ៖ បាទ!កាលនឹងពួ កាលចាប់នឹងអឺ!ខ្យល់សមុទ្រមកពីខាងណា ដូចថាខ្យល់ទិសសមុទ្រ?

កានៈ ខ្ញុំដូចអត់បានចាំ ខ្យល់មិនបានដឹងតែពេលមេឃរៀនងងឹតណា................ ។

ប៊ិន ៖ ប៊ិនតែខែ៦ ខែ៧នឹងខ្យល់ពីលិចហើយ ។

កាន ៖ បាទ!រឿងខ្យល់ខ្លាំង ។

ដានី ៖ ខ្យល់ពីលិច?

កាន ៖ បាទ! គ្រាន់ដឹងអញ្ចឹង បាទ! ។

ដានី ៖ ប៉ុន្តែដឹងៗស្ថានភាពអ្នកដែលនៅក្នុងកប៉ាល់នឹងយ៉ាងម៉េចដែរ ដូចថាពេលដែលពូទៅដល់នឹងគេក្នុងកប៉ាល់នឹងរបៀបដូចថារបៀបខ្លាច ឬក៏ឡូឡាៗ ឬក៏?

កាន ៖ ឡូឡាៗពេញ ។

ដានី ៖ ឡូឡាម៉េច?

កាន ៖ យើងក៏ឡូឡា មាត់គេឃាត់ ឡូឡាហើយខ្ញុំអត់ដឹង ព្រោះគេកំពុងតែឡូឡាខ្ញុំមិនដឹងដែរ តែខ្ញុំក្តាមអាម៉ាញ៉ែគេ ។

ដានី ៖ បាទ!អញ្ចឹងខ្ញុំសុំបញ្ចប់ពូបន្តិច ។

ប៊ិន ៖ បាទ!

ដានី ៖ អឺ!ពូអញ្ចឹងដល់ពេលក្រោយពីកប៉ាល់ៗអឺៗបន្ទាប់ពីមាន កប៉ាល់វង្វេងមក ពូមានដែលឃើញកប៉ាល់ផ្សេងទៀតអត់?

ប៊ិន ៖ ខ្ញុំដូចជាៗមិនបានចាំថាមានកប៉ាល់ណាទៀត ក្រោយពីអាកប៉ាល់អាវង្វេងនឹងមក វាដូចជាមិនបានៗចាប់អារម្មណ៍ទៀតនឹងណា ។

ដានី ៖ បាទ!ចុះពួកដែលនេសាទថៃក៏ពូអត់ដឹងដែរនោះ?

ប៊ិន ៖ បាទ!នេសាទថៃអត់ដឹងទេ ដឹងថាឲ្យយកទៅណាមកណាទៀត ខ្ញុំអត់បានដឹងដែរ ។

ដានី ៖ ចុះនេះ អឺ!មានខាងដូចខាងពីភ្នំពេញអីគេចុះមកខាង ពូមានដែលដឹងអត់?

ប៊ិន ៖ ខាងភ្នំពេញ!

ដានី ៖ បាទ!

ប៊ិន ៖ ភ្នំពេញចុះទៅ!

ដានី ៖ ចុះទៅខាងសមុទ្រអី អឺ!ចុះមកខាងកងពលអីនឹង?

ប៊ិន ៖ អឺ!ខាងភ្នំពេញនឹងចង់ និយាយពីខាងណានេះ ។

ដានី ៖ ដូចខាងសេនាធិការ ខាងអី?

ប៊ិន ៖ អូ!ខាងសេនាធិការៗវាដូចមិនដែលឃើញ បើសភាពការណ៍អញ្ចឹងៗមិនដែលឃើញថាសេនាធិការអីចុះទៅទេ ។ អានឹងបើក្រែងលរគេចុះទៅមកជាប់ត្រឹមកន្លែងកងពលអីម៉េចមិនដឹងទេប៉ុន្តែព្រោះយើងវាមិនងាយបានចេញរួចពីប៉ុករបស់យើងបន្តិចនឹងទេ ។

ដានី ៖ បាទៗ ចុះពូកាលជំនាន់នោះពូមានគ្រួសារនៅ?

ប៊ិន ៖ បាទ! នៅ ។

ដានី ៖ នៅឆ្នាំណាបានពូមានគ្រួសារ?

ប៊ិន ៖ បាទ! នៅចុង៨៤ ។

ដានី ៖ ចុង៨៤ហ៎ ដល់ពេលពូទៅខាង?

ប៊ិន ៖ កាលទល់ដែន ។

ដានី ៖ ទល់ដែន ។ ពូអឺ! ដូចថាពូធ្លាប់តស៊ូតាំងពីឆ្នាំ៧១រហូតដល់នេះ ពូយល់ឃើញថាការតស៊ូរបស់ពូនឹងដូចថាមកដល់សព្វថ្ងៃ ពូមើលទៅក្រោយវិញដូចការតស៊ូ ពូគិតថាការតស៊ូរបស់ពូយ៉ាងម៉េចដែរ?

ប៊ិន ៖ ខ្ញុំចង់និយាយថា កាលនោះខ្ញុំគិតថាវាសប្បាយ បាទ! វាសប្បាយដូចនិយាយអញ្ចឹង បើក្មេងវាជ្រើមនេះដែរណា ។ បាទ! ប៉ុនដល់វ័យវដ្តយើងកាន់តែច្រើនមក យើងកាន់តែមានការគិតច្រើនដែរ ។ បាទ! ហើយខ្ញុំនិយាយសរុបមកដល់ចុងក្រោយៗមក ក្រោយពីខ្ញុំធ្លាក់ខ្លួនរបួសពិការអីអញ្ចឹងមកណា វានឹកឃើញថា អានេះឃើញចំពោះមុខទេ សម្រាប់បុគ្គលរបស់ខ្ញុំទេ ខ្ញុំថាវាទាស់តែចាញ់បោកគេ ។

ដានី ៖ ទៅចាញ់បោកគេវិញ?

ប៊ិន ៖ បាទ! ចាញ់បោកគេ ព្រោះបើសិនជា ហើយបានថាចាញ់បោកគេ បើសិនជាក្រោយពីយើងដកអី! ខ្លួនថយមកអញ្ចឹងមក បើមានសម្បត្តិអីគ្រាន់អី! ទប់ទល់ក្នុងជីវភាពគ្រួសាររបស់យើង បើថាវាគួរសមដែរនឹង វាដូចជាមិនសូវស្តាយក្រោយទេ ប៉ុនបាតដៃទទេរស្អាត បាទ! នៅបកក្រោយមកបាតដៃទទេរស្អាត ។ ហើយមកប្រឡូកក្នុងសង្គមអញ្ចឹង ដែលសង្គមគេគ្រាន់បើដែរមិនថាវាយ៉ាងម៉េចទេ ប៉ុនសម្រាប់មើលមកយើងដូចជាអត់អីសោះ ដល់អញ្ចឹងអន់ចិត្តដែរ បាទ! អន់ចិត្តដែរ ។ ហើយអានឹងចេះបាននៅរស់ប៉ុននេះ គ្រាន់របួសស្នាមអីប៉ុននេះ ចុះបើផាប់វាចប់បាត់ហើយ បាទ! ។

ដានី ៖ ចុះពូកាលជំនាន់នឹងពូ ដូចថាអ្នកដឹកនាំប្រទេស កាលពីសម័យនឹង ពូធ្លាប់ស្គាល់ ធ្លាប់ឃើញធ្លាប់ដឹងថាមានពីណាខ្លះ ដល់ពេលកាលពូនៅខាងជើង កាលនឹងនៅខាងជើងទឹកនឹង?

ប៊ិន ៖ អ្នកដឹកនាំកំពូលៗម៉ង!

ដានី ៖ បាទ!

ប៊ិន ៖ កំពូលៗ អានេះបើគ្រាន់តែឮចេះតែឮទៅ ប៉ុនបើនិយាយសម្រាប់ឃើញស្គាល់ដែលគឺថាពេលជួនកាលខ្លះគេហៅទៅរៀនសូត្រអីម្តងកាលនឹង អឺ! បានស្គាល់ប៉ុលពត បានស្គាល់សុនសេន

បាទ!បានស្គាល់អឺ!នួនជា ខ្ញុំចង់និយាយកាលនឹងបាទ! ហើយនឹងទៀវសំផននឹងឃើញយូរៗម្តងហ៎ៗ បាទ! អឺ!អានឹងដែលខ្ញុំធ្លាប់ឃើញណា៎ មិនជាញឹកញាប់ទេ ប៉ុនតែវាអាចក្នុងចំណោមដឹកនាំបានឃើញ ។

ដានី : ចុះដូចប៉ុលពត ពូឃើញគាត់នៅពេលណា?

ប៊ិន : ខ្ញុំឃើញពីចាប់ពី៧៥មក៧៥ចុង៧៥នឹង អឺ!គេតែងតែហៅទៅរៀនសូត្រ បាទ!អឺ!រៀនសូត្រនៅស្តាតនេះ ហើយក៏ចាប់ស្គាល់គាត់ពីត្រឹមនឹង ។

ដានី : បាទ!កាលនោះ ច្រើន ពេលរៀនសូត្រនឹង គាត់ច្រើននិយាយពីរឿងអីទៅ?

ប៊ិន : បាទ!គាត់និយាយពីរឿងអឺ! កាលរៀនសូត្រនយោបាយរបស់គេសំខាន់សំដៅទៅ ទី១ការកសាងប្រទេស ទី២ការពារប្រទេស ហើយសំខាន់អឺ!ពង្រឹងៗជួរកងទ័ព ដើម្បីអឺ!ការពារប្រទេស ។

ដានី : ជួបគាត់តែពេលប្រជុំអីអញ្ចឹងទេ?

ប៊ិន : បាទ!

ដានី : គាត់អត់ដែលមកទស្សនះកិច្ចអីក៏?

ប៊ិន : ទស្សនះកិច្ចនឹង ខ្ញុំនៅជើងទឹកនឹងអឺ! ប៉ុនខ្ញុំអត់បានចាំឆ្នាំខែថ្ងៃ ខ្ញុំភ្លេចហើយណាអឺ!បានមកកាលខ្ញុំនៅនាវាការពារនឹងមកម្តង អឺ!ជូនគាត់ទៅលេងអឺ!ទៅទស្សនះកិច្ចនៅកោះកុងនេះ កោះកុងយើងនេះណា នៅកោះម៉ង់ណា ។ បាទ! ហើយដល់ខ្ញុំមករៀននៅអឺ!កប៉ាល់បណ្តែតនឹងម្តងជួបម្តងទៀត ទៅកោះកុងនឹងដែរ ។

ដានី : ពីណាគេ?

ប៊ិន : បាទ!ប៉ុលពត ។

ដានី : ដឹកគាត់ ជិះកប៉ាល់ជាមួយពូទៅតែម្តង?

ប៊ិន : បាទ!

ដានី : កាលនឹងអឺ!ពីណាដែលទៅជាមួយគាត់ខ្លះ?

ប៊ិន : បាទ!ដើរជាមួយគាត់ ភាគច្រើនជាមួយសុនសេនទេ ។

ដានី : ជាមួយសុនសេន?

ប៊ិន : ព្រោះសុន បាទ!កាលនោះសុន សេនគាត់ជាអឺ!អគ្គបញ្ជាការ អញ្ចឹងទៅណាមកណាច្រើនគាត់អមទៅជាមួយគ្នាគាត់ ។

ដានី : គាត់ទៅកោះកុង ទៅធ្វើស្អីទៅ?

ប៊ិន ៖ ទេ!បើតាមខ្ញុំមើលដូចជាមិនឃើញមានធ្វើស្អីផង ទៅអាកន្លែងកោះនឹងហើយឡើងអឺ!អាកន្លែងនឹងវាមានដែ ពួកខ្មែរក្រហមនឹងណា បាទ!អាដែយើងធ្វើដែនឹងហើយនៅកន្លែង ។ ប៉ុនមិនដឹងជាកន្លែងកោះនឹង ជាវរសេនាធំ ឬក៏កងពលអីគេខ្ញុំមិនដឹងទេ ប៉ុនដូចមនុស្សតិចដែរទេ កន្លែងនឹងហើយនៅកោះនឹង ។ ហើយទៅឃើញសម្រាកមើលចុះមើលឡើងនាយអាយ ប៉ុនមិនដែលឃើញនិយាយអីដែរ ព្រោះវាអត់មានមនុស្សអីប៉ុន្មានផងនៅកោះនឹង ។ ហើយបើហូបបាយហូបទឹកអីហើយនឹងក៏ ប្រហែលជាម៉ោង ឬ២ម៉ោងអីនឹងវិលវិញ បានចេញ ។

ដានី ៖ គាត់ទៅតែម៉ោង ២ម៉ោងទេ?

ប៊ិន ៖ បាទ!

ដានី ៖ ទៅពេលណាទើប?

ប៊ិន ៖ ទេ!អញ្ចឹងបានខ្ញុំនិយាយនាំគ្នាថា វាអត់ចាំឆ្នាំ ខែ ។

ដានី ៖ បាទ!ប៉ុន្តែគាត់ទៅពេលព្រឹកពេល ថ្ងៃពេលល្ងាច?

ប៊ិន ៖ បើកាលណាគាត់ចេញដំណើរច្រើនពេលព្រឹក ។

ដានី ៖ ពេលព្រឹកហ៎?

ប៊ិន ៖ ព្រោះគាត់មិន ប្រហែលជាមិនសូវនៅដេកនេះទេ ។

ដានី ៖ គាត់ៗជិះកប៉ាល់បណ្តែត ហើយកប៉ាល់អីទៅ?

ប៊ិន ៖ អឺ!ជួនជិះអាការពារ ជួនជិះអាបណ្តែត ប៉ុនអាបណ្តែតនឹងដូចជា វាលឿនហើយវាតូចវាសាចទឹកណា ភាគច្រើនមិនសូវជិះអានឹងទេ ច្រើនអាការពារ ។

ដានី ៖ ជិះអាការពារ?

ប៊ិន ៖ បាទ!ការពារវាធំហើយវាមិនសូវលឿន ។

ដានី ៖ បាទ! កាលនឹងពូធ្លាប់ អឺ!ដូចទៅធ្វើអមក្នុងកប៉ាល់ជាមួយគាត់ទៅដែរ?

ប៊ិន ៖ បាទ!រួចកាលនោះខ្ញុំអឺ!ដូចជានៅបុគ្គលិក ។

ដានី ៖ បាទ! គាត់អឺ!ច្រើនអមទៅជាមួយសុន សេន?

ប៊ិន ៖ បាទ!

ដានី ៖ ចុះខាងកងពលយើងមានអមទៅជាមួយគាត់ទេ?

ប៊ិន ៖ បាទ!កងពលក៏ទៅដែរ វា ដល់នឹងហើយកងពលទៅហើយ ។

ដានី ៖ កងពល អឺ!តា?

ប៊ិន ៖ តាមុតនឹង តាមុត តាអឺ!តាញ៉ាន់ នឹងហើយឃើញច្រើនទៅតាមុត ហើយនឹងតាញ៉ាន់ ។

ដានី ៖ ចុះប៉ុលពត គាត់រុះរាយអត់ដូចថាយើងជិះក្នុងកប៉ាល់ជាមួយគ្នាអី គាត់ដូចថាមាននិយាយស្អី?

ប៊ិន ៖ លេងសើចច្រើនតើ លេងសើចជាមួយយើងច្រើន ប៉ុនមិនមែនដូចថាលក្ខណៈប្រុកប្រាចជាសាមញ្ញទេ មិននេះ ៗ និយាយ ប៉ុននៅតែក្នុងក្របខ័ណ្ឌគាត់និយាយលេងសើច ប៉ុនកាលនោះគាត់មិនមែនហៅបង ហៅប្អូនអីទេ មិត្ត បាទ!គឺនិយាយមិត្ត គឺជា ។

## កាសែ្សតទី២ ផ្នែក«ខ»

ប៊ិន ៖ មិនសូវមាត់កអីម៉ាទេ ប៉ុន្តែដូចនិយាយលេងដែរ នេះចេះ ។

ដានី ៖ កាលនោះពូមានចាំថាពាក្យគាត់និយាយលេងជាមួយ?

ប៊ិន ៖ ហ៎!មិនបានចាប់អារម្មណ៍ទេ ប្អូន អត់បានចាប់អារម្មណ៍ទេ បាទ!រឿងនឹង ។

ដានី ៖ ប៉ុន្តែគាត់មើលទៅ ចរិតគាត់រុះរាយ រាក់ទាក់អីអញ្ចឹងដែរ?

ប៊ិន ៖ បាទៗរុះរាយរាក់ទាក់អីធម្មតា អឺ!ប៉ុនគ្រាន់យើងដឹងថាគេអ្នកធំ យើងមិនសូវហ៊ាននឹងគេបាទ! ប៉ុន ៗ

ដានី ៖ ចុះដល់ពេលគាត់ទៅអញ្ចឹងគាត់មានដូចថាកងការពារផ្ទាល់ខ្លួនគាត់ ទៅជាមួយគាត់ដែរ ហើយអត់ទេ?

ប៊ិន ៖ បាទ!មាន២ ៣នាក់អីនឹងដែរនឹង ។

ដានី ៖ ពូមានស្គាល់ដែរអត់ទេ?

ប៊ិន ៖ អត់ទេ អត់ដែលស្គាល់ក្លួយ ពួកខាង ។

ដានី ៖ បាទ!ចុះពេលដែលគាត់ជិះក្នុងទូការពារអញ្ចឹង គាត់ច្រើនតែនៅ អឺ!គាត់ជិះនៅកណ្តាលទូក ឬក៏នៅជិះអឺ!តៃកុង?

ប៊ិន ៖ បាទ! នៅកន្លែងៗតៃកុង បើកបរ ។

ដានី ៖ កន្លែងតៃកុង?

ប៊ិន ៖ បាទ!មានកន្លែងនឹង ដែលបាំងខ្យល់បាំងទឹក ។

ដានី ៖ អូ!នៅក្នុងម៉ានេះនឹង ដូចថាទៅគ្នាច្រើនដែលនៅក្នុងកប៉ាល់ការពារនឹង?

ប៊ិន ៖ បាទ!អានឹងបើថាមានដូនដំណើរគាត់ទៅអញ្ចឹងមានកប៉ាល់៣អីអញ្ចឹងទៅ បាទ!អមដំណើរ ។

ដានី ៖ កន្លែងៗកោះកុងនឹង មិនមែនខេត្តកោះកុងទេ?

ប៊ិន ៖ មិនមែនខេត្តទេ កោះ ។

ដានី ៖ កោះ?

ប៊ិន ៖ បានន័យថានៅកោះ ។

ដានី ៖ កោះនឹងនៅម្តុំណាទៅ?

ប៊ិន ៖ កោះកុងនឹងហ៎ ។

ដានី ៖ បាទ!

ប៊ិន ៖ កោះកុងនឹង អានឹងផ្លូវចូលមកត្រពាំងរូង មកត្រពាំងអីនេះ ត្រពាំងរ៉ូងអណ្តូងទឹកនេះ ។

ដានី ៖ អូ!ផ្លូវ ប៉ុន្តែទៅតាម?

ប៊ិន ៖ បាទ!ទៅតាម មកផ្លូវពីនឹងមក គឺមកនឹង ផ្លូវពីជិតផ្លូវទឹកមកនឹង បាទ! ។

ដានី ៖ បាទ!តែទៅប្រហែលម៉ាម៉ោង២ម៉ោងអី គាត់ត្រឡប់មកវិញ?

ប៊ិន ៖ បាទ!

ដានី ៖ ត្រឡប់មកកំពង់សោមវិញ?

ប៊ិន ៖ បាទ!

ដានី ៖ ពូកាលនឹងមិនដឹងថាគោលបំណងគាត់ទៅទស្សនៈកិច្ចធម្មតា ឬក៏គាត់ទៅមានការអី?

ប៊ិន ៖ បាទ!មិនដឹងមានការអី ព្រោះធម្មតាអញ្ចឹង យើងមិនអាចហ៊ានជិតគេទេ ដូចខ្ញុំនិយាយថា ដដែលៗ នាទីរបស់យើងស្អី សមមានអ្នកធំអ្នកអីទៅចេះទៀត អត់ហ៊ានចោលកន្ទែងឆ្ងាយសោះ ។ ព្រោះបើកាលណាត្រឹមតែមានបញ្ជាភ្លាម បញ្ជា អឺ!នែក!ដំណើរការគ្រឿងទាំងអស់នឹងត្រូវដើរម៉ង បាទ! ។

ដានី ៖ បើតាមពូមានប្រសាសន៍ គាត់ទៅ២ដង ទៅកោះកុងនឹង?

ប៊ិន ៖ បាទ!នឹងតាមខ្ញុំធ្លាប់ អឺ! ។

ដានី ៖ ដូចថាទៅលើកទី១នឹង ដូចថាពេលបែកឆ្នាំ៧៥មកខ្វង់រយៈពេលប៉ុន្មាន?

ប៊ិន ៖ ហ៎!ទៅនឹងក្នុងកំឡុង៧៦ ឬ៧៧នឹងឯង ៧៦ប្រហែលជាទៅម្តង ៧៧ប្រហែលទៅម្តង បាទ! ។

ដានី ៖ តែ២ដងនឹងទេ?

ប៊ិន ៖ បាទ!អានឹងៗ តាមខ្ញុំអឺ!ធ្លាប់រួមដំណើរជាមួយគាត់ ប៉ុន្តែត្រង់បំណងរបស់គាត់និយាយអីៗ យ៉ាងម៉េច យ៉ាងម៉ាយើងអត់ដឹងរឿងទេ ។

ដានី ៖ ចុះពេលដែលក្រោយពីព្រឹត្តិការណ៍ដែលគាត់ទៅហើយ ដូចថាមានលក្ខណៈអីប្លែក ព្រឹត្តិការណ៍អីប្លែកទេ?

ប៊ិន ៖ មិនៗបាន យើងមិនបានចាប់អារម្មណ៍អញ្ចឹងទេ ខ្ញុំអត់បានដឹងរឿងទេ ។

ដានី ៖ ចុះដូចអឺ!នួន ជាអី ពូឃើញគាត់នៅពេលណា?

បិន ៖ ឃើញ អានឹងឃើញនៅពេលដែលដូចថាទៅរៀននយោបាយម្តងម៉ាយាមនឹង ឃើញដល់ពេលបើកវគ្គ ។

ដានី ៖ បើកវគ្គហ៎?

បិន ៖ បាទ!បើកវគ្គនឹងគេមានជាគណៈអធិបតីហែរៗរបស់គាត់អញ្ជើងមក បាទ!ជាប៉ុល ពត ជាអី! នួន ជា អឺ!អៀង សារីមួយទៀត នឹងហើយ អៀង សារីអីអញ្ជើងមក ហើយតាម៉ុកអីនឹង ។

ដានី ៖ តាម៉ុកហ៎?

បិន ៖ បាទ! អានឹងពេលបើកវគ្គ ច្រើនឃើញអញ្ជើងហ៎ ។

ដានី ៖ ចុះមាននួន ជាអី គាត់មានដែលមកខាងជើងទឹក?

បិន ៖ ខ្ញុំដល់នឹងខ្ញុំភ្លាប់អត់បានវិញ ព្រោះអត់សូវដែលឃើញមិនដែលនាំដំណើរទស្សនៈកិច្ចអីជាមួយគាត់ទេ ។

ដានី ៖ បាទ! នួន ជាអី អឺ!អៀង សារី?

បិន ៖ បាទ!

ដានី ៖ ហើយខៀវ សំផនអី គាត់មានដែលមក?

បិន ៖ បាទ!ខៀវ សំផនអីក៏ខ្ញុំមិនដែលបាន និយាយម៉ាម៉ាត់ ខៀវ សំផន ខ្ញុំអត់សូវបានជួបទេ ។ បាទ!ខៀវ សំផន កាលមុនដូចខ្ញុំជួបតែម្តង បាទ!ជួបតែម្តង ព្រោះកាលនោះបើកវគ្គដូចខ្ទង់មុំ ៧៦នឹង ។ បើៗនួន ជានឹង គ្រាន់ខស្សាហ៍ជួបនៅពេលបើកវគ្គតែញឹក ប៉ុន្តែខ្ញុំមិនមែនបានទៅរៀនញឹកញាប់ទេ មួយឆ្នាំជួនបានទៅម្តង បាទ!អញ្ជើងទេ ។

ដានី ៖ បាទៗ នួន ជា គាត់បើកវគ្គគាត់ច្រើននិយាយ គាត់បង្រៀន គាត់នៅពេលនឹងគាត់ច្រើននិយាយរឿងអីទៅ?

បិន ៖ បាទ!សំខាន់ និយាយពីរឿងដូចខ្ញុំនិយាយខាងដើមអញ្ជើង ការអប់រំរបស់គាត់សំខាន់ពីរឿងការពារប្រទេស កសាងប្រទេស ។

ដានី ៖ បាទៗ កសាងប្រទេស ការពារប្រទេស?

បិន ៖ បាទ!

ដានី ៖ ដូចពូមានប្រសាសន៍ខាងដើម ដូចថាកាលនឹងដូចមានការបាត់ខ្លួន មានគេអីចាប់ច្រើនអីនៅក្នុងកងពលជាមួយគ្នា ដូចកងពល១៦៤អីនឹង?

បិន ៖ បាទៗ បាត់ច្រើនតើ ។

ដានី ៖ ដូចថាពួកគាត់នឹង ដែលបាត់ទៅនឹង ច្រើនដូចថាខុសអី មានបញ្ហាអីដែលបាត់នឹង?

បិន ៖ អានឹងៗខ្ញុំមិនបានយល់ទេ ប៉ុនសំខាន់គឺនិយាយកាលនោះ និយាយពីរឿងនិន្នាការៗវាមានប៉ុន្មានយ៉ាង ម៉ាយ៉ាងនិន្នាការតាមសាច់សាលោហិត ប៉ុនម៉ាយ៉ាងទៀត និន្នាការតាមមេបញ្ជាការដឹកនាំ បាទ!ៗ សាច់សាលោហិត ក្រែងលរបង ប្អូន ម៉ែឪអីចូលធ្វើទាហាន អានឹងមាននិន្នាការមួយ តាមការដឹកនាំក៏អញ្ចឹងដែរ ជូនអ្នកដឹកនាំជាមេវរសេនាធំ វរសេនាតូចអីអញ្ចឹងមក គេមានពាក់ព័ន្ធជាមិត្តជាភ័ក្ត ជាម៉ែជាឪសាច់ឈាមគេអញ្ចឹងដូចគ្នា ការស្រាវជ្រាវបើមានពាក់ព័ន្ធ ឬក៏ពាក់ព័ន្ធតាមចំលើយណាមួយ ក៏យើងនេះរងគ្រោះដែរ បាទ! គឺតាមៗនឹងៗ

ដានី ៖ ពូមានប្រសាសន៍ថាទាក់ទងតាមចំលើយណាមួយ ចំលើយយ៉ាងម៉េច ចំលើយ?

បិន ៖ ខ្ញុំមិនៗយល់ទេ ប៉ុនថាគ្រាន់ថាឧទាហរណ៍ថាឆ្លើយដាក់ថាជាសកម្មភាព អឺ!យើងចង់និយាយថាជំនាន់ពាឆ្នាំអីចុះ ជាសកម្មភាពរបស់នេះៗ អ្នកនឹងជាៗបក្សរបស់យួន បាទ!នឹងឧទាហរណ៍ថាអញ្ចឹងណាៗ បាទ!ដូច្នេះ ស្មើនឹងអ្នកខាងនឹងជាមិត្តភ័ក្តរបស់ខ្ញុំ ឬក៏ថាកូនទាហានខ្ញុំ ឧទាហរណ៍ថាអញ្ចឹង ដែលខ្ញុំធ្លាប់ដឹកនាំ ដូច្នេះបើគេចាប់ខ្ញុំ ក៏ត្រូវស្រាវជ្រាវតាមបណ្តាញនឹងទៀតៗ បាទ!ដូច្នេះ វាជាខ្សែរបស់យួន អានឹងវាអញ្ចឹងៗ

ដានី ៖ ចុះកាលនឹងអឺ!ដូចថាគេមានចំលើយអីអញ្ចឹង កាលនៅកន្លែងកងពលនៅខាង៦៨នឹងមានកន្លែងគេកន្លែងសន្តិសុខ កន្លែងអីគេដែរអត់?

បិន ៖ គេ កន្លែងសន្តិសុខគេ កាលនឹងដូចជាគេមាន ប៉ុន្តែកន្លែងវាច្បាស់ណាស់ យើងមិនដឹងទេ អានឹងមួយ ពីរទៀតកន្លែងអ្នកទោសក៏យើងអត់ដឹងវាដាក់ត្រង់ណាដែរ បាទ!ខ្ញុំអត់ដឹងដែរទេៗ មិនដឹងថាហ៎! អ្នកដែលត្រូវចាប់នឹង យកទៅដាក់ត្រង់ណាៗអីត្រង់ណា ខ្ញុំអត់ដឹងទេៗ ហើយសន្តិសុខគេ កាលនឹងគេរៀបចំដែលនឹង ពួកញាន់ ពួកអីនឹងដែលត្រចៀកកំបុតនឹង ហើយអានឹងពួកសន្តិសុខគេហើយនឹងៗ បាទ!មិនមែនតាញាន់យើងនេះ ញាន់មួយទៀត ប៉ុនគាត់ស្លាប់ហើយ គាត់ត្រចៀកកំបុតៗ

ដានី ៖ កាលនឹងគាត់នៅខាងណា នៅម្តុំ?

បិន ៖ កាលនឹងគាត់នៅ បែបម្តុំៗជិតៗកងពលយើង តាមមើល ចេញពីកងពលគេ ប៉ុនមិនយើងមិនដែលបានចូលដល់កន្លែងគេទេៗ បាទ!ប៉ុនគ្រាន់យើងមានដឹងលក្ខណៈថាម្តុំនឹងហើយ កន្លែងកងពលគេ តែកន្លែងណាអ្នកណាត្រង់ណាៗយើងអត់ដឹងទេៗ ព្រោះយើងមិនមានពេលឯណាដែលថា កាលនោះនៅតំបន់កំពង់សោម អ្នកដើងទឹកនៅកំពង់សោម គិចលរថាបានស្គាល់ថាបើនៅអូរ៩នៅត្រង់ណា អូរ៣ត្រង់ណា អូរ១ត្រង់ណា អត់បានដឹងដែរ ព្រោះមានដែលបានដើរឯណាអត់ផងៗ

ដានី ៖ ចុះពូអ្នកដែលបាត់ទៅ ដូចពូរៀបរាប់មុន ដូចឈ្មោះតាៗមាឃ តាង៉ែត ឪមអី?

ប៊ិន ៖ ឆានអី ។

ដានី ៖ ឆានអី បាត់ទៅតាមមើលគេយកគាត់ទៅដាក់គុក ឬក៏បញ្ជូនទៅខាងណាៗមាន?

ប៊ិន ៖ មិនក្តាប់អត់បាន ក្តាប់មិនបាន ។

ដានី ៖ បញ្ជូនមកភ្នំពេញអី?

ប៊ិន ៖ ទេ! គេចាប់ក៏យើងមិនដឹង គេអីក៏យើងមិនដឹង ប្រាប់ថាយូរហ៎!ដូចជាបាត់មុខមនុស្សម៉េចបាទ!វាអញ្ចឹង ហើយអ្នកណាហ៊ានទៅសួរគេ ព្រោះសូម្បីតែខ្ញុំស្និតស្នាលជាមួយប្អូនឯងនឹងចុមខ្ញុំ ស៊ីឪមណាហឺ!ឆាននោះ មិនហ៊ានសួរទេ យើងមិនហ៊ានសួរទេ ។

ដានី ៖ ចុះអញ្ចឹងបានន័យថាកាលជំនាន់នឹង ពូដឹងថាមានគេចាប់ មានគេសម្លាប់មនុស្សដែល កាលជំនាន់ពូនៅ?

ប៊ិន ៖ ដឹងតើ ។

ដានី ៖ ដឹងដែរ?

ប៊ិន ៖ បាទ!

ដានី ៖ ពូដឹងនឹងដឹងអឺ!ដោយសារមូលហេតុអីបានពូដឹង?

ប៊ិន ៖ ដោយសារមានអ្នកខ្លះគេខ្សឹបប្រាប់យើង ។

ដានី ៖ ខ្សឹបហ៎?

ប៊ិន ៖ បាទ!

ដានី ៖ ខ្សឹបប្រាប់ថាម៉េច?

ប៊ិន ៖ គេប្រាប់ថាចាប់អានេះទៅហើយណា ចាប់អានេះ ចាប់អ្នក«ក» អ្នក«ខ»ទៅហើយឯងប្រយ័ត្នខ្លួន ប៉ុនយើងមិនដឹងប្រយ័ត្នវិធីណា ។

ដានី ៖ ខ្សឹបនឹងអ្នក មិត្តភ័ក្តដែលធ្វើការ?

ប៊ិន ៖ បាទ!មិត្តភ័ក្ត ពិសេស មិនភ័ក្តអឺ!នៅអង្គភាពជាមួយគ្នាចាស់យូរហើយនឹងណា ដូចថាវាដឹងចិត្តដឹងថ្លើមគ្នាណា ប៉ុន្តែបើនៅឆ្ងាយពីគ្នា មិនៗឆ្ងាយប៉ុន្មានទេ ដូចថាឆ្ងាយប្រហែលជាកន្លះគីឡូ ឬក៏២០០ ៣០០ម៉ែត្រពីគ្នានឹង ក៏យើងមិនដែលបានដើរទៅទាក់ទងអីដែរនឹងហើយ ។ លើកលែងមានករណីណាមួយ ដែលចៃដន្យដើរជួបគ្នាអីទៅ ហើយបើមិនអញ្ចឹងទេ ក៏បានដឹងរឿងចាប់អានេះ ថ្ងៃនេះចាប់អានេះៗហើយណា គ្រាន់ប្រាប់ឲ្យដឹងអញ្ចឹងទេ ហើយឯងប្រយ័ត្នខ្លួន

អានឹងសម្រាប់មិត្តភ័ក្តយើងដែលស្និតស្នាលតាំងពីមុនៗមកណា ។ ហើយយើងក៏មិនដឹងប្រយ័ត្នវិធីណាដែរ ព្រោះវានៅតែប៉ុននឹង បាទ! ។

ដានី : កាលនឹងពូដែលត្រូ ដែលដឹងពីសន្តិសុខស-២១ដែរអត់?

ប៊ិន : ស-២១!

ដានី : បាទ!

ប៊ិន : អត់ទេៗ ។

ដានី : ចុះពេល ដូចថាពូកាលពូនៅខាងជើងទឹកអីនឹង កាលដូចថាពេលពូអញ្ចឹងមាននឹកបារម្ភនឹកអីនឹកដូចថានឹកដល់សាច់ញាតិ បងប្អូន ឪពុកម្តាយ ដែលនៅស្រុកភូមិអីយ៉ាងម៉េចដែរ?

ប៊ិន : នឹកតើ ដល់ៗអាយើងឃើញអាយើងឃើញអាសភាពការណ៍រំដើបរំដួបចាប់កាន់តែខ្លាំងនោះទី១ យើងនឹកដល់បងប្អូននោះហើយ ប៉ុន្តែទី២ៗគិតថាវើរុះវើមើលអត់ឃើញ យើងមើលអាដកអត់ឃើញណា ។ ប៉ុនសំខាន់វាព្រួយបារម្ភខ្លួនយើង ចំ!ដឹងនៅណាដែលទេអញ ដឹងនៅណាទេ ។

ដានី : កាលនឹងពូនឹកអញ្ចឹងដែរ?

ប៊ិន : ហ៎!បើមិននឹកម៉េច ព្រួញៗមែនទែន ព្រោះយើងឃើញអ្នកទាំងឡាយទាំងពួងដែលនៅជាមួយយើងហើយបាត់ៗខ្លួនទៅវាអត់មានសកម្មភាពអី ដែលគួរឲ្យយើងអឺ!កត់សម្គាល់ណា ។ ហើយដល់អញ្ចឹងយើងក៏មិនដែលមានសកម្មភាពអី យើងធ្វើការជាប្រុងប្រយ័ត្នដូចគ្នា ប៉ុន្តែមិនម៉េចក៏គេចាប់អានោះ ហើយយើងវាអត់មានសកម្មភាពអីផងនឹង ចុះយើងមិនដឹងម៉េចដែរ បាទ! ដូច្នេះការព្រួយបារម្ភគិតអញ្ចឹង ។

ដានី : ចុះអឺ!កាលជំនាន់ដូចថាពូរស់នៅក្នុង អឺ!ពេលពី៧៥ ៧៩នឹងពូធ្វើខាងជើងទឹក១៦៤ កាលនឹងអឺ!ពូយល់ឃើញថាកាលនឹង អឺ!ការរស់នៅការៗជួយកងទ័ព កាលពីចន្លោះ៧៥ ៧០អឺ!៧៩ការពូធ្វើកងទ័ពនៅជើងទឹកនឹង ពូយល់ឃើញថាកាលនឹង យ៉ាងម៉េចដែរ ដូចថាការរស់នៅក្នុងរបបនឹង យ៉ាងម៉េច ស្រួល ឬក៏ពិបាក ឬក៏អីយ៉ាងម៉េចខ្លះ?

ប៊ិន : អឺ!អានឹងវាចេះ ខ្ញុំមិនយល់ដែលទេ ក្នុងភាពដឹកនាំគិតថា ទី១ការហូបចុកហើយមនុស្សសំខាន់ជាងគេគឺការហូបនឹងឯង ។ ហូបចុកនៅបើនិយាយសម្រាប់អង្គភាពជើងទឹករបស់ខ្ញុំម៉ង បើតាមការណែនាំគឺ ត្រូវតែហូបគ្រប់គ្រាន់ បាទ!មួយថ្ងៃ៣ពេលណា តាមការណែនាំរបស់អឺ! ខាងលើៗមក ។ ប៉ុន្តែដល់អឺ! មកក្រោមៗមកកងពលវរសេនាធំអីមក គេមិនដឹងជាមានគំនិតម៉េចទេ ប៉ុនតែគេថាយើងគួរតែកាន់ៗរបប ឧទាហរណ៍ថាម៉ាថ្ងៃៗ២កំប៉ុង ឧទាហរណ៍ថាអញ្ចឹង ២

កំប៉ុងនឹង យើងក្តាប់ចេញម៉ាក្តាប់មក ហើយនៅសល់ប៉ុន្មាន យើងរំលែងមួយថ្ងៃនឹងយើងហូប តែប៉ុននឹងបានហើយ យកម៉ាក្តាប់នេះដើម្បីយកចែករំលែកដល់ប្រជាពលរដ្ឋកន្លែងដែលអត់និយាយ ប្រជាជនដែលអត់ៗ បាទ!អានឹងគេនិយាយអញ្ចឹង ប៉ុនទៅដល់ថាគំនិតគេយ៉ាងម៉េច អឺអឺ!យកអានឹងចែកដើម្បីអីម៉េច ខ្ញុំអត់ដឹងទេ បាទ!រឿងរបស់គេអានឹងៗ

ដានី ៖ ម៉ាថ្ងៃរបប២កំប៉ុង ប៉ុន្តែដល់ពេល?

ប៊ិន ៖ បាទ!២កំប៉ុងឲ្យចាប់ម៉ាក្តាប់ចេញ ដើម្បីសំចៃយកទៅឲ្យអ្នកកន្លែងដែរអត់ៗ

ដានី ៖ បាទ!ចុះគេក្តាប់ចេញទៅ អឺ!ម៉ានេះទៅនៅរបស់ អឺ!របបដែលនៅសល់យើងហូបបានឆ្អែតគ្រប់?

ប៊ិន ៖ បាទ!មិនឆ្អែតទេ រឿងឆ្អែតអត់ឆ្អែតទេ បាទ! វាហើយកាលនឹងយើងកំពុងពេញហូបផង មានអី(សើច) អត់ឆ្អែតទេ បាទ!ៗ

ដានី ៖ អត់ឆ្អែតទេនោះ?

ប៊ិន ៖ បាទ!

ដានី ៖ ចុះកាលជំនាន់នោះពូមានបានថតរូប មាននៅសេសសល់ រូបថត ឬក៏ឯកសារអី អត់ទេ?

ប៊ិន ៖ អត់ទេៗ ៗ

ដានី ៖ អត់សល់នោ៎ះ?

ប៊ិន ៖ ខ្ញុំមិនដែលបានថត ជាមួយរូបមួយណាៗ

ដានី ៖ ចុះរូបថតខ្លួនឯង រូបថតអីកាលពីសម័យនោះមក?

ប៊ិន ៖ អត់មានៗ

ដានី ៖ អត់មាន ឯកសារអីក៏ពូអត់ដែលមានសល់ទេ?

ប៊ិន ៖ អូ!រលាយនៅនឹងព្រៃ ចូលក្នុងព្រៃអត់បាយ មិនស្តាយរឿងឯកសារ បាទ!ៗ

ដានី ៖ អឺ!ចុះមកដល់សព្វថ្ងៃពូដែលឮពត៌មានស្តីពីការបង្កើតសាលាក្តីដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម?

ប៊ិន ៖ បាទៗ ឮវិទ្យុនិយាយដែរតើៗ

ដានី ៖ ឮដែរ?

ប៊ិន ៖ បាទ!

ដានី ៖ ពូយល់ឃើញម៉េចដែរ តាមចិត្តគំនិតរបស់ពូផ្ទាល់?

ប៊ិន ៖ បាទ! ចិត្តគំនិតរបស់ខ្ញុំៗថាវាគ្រាន់មានអារម្មណ៍មួយថា ដើម្បីយុត្តិធម៌បន្ធំចិត្តត្រូវតែកាត់ទោស បាទ!ត្រូវតែកាត់ ត្រូវតែរកឲ្យឃើញនូវយុត្តិធម៌ ។ ពាក្យថាយុត្តិធម៌ថា តើអ្នកណាខុស អ្នកណាត្រូវ ។ បាទ! ខ្ញុំក៏ចង់ដឹងថាផែនការនឹងដែរ ព្រោះនៅសាច់ឈាមខ្ញុំក៏គេចាប់សម្លាប់ដូចគ្នា បាទ! សម្លាប់អឺ!បងខ្ញុំ អានឹងបងជីដូនមួយទេ ប្អូន បាទ!វាមានបងមានប្អូនមានដល់អឺ!ពូ បាទ! ។ ដូច្នេះ ខ្ញុំឈឺចាប់ដូចគ្នាបញ្ហានឹងថ្មីត្បិតតែខ្ញុំបានយករូបខ្លួនប៉ុននេះ ប៉ុន្តែក៏នៅជួរចត់អំពីអាយុជីវិត សាច់ឈាមនេះដែរ ។

ដានី ៖ ពូបាត់បងៗសាច់ញាតិ អស់ប៉ុន្មាននាក់?

ប៊ិន ៖ ខ្ញុំបាត់អស់អឺ!សាច់ញាតិនឹងអស់អឺ!បងជីដូនមួយ ប្អូនជីដូនមួយ២ ៣ បាទ! ហើយនឹងពូ១ ។

ដានី ៖ ចុះពួកគាត់នឹង អឺ!ស្លាប់ទៅនឹងស្លាប់ដោយសារមូលហេតុអី?

ប៊ិន ៖ ពួកដែលស្លាប់នឹង!

ដានី ៖ បាទ!ដូច ។

ប៊ិន ៖ ស្លាប់នឹងគេចាប់យកទៅ ។

ដានី ៖ ដូចគេចោទគាត់?

ប៊ិន ៖ បាទ!នឹងចាប់នឹងហើយមិនដឹងគេចោទយ៉ាងម៉េចដែរ នឹងខ្ញុំក្រោយពីខ្ញុំមកពីអឺ!មកចូលស្រុកវិញខ្ញុំសាក់សួរទៅដឹង បងប្អូននិយាយប្រាប់អញ្ចឹងណា៎ ។ សូម្បីតែឪពុកខ្ញុំ ប្អូនខ្ញុំក៏គេដេញចាប់ដែរ ប៉ុន្តែកាលនោះដូចជាគេចែកតំបន់ម៉េច ព្រោះកាលនឹងយើងនៅតំបន់តាកែវ ហើយខាងតាកែវដេញចាប់ប៉ិតប៉ីង គ្រាន់ឆ្លងព្រៃមកដល់ខាងកំពត ខាងឈ្លបកំពតគេស្វាគមន៍ ដល់អញ្ចឹងអឺ! បានឪពុកខ្ញុំ បងប្អូនខ្ញុំបានរស់នឹង កុំអីប្រហែលជាចប់អស់ហើយ កាលនឹង ។ ហើយមិនដឹងជាទោសកំហុសអីដែរ ខ្ញុំមិនបានដឹងដែររឿងនឹង ។

ដានី ៖ បាទៗ អញ្ចឹងពូចាំមើលដែរ ចាំមើលតុលាការនឹង ចង់ដឹងថាយើង?

ប៊ិន ៖ បាទៗ ចាំមើល ចង់ដឹងដែរ បាទ! តើអ្នកណាខុស អ្នកណាត្រូវ អ្នកណាយុត្តិធម៌ ។

ដានី ៖ អឺ!អញ្ចឹងដូច ពួកខ្ញុំអស់សំនួរអីត្រូវសួរ ។

ប៊ិន ៖ បាទៗអរគុណច្រើន ។

ដានី ៖ ហើយអញ្ចឹង អឺ!ពូមានអីចង់បន្ថែមនូវអ៊ីដែលពួកខ្ញុំអត់ទាន់បានសួរនាំពូ?

ប៊ិន ៖ បាទ!ខ្ញុំអត់មានថាម៉េចទេ ខ្ញុំគ្រាន់មានសំណូមពរថាបើការកាត់ទោសរៀបចំសាលាក្តីកាត់ទោសខ្មែរក្រហមនេះ បើកាន់តែឆាប់ កាន់តែល្អ ។

ដានី ៖ បាទៗ ហើយឥឡូវនឹងអឺ!តុលាការកាត់ក្ដីខ្មែរក្រហមនឹង អឺ!គេដំណើរការទៅធម្មតា គេមានអង្គភាពគេដូចជាចៅក្រមៗស៊ើបអង្កេត ព្រះរាជអាជ្ញ ខាងអឺ!រដ្ឋបាលគេធ្វើការធម្មតា ៗប៉ុន្តែគេកំពុងតែរង់ចាំវិធានផ្ទៃក្នុងណា៎ ដើម្បីឯកភាពគ្នារវាងខាងៗខ្មែរ និងខាងអន្តរជាតិនឹងត្រូវគ្នា នឹងគេចាប់ផ្ដើមដូចថាបើកសវនាការដូចជា ចេញដីកាកោះហៅ ឬក៏អ្នកណាដែលត្រូវគេចោទប្រកាន់ ដែលមានឯកសារ ភស្តុតាងនឹង គេចាប់ផ្ដើមកោះហៅគេបើកសវនាការ ។

ប៊ិន ៖ បាទ!អរគុណ ។

ដានី ៖ អញ្ជើញខ្ញុំអរគុណពូច្រើន ។

ប៊ិន ៖ បាទ!អរគុណ ។

«ចប់»